01137067

E1/339.1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 07-Sep-2015, 08:00

CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី៣២០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ហ្វីលីព រ៉ូជឺ *(Mr.Philips ROGER)*

លោក ឯម ហ៊ុយ

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរលក្ស័

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ែន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុិច អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
| --- | --- |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោកស្រី នួន ណារុំ (2-TCCP-991) | ខ្មែរ |
| លោកស្រី ចៅ ឡាង (2-TCCP-992) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី នួន ណារុំ** (2-TCCP-991)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ៥
ស្ទួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........................................ ទំព័រ ៨
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាងល ផ្តើមពី ........................................ ទំព័រ ២០
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ........................................ ទំព័រ ២៦
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី ........................................ ទំព័រ ៣៤

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ចៅ ឡាច** (2-TCCP-992)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ៤២
សួរដោយលោក ឡៅ ជុនធី ផ្តើមពី ........................................ ទំព័រ ៤៤
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាងល ផ្តើមពី ........................................ ទំព័រ ៥៨
សួរដោយលោក លីវ សុវណ្ណា ផ្តើមពី ........................................ ទំព័រ ៦៤
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី ........................................ ទំព័រ ៧០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៣៤]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ និងនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់នូវសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ដែលដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពាក់ព័ន្ធនឹង អង្គហេតុទំនប់១មករា ទំនប់ត្រពាំងថ្មដែលសរុបទាំងអស់មានចំនួនបួនរូប គឺដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-991, 2-TCCP-992, 2-TCCP-993 និង 2-TCCP-994។ ដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងមកថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មមុនគេនៅព្រឹកនេះ គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-991។

ក្រឡាបញ្ជីសវនាការលោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ៗ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងត្រូវមកថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម សម្រាប់រយៈពេលពីរថ្ងៃនេះ មានចំនួនបួនរូប ដែលមានរហស្សនាម 2-TCCP-991, 2-TCCP-992, 2-TCCP-993 និង 2-TCCP-994។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនរូបនេះ មានវត្តមានរួចហើយនៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ឯម ហ៊ាយ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះ បានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ដង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥។

មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃសិទ្ធិនៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬសិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៥:៣៦]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់នៅ អ.វ.ត.ក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ បានកត់សម្គាល់អំពីស្ថានភាពសុខភាពរបស់លោក នួន ជា ថាមានអាការៈឈឺចង្កេះជាប្រចាំ មិនអាចអង្គុយយូរបាន និងផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសវនាការនេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៦:៤០]

មុននឹងធ្វើការតាំងសំណួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ និងដោយកត់សម្គាល់ពីការជំទាស់របស់សហមេធាវីការពារក្ដី ខៀវ សំផន ពាក់ព័ន្ធនឹងការប្រើប្រាស់ឯកសារ E319/25.3.24 ដែលស្នើសុំសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីកាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ ឧបសម្ព័ន្ធ(ក) នៃឯកសារE319/31 អង្គជំនុំជម្រះសូមសួរបញ្ជាក់ទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីថាតើខ្លួនរក្សាជំហរក្នុងការស្នើសុំប្រើប្រាស់ឯកសារ E319/25.3.24 នេះដែរឬទេ បន្ទាប់ពីដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-995 ត្រូវបានដកចេញពីបញ្ជីឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានមកថ្លែងរៀបរាប់ទុក្ខសោកវេទនា និងព្យសនកម្មនាពេលនេះ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។ យើងបានអានសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីលោក ខៀវ សំផន យើងមិនមានការជំទាស់អ្វីទៅនឹងសេចក្ដីសន្និដ្ឋាននេះទេ ដោយសារតែយើងបានបង្ហាញឯកសារពាក់ព័ន្ធរួចមកហើយសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីប្រាំរូប។ ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបដែលត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខៗអង្គជំនុំជម្រះនៅថ្ងៃនេះ គឺត្រូវបានលុបចោលវិញនៅនាទីចុងក្រោយ។ ដូច្នេះមិនមានការលំបាកអ្វីទេចំពោះឯកសារដែលពាក់ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ មិនត្រូវបានចាត់ទុកថាទទួលយកដោយអង្គជំនុំជម្រះនោះ។ យើងខ្ញុំគោរពតាមអនុសាសន៍របស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងភាពចាំបាច់ក្នុងការដាក់សំណើមួយ។

[០៩:០៩:១០]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបន្តទៀតបាទ! អញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

យើងបានដាក់ឯកសារនេះបញ្ចូល ពីព្រោះថាដើមបណ្ដឹងរដ្ឋប្បវេណីនេះត្រូវបានចាត់ទុកថាមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ យើងបានផ្ដល់ជូនអង្គជំនុំជម្រះ និងភាគីនៅថ្ងៃសុក្រ ថាដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះមិនមានភាពទំនេរទេ។ ដូច្នេះយើងគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ ថាតើឯកសារនេះគួរតែទទួលយក ឬមិនទទួលយក។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយខាងយើង គឺយើងមិនចង់ប្រើប្រាស់ឯកសារនេះទេ ពីព្រោះដើមបណ្ដឹងរដ្ឋប្បវេណីនេះ គាត់មិនមកផ្ដល់

សក្ខី -- គាត់នឹងមិនផ្តល់សក្ខីកម្មអំពីព្យសនកម្មនោះទេ។ ដូច្នេះខ្ញុំគិតថា ខ្ញុំអាចបានផ្តល់នូវគោលជំហរខាងដើមបណ្តឹងរដ្ឋប្បវេណីរួចមកហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនដល់ភាគី និងសារធារណជនជ្រាបផងដែរថា នៅរសៀលនេះ នៅពេលចាប់ផ្តើមសវនាការអង្គជំនុំជម្រះនឹងធ្វើការដោះស្រាយទៅលើបញ្ហានៃការដាក់ឯកសារគន្លឹះដែលធ្វើបានធ្វើសវនាការកាលពីសប្តាហ៍មុន ហើយមានបញ្ហាចម្រូងចម្រាសនោះ។

អង្គជំនុំជម្រះបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-992 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្ម ឬក៏ធ្វើសេចក្តីថ្លែងរៀបរាប់ទុក្ខសោកវេទនានៅចំពោះមុខអង្គជំនុំជម្រះក្នុងបន្ទប់សវនាការនេះ រួមទាំងបុគ្គលិកនៃអង្គការ ធី.ភី.អូ ផង។

[០៩:១១:២៧]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធានខ្ញុំសូមបំភ្លឺមួយ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះចូលមក។ លោកប្រធានបានបញ្ជាក់ថា យើងនឹងពិភាក្សាអំពីឯកសារគន្លឹះនៅរសៀលនេះ។ នេះជាអ្វីដែលខ្ញុំស្តាប់ឮតាមរយៈការបកប្រែជាភាសាបារាំង។ ដូច្នេះខ្ញុំចង់បានការបំភ្លឺពាក់ព័ន្ធនឹងចំណុចនេះ ដើម្បីឲ្យយើងអាចត្រៀមខ្លួនបាន ប្រសិនបើអង្គជំនុំជម្រះសម្រេចថានឹងមានការពិភាក្សាគ្នាទៅលើឯកសារគន្លឹះនៅរសៀលនេះនោះ ព្រោះថាយើងអត់មានបានទទួលព័ត៌មានអីជាមុនអំពីរឿងថា ពិភាក្សាគ្នារឿងឯកសារគន្លឹះនេះទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ទំនងជាភាសាស្តាប់ច្រឡំ ឬក៏ខ្ញុំប្រើពាក្យច្រឡំ ខ្ញុំសរសេរដូចជាច្បាស់លាស់ហើយ គឺបញ្ហាហ្នឹងគឺយើងមានដំណោះស្រាយរួចហើយ។ យើងផ្សព្វផ្សាយ និងសេចក្តីដំណោះស្រាយរបស់អង្គជំនុំជម្រះចំពោះបញ្ហាដែលកើតមានកន្លងមក ដើម្បីឲ្យបញ្ហានៃការសវនាការដាក់បង្ហាញឯកសារគន្លឹះនាពេលខាងមុខ វាប្រព្រឹត្តទៅបានរលូនល្អ វាចៀសវាងបញ្ហាចម្រូងចម្រាសជាបន្តបន្ទាប់ទៀត។ គ្រាន់តែយើងជម្រាបជូនថា យើងនឹងធ្វើនៅរសៀលនេះនៅពេលដែលចាប់ផ្តើមសវនាការនៅរសៀល។ បាទដោយសារបញ្ហានៅព្រឹកនេះ យើងនៅមានបញ្ហាមួយចំនួនដែលត្រូវដោះស្រាយបញ្ចប់នៅព្រឹកនេះប៉ុណ្ណោះទេ។ មិនមានដេញដោលអីទៀតទេ យើងនឹងចេញដំណោះស្រាយសមស្រប ដើម្បី

អាចឲ្យដំណើរការហ្នឹងវាប្រព្រឹត្តទៅបានទៅមុខទៀត។

[០៩:១៣:០៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី! តើលោកស្រីឈ្មោះអី?

**លោកស្រី នួន ណារុំ៖**

**ឆ៖** ចាស សូមគោរពលោកប្រធាន។ សូមគោរពមេធាវី និងភ្ញៀវជាតិ អន្តរជាតិទាំងអស់។ នាងខ្ញុំឈ្មោះ នួន ណារុំ។ កើតនៅឆ្នាំ១៩៥៦។ មានស្រុកកំណើតស្រុកចំការលើ ខេត្តកំពង់ចាម។

**ស៖** បាទអរគុណ។ ហើយចុះទីលំនៅសព្វថ្ងៃនេះ រស់នៅទីកន្លែងណា? កុំទាន់អាលឆ្លើយតប!

**ឆ៖** ចាស នាងខ្ញុំសព្វថ្ងៃរស់នៅទីក្រុងភ្នំពេញ។

**ស៖** ហើយលោកស្រីប្រកបមុខរបបធ្វើអ្វីដែរ?

**ឆ៖** ពីឆ្នាំ៨០ជាង នាងខ្ញុំបានបម្រើការងារនៅក្រសួង អេស.ប៉េ.កា តែបច្ចុប្បន្ននៅផ្ទះ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការមាន នរណាគេមកថតរូបអីគេ? មានការអនុញ្ញាតអត់? សួរគាត់ ម៉េចយ៉ាងម៉េចមាន?

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ ឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្តាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

**លោកស្រី នួន ណារុំ៖**

**ឆ៖** ឪពុកបង្កើតនាងខ្ញុំ ឈ្មោះ អ៊ុយ ឈឹម។ ម្តាយបង្កើតឈ្មោះ នូ យ៉ែម។

**ស៖** អរគុណ។ ចុះប្តីរបស់លោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ប្តីនាងខ្ញុំឈ្មោះ ពេជ្រ អានីន។ នាងខ្ញុំមានកូនពីរនាក់ ប្រុសមួយ ស្រីមួយ។

[០៩:១៥:៥០]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនបន្ថែមទៀត នៅក្នុង

អំឡុងពេលស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា របស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននៅក្នុងសវនាការ អង្គជំនុំជម្រះបានរៀបចំនូវបុគ្គលិកអង្គការ ធី.ភី.អូ អង្គុយអមក្បែរដើមបណ្តឹងរដ្ឋប្បវេណីដើម្បីជួយសម្រួលដល់ផ្នែកអារម្មណ៍របស់គាត់ ដើម្បីឲ្យគាត់មានជំហររឹងមាំ នឹងនៅក្នុងការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់គាត់។ ហើយនាពេលនេះគឺមានលោកស្រី ឆាយ ម៉ារីដែត ដែលជាបុគ្គលិកនៃអង្គការ ធី.ភី.អូ។

លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងនាមលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសវនាការនេះ ហើយអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅលោកស្រី ដើម្បីមានឱកាស ថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកស្រីជាអាទិ៍ ព្យសនកម្មខាងផ្លូវកាយ ផ្លូវចិត្ត និងសម្ភារៈ ដែលជាព្យសនកម្មផ្ទាល់ខ្លួន ជាបច្ច័យផ្ទាល់ ពីបទឧក្រិដ្ឋដែលកើតមានពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ដែលនាំឲ្យលោកស្រីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងនេះពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទចំនួនពីររូប នួន ជា និង ខៀវ សំផន ដែលលោកស្រីគិតថា បានប៉ះពាល់ដោយផ្ទាល់ចំពោះលោកស្រីនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[០៩:១៧:៣៣]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

សូមអរគុណលោកប្រធាន។ ដូចដែលយើងបានធ្វើនៅសវនាការលើកមុនអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្ម យើងជាមេធាវី យើងចង់មានលទ្ធភាពក្នុងការសួរសំណួរមួយចំនួនទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីណែនាំតម្រង់ទិសគាត់។ ដូច្នេះ ខ្ញុំចង់សួរសំណួរមួយចំនួនដល់គាត់ ដើម្បីឲ្យគាត់រៀបចំសក្ខីកម្មរបស់គាត់ អំពីព្យសនកម្ម ដូចដែលយើងបានធ្វើកាលពីសវនាការមុនៗអ៊ីចឹងដែរ។ ដូច្នេះខ្ញុំសុំការអនុញ្ញាតពីលោកប្រធាន ឲ្យអនុវត្តដូចរាល់ដង គឺអនុញ្ញាតឲ្យយើងមានសិទ្ធិសួរសំណួរទៅពួកគាត់នៅពេលដែលគាត់ធ្វើសក្ខីកម្មនោះ។

**ប្រធានអង្គជំនុំ៖**

ជាការអនុវត្ត យើងអនុវត្តពីដើមទីមក គឺឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីថ្លែងរៀបរាប់ ក្រោយមកមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបានជម្រើស ដោយសារដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនគាត់

មិនមានលទ្ធភាពធ្វើសេចក្ដីថ្លែងរៀបរាប់ដោយឯកឯងបាន លោកស្រីបានស្នើសុំធ្វើដូច្នេះករណីមួយចំនួន មិនមែនទូទៅទេ។ ហើយយើងបានប្រើប្រាស់នីតិវិធីនេះ ផ្ដល់ឲ្យលទ្ធភាពទាំងពីរ ដោយយើងជាប្រធានអង្គជំនុំជម្រះ យើងអនុវត្តនូវលំហូរនីតិវិធីមួយដែលស្ដាប់នេះ សេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់ខ្លួនគាត់ផ្ទាល់ ប្រសិនបើគាត់មានសមត្ថភាពនៅក្នុងការធ្វើដូច្នេះ វាច្បាស់លាស់ ចេញពីក្រអៅបេះដូង និងអ្វីដែលកើតមានពិតប្រាកដចំពោះរូបគាត់។ ហើយប្រសិនបើគាត់មិនមានលទ្ធភាពទេ គឺអង្គជំនុំជម្រះនឹងទទួលតាមសំណើសុំរបស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ ប្រសិនបើយើងប្រើប្រាស់នូវវិធានការថា ផ្ដល់ឲ្យតែម្ដងនោះ យើងដូចមិនទាន់បានសម្រេចឲ្យច្បាស់លាស់លើបញ្ហានោះដាច់ណាត់ថាយើងធ្វើដូច្នោះទេ។ ពីព្រោះមានករណីមួយចំនួន ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនមានសមត្ថភាព មានលទ្ធភាពនិយាយបាន លោកស្រីបណ្ដោយឲ្យគាត់និយាយដោយគាត់ ដើម្បីឲ្យគាត់អស់ចិត្តគាត់ដែរ។

[០៩:១៩:៤០]

អ៊ីចឹងនីតិវិធីអង្គជំនុំជម្រះបានសម្រេចធ្វើតាមលំហូរនីតិវិធីដែលលំនាំអនុវត្ត។ ហើយប្រសិនបើលោកស្រីមានបំណងដូច្នេះ យើងអនុវត្តតាមវិធានទី២ បានន័យថា ឲ្យគាត់និយាយដោយផ្ទាល់ថ្លែងរៀបរាប់ឲ្យគាត់ ហើយបានសួរបញ្ជាក់ទៅគាត់ ឬក៏លោកស្រីតាំងសំណួរ។ ដូចមិនមានវិធានអីដែលត្រូវទម្លាប់អនុវត្តឯណាច្បាស់លាស់ថា ប្រធានសាលាដំបូងមិនអាចណែនាំឲ្យភាគនិយាយបានទេ ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីថ្លែងខ្លួនឯងបានទេ។ នៅក្នុងអត្ថន័យនីតិវិធី គឺថ្លែងរៀបរាប់ដោយខ្លួនឯង។ នេះគឺគោលដៅចម្បងទី១។ ដំណាក់កាលទី២ទេ ដែលថាបើសិនជាគាត់មិនមានលទ្ធភាពក្នុងការនិយាយស្ដីហ្នឹងបានល្អទេ ឲ្យតាំងសំណួរ។

បាទ យើងផ្ដល់ជូនវេទិកាទៅលោកស្រី ដើម្បីមានលទ្ធភាពក្នុងការសួរសំណួរពាក់ព័ន្ធទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការសម្ដែងនូវទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់គាត់ ដែលនាំឲ្យគាត់តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងនេះ តាមសំណើសុំ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ មូលហេតុដែលយើងចង់សួរសំណួរទៅកាន់គាត់នោះ ពីព្រោះថាយើងចង់ឲ្យដើមបណ្ដឹងរដ្ឋប្បវេណី គាត់ផ្ដោតអារម្មណ៍ទៅលើព្យសនកម្មដែលកើតមាននៅការដ្ឋានណាមួយ។ អ៊ីចឹងហើយ យើងចង់ជួយដល់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងជួយដល់អង្គជំនុំជម្រះ និងភាគី

ទាំងអស់ឲ្យយល់អំពីប្រវត្តិរឿងរ៉ាវរបស់គាត់ ហើយនិងខ្សែជីវិតរបស់គាត់ដែលនៅការដ្ឋាននោះ។ អ៊ីចឹងហើយបានជាយើងចង់សួរសំណួរផ្ដើមមួយចំនួនសិន ដើម្បីឲ្យយើងទាំងអស់គ្នាយល់អំពីរឿងរ៉ាវរបស់គាត់ ហើយនិងមូលហេតុដែលគេបញ្ជូនគាត់ឲ្យទៅធ្វើការនៅទំនប់១មករា។

[០៩:២១:៤០]

**ប្រធានអង្គជំនុំ៖**

ដូចយើងអនុញ្ញាតហើយអំមិញ ដូចអត់មានអត្ថាធិប្បាយអីទៀតទេ។ មធ្យោបាយពីរ គឺតាមសំណើសុំ យើងបានអនុញ្ញាតឲ្យលោកស្រីតាំងធ្វើនីតិវិធីសួររបស់គាត់ តាមសំណើសុំហើយ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ សំណួរទី១ ដែលខ្ញុំចង់សួរទៅកាន់លោកស្រី គឺសំណួរសុំឲ្យលោកស្រីបំភ្លឺ ដោយសារតែលោកស្រីបានចុះហត្ថលេខាលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានឈ្មោះផ្សេងពីឈ្មោះដែលលោកស្រីបានប្រាប់ជូនលោកប្រធាន នៅថ្ងៃនេះ។ ខ្ញុំយោងទៅលើឯកសារលេខ E3/4909 ឯកសារនៅក្នុង -- ឈ្មោះនៅក្នុងឯកសារនេះ គឺខ្ញុំសូមអានដូចតទៅ អ៊ុយ សំណា។ សូមអធ្យាស្រ័យផង បើសិនបើខ្ញុំអានឈ្មោះនេះមិនត្រឹមត្រូវ។ អ៊ីចឹងសូមលោកស្រីបញ្ជាក់ផងថា ឈ្មោះហ្នឹងជាឈ្មោះអ្នកណាគេដែរ?

**លោកស្រី នួន ណារុំ៖**

**ឆ៖** ចាស សូមអរគុណ។ ឈ្មោះ អ៊ុយ សំណា នេះគឺជាឈ្មោះក្នុងបញ្ជីជាតិរបស់នាងខ្ញុំ។ ដល់ពេលក្រោយ៧៩មក នាងខ្ញុំរស់នៅជាមួយបងប្អូន ហើយតែនាងខ្ញុំមានឈ្មោះពីរនៅតាំងពីដើម ឈ្មោះ សំណា ឈ្មោះ ណារុំ។ តែដល់ពេលដាច់សម័យខ្មែរក្រហមហើយ នាងខ្ញុំរស់នៅជាមួយបងប្អូន ធ្វើស្ថិតិនាងខ្ញុំមិននៅ គាត់មិនដឹងជាត្រកូលនាងខ្ញុំអី គាត់ក៏ដាក់ នួន ណារុំ ទៅ។ តែ "នួន" នេះគឺមិនមែនជាត្រកូលអី សាច់ញាតិអីទេ ប៉ុន្តែដល់គាត់កត់ស្ថិតិអ៊ីចឹងទៅ ត្រូវធ្វើអត្តសញ្ញាណប័ណ្ណឈ្មោះនេះ ចាស។

[០៩:២៣:៤៧]

**ស៖** សូមអរគុណលោកស្រី។ តើលោកស្រីរស់នៅទីណា នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥?

ហើយលោកស្រីពេលនោះមានអាយុប៉ុន្មាន? ហើយលោកស្រីរស់នៅជាមួយសមាជិកគ្រួសារណាខ្លះ?

**ឆ៖** ចាស ក្នុងសម័យ៧៥ នាងខ្ញុំបានភៀសខ្លួនមកនៅភ្នំពេញ នៅផ្ទះបងជីទូតមួយនៅបឹងត្របែក។ ដល់កាលគ្រាប់ផ្គោងខ្លាំងពេក នាងខ្ញុំក៏បានមករស់នៅនៅក្នុងវត្តកោះ។ ដល់ថ្ងៃ១៧ មេសានេះ គឺគ្រួសារនាងខ្ញុំនៅជុំបងប្អូនទាំងអស់ជម្លៀសចេញពីវត្តកោះ ទៅតាមផ្លូវមុនីវង្ស ឆ្លងតាមស្ពានច្បារអំពៅ ទៅដល់តាខ្មៅ -- អំ! កៀនស្វាយ។ នៅពេលធ្វើដំណើរតាមផ្លូវហ្នឹង យើងធ្វើដំណើរតាមស្ពានច្បារអំពៅហ្នឹង គឺមានការលំបាកខ្លាំង ដោយក្មួយខ្ញុំតូចៗ ប្រាំពីរប្រាំបីនាក់ តូចជាងគេ១០ខែ យើងឆ្លងកាត់ស្ពានច្បារអំពៅមួយ ចំណាយពេលអស់រាប់ម៉ោង ទម្រាំទៅដល់វត្តក្ដីតាកុយ វារាងរសៀលហើយ។ ហើយគ្រួសារនាងខ្ញុំក៏បានសម្រាកនៅទីនោះ បងថ្លៃក៏ទៅដងទឹកដងអី ដាំបាយឲ្យកូនក្មួយតូចៗញ៉ាំ។ បានជា សម្រាកបានបួនប្រាំថ្ងៃ គ្រួសារនាងខ្ញុំបានធ្វើដំណើរទៅកៀនស្វាយ ដោយធ្វើដំណើរដោយកកកុញ ដោយមនុស្សពាសពេញផ្លូវ។ យើងដំណើរពីត្រឹមកៀនស្វាយ យើងត្រូវសម្រាកកណ្ដាលផ្លូវមួយយប់។ ព្រលឹមឡើងធ្វើដំណើរទៅទៀត ម៉ោងដប់ដល់កៀនស្វាយ ពួកខ្មែរក្រហមបានឲ្យពួកយើងខ្ញុំចុះកាណូតទៅព្រែកពោធិ៍។ ទៅដល់ព្រែកពោធិ៍ អ្នកស្រុកគេទទួលបាយ ដើម្បីឲ្យកូនក្មេងតូចៗញ៉ាំទៅ។ ញ៉ាំហើយ ពួកខ្មែរក្រហមដឹកគ្រួសារនាងខ្ញុំ ព្រមទាំងប្រជាជនទៅស្ទួង ទៅស្ទួងដាក់នៅភូមិតាប៉ាវ។ នៅតាមភូមិតាប៉ាវ នៅពេលនោះដាក់តាមភូមិ គ្រួសារនាងខ្ញុំ បងស្រីបីនាក់ ត្រូវដាក់មួយភូមិម្នាក់ មួយភូមិមួយ នាងខ្ញុំនៅជាមួយម្ដាយ។

[០៩:២៦:១៩]

ពេលនៅបានបួនប្រាំថ្ងៃ ពួកខ្មែរក្រហមយកបងថ្លៃប្រុសៗ ហើយនិងក្មួយម្នាក់ដែលនេះដែរ ធំដែរ ទៅរៀនសូត្របាត់ទៅ។ នៅនឹងភូមិនោះរយៈពេល២ខែ ពួកខ្មែរក្រហមបញ្ជូនពួកនាងខ្ញុំមកទៅព្រែកជីមាន់ នៅភូមិត្រពាំងផ្លុងទៀត។ នៅបានរយៈពេលប្រហែលជាប្រាំប្រាំមួយខែ គេបញ្ជូនខ្ញុំទៅស្រុកចំការលើ ឲ្យទៅនៅ គ្រួសារនាងខ្ញុំទៅនៅភូមិ គេហៅថា ភូមិបី ឈ្មោះ ភូមិបី។ ចាស ក្រោយមកអស់រយៈប្រហែលជាពីរបីខែ នាងខ្ញុំដែលនៅលីវម្នាក់ឯង ត្រូវគេប្រមូលមកនៅកងចល័ត។ កងចល័តហ្នឹង គឺនៅក្នុងវត្តល្វា – វត្តល្វាលើ។ រយៈពេលដែលនៅក្នុងកងចល័តហ្នឹងប្រហែលបានជា ខ្ញុំចាំក្នុងឆ្នាំ៧៧ ខែ០១ បានគេបញ្ជូននាងខ្ញុំទៅលើកទំនប់១មករា។ ចាស ទៅដល់ទំនប់១មករា គឺមានរោងគេធ្វើស្រាប់នៅកណ្ដាលវាលស្រែ ហើយរោងគេប្រក់ចំបើង ក្រាលចំបើង។ នៅពេលនោះនាងខ្ញុំ គឺទៅដល់ភ្លាម គឺគេឲ្យធ្វើការភ្លាម។ ធ្វើការក្នុងរយៈពេលទាំងយប់ទាំងថ្ងៃ គឺគ្មានពេលសម្រាកទេ ពេលយប់ក៏ធ្វើ

ដែរ ព្រោះគេប្រជុំថា គេសម្រុកដើម្បីឲ្យរួចមុនពេលរដូវធ្លាក់ភ្លៀង ឲ្យរួច។

ដូច្នេះការធ្វើការនេះ គឺមានការលំបាកខ្លាំង ហើយការហូបចុកក៏គ្មានស្អីហូបចុកត្រឹមត្រូវ គឺពិបាកៗ មែនទែន ពួកខ្ញុំជានារី គឺត្រូវការអនាម័យ ត្រូវការ – តែគ្មានស្អីទាំងអស់ រស់នៅដោយខោអាវមួយចង្កេះ។ ធ្វើការទាំងយប់ទាំងថ្ងៃ គឺគ្មានបាន -- ពេលឈឺ ឈប់ គេមិនឲ្យយើងឈប់ទេ។ គេថាឲ្យទៅឈឺ ឲ្យទៅដួលនៅកន្លែងឲ្យជាក់ស្តែង ដួលនៅកន្លែង។ នៅក្នុងអំឡុងធ្វើការហ្នឹង គឺគេសង្កេតការណ៍ជានិច្ច អ្នកណាមានទម្រន់ អ្នកណាមិនសកម្មការងារ គឺត្រូវបាត់។ ពួកសង្កាត់របស់ខ្ញុំ គឺបាត់ច្រើន។ ដូច្នេះនាងខ្ញុំធ្វើការ ទោះបីឈឺជា ក៏ខំទៅ គ្មានពេលសម្រាក ហើយការហូបចុក សូម្បីតែទឹក ក៏នាងខ្ញុំមិនដែលបានទឹកល្អហូប។ ពេលធ្វើការ ក្តៅខ្លាំង គឺស្រេកទឹក តែមិនដែលបានទឹក។

[០៩:២៩:៣២]

ក្នុងអំឡុងធ្វើការហ្នឹង នាងខ្ញុំក៏មិនដឹងដែរ អ្នកទាំងអស់គ្នាក៏មិនដឹងម៉ោងប៉ុន្មានដែរ ពេលយើងសម្រាកបាន ពេលសម្រាកបានមួយស្ទុះអ៊ីចឹង គេផ្លុំកញ្ចែឲ្យឡើង។ ហើយចម្ងាយធ្វើការរបស់នាងខ្ញុំ ពីរោងទៅកន្លែងធ្វើការប្រហែលជា៣គីឡូ ពីរោងហ្នឹង។ យើងដើបទៅ ដើរទៅដល់កន្លែងការដ្ឋានហ្នឹង គឺជិតភ្លឺល្អះៗ យើងចាប់រែកដី។ ពួកនាងខ្ញុំ គឺរែកបិទស្ទឹង ស្ទឹងជីនិត ស្ទឹងហ្នឹង បិទស្ទឹង។ ហើយពេលថ្ងៃត្រង់ ត្រូវដើរមកហូបបាយនៅឯរោងវិញ។ តែបាយគឺគេចែកម្នាក់មួយចានអ៊ីចឹង គឺនៅក្នុងបាយហ្នឹង គឺមានរុយ មួយចានហ្នឹងគឺមានប្រាំប្រាំមួយអ៊ីចឹងទៅ។ ហើយយើងហៅ ពេលនោះយើងហៅ មានមិត្តៗខ្លះគេអ្នកប្រជាជនចាស់អ៊ីចឹង គេទៅសុំអំបិលចុងភៅបានបន្តិចមក ចែកគ្នាម្នាក់ពីរបីគ្រាប់ទៅ។ យើងហូបបាយហ្នឹង បានទៅ បានពាក់កណ្តាលអ៊ីចឹងទៅ សម្លបានគេឆ្អិន បានគេលើកមក តែសម្លគឺនាងខ្ញុំហូបមិនកើត ព្រោះសម្លខ្ទះឆ្នោតហើយសម្លដើមចេក ហើយមានខ្លាញ់ជ្រូកអណ្តែតអីអ៊ីចឹង យើងហូបតែបន្តិចបន្តួច យើងហូបជាមួយអំបិលហ្នឹងទៅ បាន។ យើងសម្រាកបានបន្តិច គ្រាន់តែអង្គុយមួយបន្តិចដល់ម៉ោងយើងទៅធ្វើការ។ ទៅធ្វើការដល់ពេលល្ងាចម៉ោងប្រាំ ត្រូវត្រឡប់មកវិញ។ មកហូបបាយនៅរោង ហូបហើយ យើងត្រូវដើរទៅវិញ ទៅរែកដីវិញ តែមិនដឹងជាម៉ោងប៉ុន្មានទេ ពេលកំពុងតែរែកហ្នឹង គឺយើងងុយ។ ពេលនោះ នាងខ្ញុំអាយុ១៨, ១៩ហើយ គឺរែកមិនដឹងជាម៉ោងប៉ុន្មានទេ គឺស្នាៗគឺរបកៗគឺជាំ គឺខ្មៅ។ ហើយពេលរែកដីហ្នឹង គឺភ្នែកធ្មេច ដោយសារការងុយងោក។ បានដល់ម៉ោងគេឲ្យសម្រាកបានយើងដើរមករោងវិញ។ មកដល់រោង ត្រូវគេប្រជុំ ១កន្លះម៉ោងអីអ៊ីចឹងទៀត ពីរបីថ្ងៃប្រជុំម្តង។ តែពួកយើងងុយងោកខ្លាំង ពេលយើងប្រជុំហើយ យើងទៅសម្រាកអ៊ីចឹង យើងសម្រាកបានមិនដឹងជាបាន

ប៉ុន្មានម៉ោងទេ គេផ្ដុកញ្ញែឲ្យយើងងើបទៀត យើងទៅទៀត ធ្វើអ៊ីចឹងដដែលៗៗ។ ហើយអាការប្រើប្រាស់ទឹកអីហ្នឹង គឺមានប្រឡាយនៅរោងហ្នឹង គេមានប្រឡាយនៅក្បែរហ្នឹង ប្រឡាយហ្នឹងគឺយើងប្រើទឹកហ្នឹង ប្រឡាយហ្នឹង គឺមានគេលាងគោ លាងក្របីផង គេបោកខោអាវផង គេងូតហ្នឹង អីគេហ្នឹងទាំងអស់ តែយើងគ្មានជម្រើស យើងត្រូវរស់តាមហ្នឹង។

[០៩:៣២:១៤]

ហើយយើងទៅអនាម័យអី ចំពោះនារីគឺគ្មានៗ គឺយើងៗរស់ដោយខោអាវពីរបន្លាស់កញ្ចាស់ហ្នឹង។ ពេលយើងងូតទឹក ក៏យើងមិនសូវបានងូតទឹក ពេលយើងងូតទឹកគឺយើងងូតទាំងអស់។ ហើយពេលដែលយើង ពេលយើងកំពុងរែកដីក្ដៅអ៊ីចឹង គឺស្រេកទឹក យូរៗឃើញបានគេចាត់មនុស្សឲ្យទៅដងទឹកមកម្ដង គេដាក់ឃោង ហើយគេសែងទឹកមកម្ដង ទឹកហ្នឹងគឺល្អក់ តែយើងស្រេកយើងត្រូវតែហូប។ យើងស្រេកមែនទែន រហូតដល់ពេលយប់អី យើងគេង យល់សប្តិបានហូបទឹកកកអីអ៊ីចឹង ដូចថាយើងខ្វះទាំងអស់។ ហើយគេប្រជុំៗឲ្យយើងសម្រុក ពីរបីថ្ងៃគេប្រជុំម្ដង។ ហើយថាអ្នកណាដែលមិន -- "ការងារមិនសកម្ម កង់ប្រវត្តិសាស្ត្រវិលហើយ" គេប្រជុំប្រាប់យើងអ៊ីចឹង "តែអ្នកឯងលូកដៃដាច់ដៃ លូកជើងដាច់ជើង"។ ដូច្នេះទោះបីឈឺជា ក៏ត្រូវតែទៅ។ ហើយពេលញាតិមិត្ត -- មិត្តភក្តិរបស់នាងខ្ញុំបួនប្រាំនាក់ហ្នឹង គឺមានអ្នកងងឹតមាន់ទៀត ពេលធ្វើការយប់អីអ៊ីចឹង នាងខ្ញុំហ្នឹងអ្នកដឹក។ យើងពេលថ្ងៃដល់ពេលធ្វើយូរទៅយូរខែទៅ គេមានផែនការគេ១០ថ្ងៃឲ្យសម្រាកមួយថ្ងៃ។ ពេលហ្នឹងបានយើងឃើញថា ទិដ្ឋភាពទឹកដែលយើងប្រើ គឺដូចស្លែឡើងខៀវអ៊ីចឹង។ ពេលហ្នឹងពួកមិត្តរបស់នាងខ្ញុំហ្នឹងគេទៅបបួលគ្នាទៅគោះអង្គ្រងនៅក្នុងព្រៃហ្នឹង ហើយអ្នកខ្លះគេចាប់អីកូនកង្កែបកូនអីអ៊ីចឹង នាងខ្ញុំហ្នឹងទៅនឹងគេ ហើយគេយកអង្ក្រងហ្នឹងមកធ្វើទៅ យើងបានហូបហ្នឹង ព្រោះសម្លរបស់គេ យើងហូបមិនកើត។ បើក្នុងរយៈពេលប្រាំមួយប្រាំពីរខែហ្នឹង គឺនាងខ្ញុំទ្រាំៗៗទាំងវេទនា រហូតដល់ពេលជិតស្ទឹង ពេលបិទស្ទឹងជិត នៅសល់ប្រហែលជាង១០ម៉ែត្រហ្នឹង គឺគេធ្វើឫស្សីឲ្យយើងឆ្លងទៀត យើងដើរមិនប្រយ័ត្នធ្លាក់ ហើយមានមនុស្សធ្លាក់ គឺទឹកក្លួចឡើងខ្នាញ់។ អ្នកធ្លាក់ហ្នឹង គឺធ្លាក់ទៅគឺបាត់។ យើងពិបាកពេក យើងពិបាក យើងហេវ ពេលយើងទៅធ្វើការព្រលឹមឡើងយើងគ្មានស្អីទេ។ ពេលរាងថ្ងៃ រាងជិតត្រង់បន្តិចយើងហេវ យើងសុំគេទៅបត់ជើងក្នុងព្រៃអ៊ីចឹង យើងឆ្លៀតបេះស្លឹកថ្នឹងៗ ដើម្បីដាក់មាត់អីបួនប្រាំសន្លឹកអីអ៊ីចឹងទៅ ចេញមកវិញ។ គឺយើងធ្វើរបៀបហ្នឹងប្រាំមួយប្រាំពីរខែ ដែលយើងរស់នៅ ហើយយើងឃ្លាតពីម្ដាយ យើងរស់នៅដូចថា ដោយវេទនា។

[០៩:៣៥:៥៦]

មានគេធ្វើបាបមិត្តៗពួកខ្ញុំនឹងភ្នែក ដោយសារការឈឺ គ្នាឈឺ សូមឈប់គេមិនឲ្យឈប់។ គ្នាថា គ្នារាក គ្នាឈឺពោះ គេមិនឲ្យឈប់ទេ។ ប្រាប់ថា ខ្ញុំវាឈឺមែន តមាត់គេ គេវៃ នៅនឹងភ្នែកនាងខ្ញុំ។ ដល់អ៊ីចឹងនាងខ្ញុំមិនហ៊ាន ទោះបីឈឺជាក៏សុខចិត្តទ្រាំ។ វៃគ្នាហើយ ឲ្យគ្នារែកដី២ម៉ែត្រ អ្នកថ្មីដូចគ្នាហ្នឹង ជាកូនចៅចិន យកបង្គីឲ្យគ្នាមកធំណាស់ ឲ្យគ្នារែក។ តែពួកយើងមិនដែលហ៊ានមើល ដូចថាលួចតែអាណិតក្នុងចិត្ត។ ដូច្នេះទិដ្ឋភាពទាំងអស់នេះ ខ្ញុំខំប្រឹង ខ្ញុំមិនហ៊ានឈប់។ ទោះបីនារីៗ ត្រូវតែមានរដូវមានអីឈឺពោះ ក៏មិនដែលហ៊ានឈប់ ហើយក៏គ្មានស្ទីជាអនាម័យ។ យើងរស់ដូចសត្វដូចធាតុ ពេលយប់យើងហត់ហេវពេក មិត្តៗខ្ញុំហ្នឹង ប៉ុន្តែគេស្លាប់អស់ហើយឥឡូវ យើងរែកដីទៅយើងអាចដើរជិតគ្នាទៅយើងមានជិតគ្នាបន្តិច យើងចេះតែខ្សឹបគ្នាថា អានេះគេហៅអី យើងមិនដែលឃើញទេ ក្នុងប្រវត្តិសាស្ត្រយើងទុករឿងនេះ ប្រាប់ដល់ក្មេងជំនាន់ក្រោយ តែយើងវេទនាណាស់។

នឹកម្តាយ សូម្បីតែដំណឹងមិនដែលបានឮដំណឹង ម្តាយនឹកកូន ម្តាយមិនដឹងកូនទៅដល់ណា។ យើងរស់នៅរោងគេហ្នឹងកណ្តាលវាលស្រែ គ្មានផ្ទះគ្មានអីមួយ មិនដឹងគេហៅកន្លែងអីទៀត។ ពេលយប់ពេលសម្រាកយប់ យើងលើចំបើងហ្នឹងមានក្រណាត់អីកញ្ចេះកញ្ចាស់ យើងក្រាលទៅលើរោងហ្នឹង គេធ្វើវែង សង្កាត់ខ្ញុំហ្នឹង សង្កាត់ល្វាហ្នឹង គេធ្វើរោងវែងអ៊ីចឹងទៅ យើងសម្រាកទល់ជើងគ្នា ក្រាលចំបើង។ ដល់ពេលយប់នាងខ្ញុំត្រូវសម្រាកជួតក្បាលក្រមាហ្នឹង ឲ្យជិតត្រចៀក ដើម្បីកុំឲ្យខ្លាចសត្វអីចូលត្រចៀក យើងសម្រាកៗជួតក្បាលក្រមាឲ្យជិត។ យើងសម្រាកមិនដែលបាននេះទេ មិនដឹងជាបានប៉ុន្មានម៉ោងទេ យើងសម្រាក គេផ្លុំកញ្ចែឲ្យឡើងទៀត។ ធ្វើទាំងយប់ធ្វើទាំងថ្ងៃ យើងធ្វើរហូតដល់ខែធ្លាក់ភ្លៀង។ ពេលធ្លាក់ភ្លៀងហើយ ក៏គេមិនទាន់ឈប់ដែរ។ ថ្ងៃខ្លះក៏យើងអត់បានសម្រាកដែរ យប់ខ្លះ ដោយសារភ្លៀងៗដំបូលប្រក់ចំបើង ភ្លៀងវាលិច។ នៅប្រហែលជាខែ០៧ៗ ភ្លៀងខ្លាំងមែនទែន ធ្វើមិនកើត ព្រោះកន្លែងន៉ុង កន្លែងរោងជាវាលស្រែ បើគេមិនចប់ការដ្ឋាន គេមកៗនេះវិញ។ ពេលន៉ុងខ្ញុំឈឺ ពេលគេចប់ជិតចប់ហ្នឹង ខ្ញុំឈឺ ខ្ញុំក្តៅខ្លួន ខ្ញុំគ្រុន ខ្ញុំដើរមកកន្លែងមិនបានទេ សុំរទេះគេជិះ។ ខ្ញុំដើរមកកន្លែងភូមិល្វាហ្នឹងមិនបានទេ សុំរទេះគេជិះ។ មកដល់កន្លែង ខ្ញុំទៅជួបម្តាយខ្ញុំ សុំគេទៅផ្ទះ។ ម្តាយខ្ញុំស្គម ឃើញខ្ញុំស្គម គាត់យំ។ ពេលនោះខ្ញុំឈឺខ្លាំង គេមិនឲ្យខ្ញុំនៅភូមិ គេឲ្យមកកងចល័ត ដើម្បីឲ្យនៅសម្រាកពេទ្យ។ គេយកវិហារធ្វើពេទ្យ។ ពេលខ្ញុំឈឺខ្លាំង ខ្ញុំស្គម ហើយខ្ញុំឈឺក្នុងពោះ ខ្ញុំដាក់ទឹកតែបន្តិច ក៏ខ្ញុំចុកឈឺពោះ ហើយក្អួត ក្តៅ ហើយក្អួត។ ខ្ញុំគេឲ្យសម្រាកពេទ្យនៅកន្លែងហ្នឹងប្រហែល២អាទិត្យ អត់បាត់។ អត់បាត់ គេ

បញ្ជូនទៅពេទ្យស្រុកនៅស្ពឺ។ ទៅបានប្រហែលជាជាងពីរអាទិត្យ បានគ្រាន់បើ បាននាងខ្ញុំចេញ។ ម្ដាយនាងខ្ញុំទៅជាមួយ សុំគេទៅ បានចេញមកផ្ទះវិញ នាងខ្ញុំក៏សូមគេទៅនៅភូមិសិន ព្រោះនាងខ្ញុំមិនស្រួលខ្លួន។ ទៅនៅភូមិបានប្រហែលជាជិតមួយខែ គេដេញមកវិញ ដេញមកកងចល័តវិញ។ ដេញមកកងចល័តវិញ គេឲ្យយើង គេឲ្យធ្វើចម្ការ ធ្វើស្រែអីនៅៗភូមិហ្នឹង។ គេឲ្យធ្វើស្រែធ្វើចម្ការហ្នឹង ទៅកាត់ពោត កាត់អីអ៊ីចឹង។

[០៩:៤២:០៩]

ពេលប្រហែលជាពីរបីខែក្រោយមកនេះ ខ្ញុំសុំគេទៅលេងផ្ទះម្ដងទៀត។ ទៅមួយថ្ងៃអ៊ីចឹង ថ្ងៃនុំងខ្ញុំឃើញប្រធានក្រុមភូមិបី ខ្ញុំហ្នឹង ម្ដាយខ្ញុំរស់នៅហ្នឹង គេដើរកត់ គេមកៗកត់ប្រវត្តិរូប។ គេសួរៗម្ដាយខ្ញុំថា៖ "អ៊ំ ពេលជម្លៀសពីភ្នំពេញមក គ្រួសារអ៊ំមានទៅៗខាងប្ញូព៌ាអត់?" ហើយយើងមិនដឹង យើងឆ្លើយត្រង់ យើងឆ្លើយ យើងអត់ដឹងរឿងស្អីទាំងអស់ យើងឆ្លើយតាមហ្នឹង។ គេដឹកយើងទៅ ដឹកទៅនៅបានបួនប្រាំខែ ត្រពាំងផ្លុងហ្នឹង គេយកមកចំការលើវិញ យើងឆ្លើយអ៊ីចឹង។ ក្រោយមកប្រហែលជាក្នុងឆ្នាំ៧៨ ប្រហែលជាខែ០៦ ខែ០៧ នាងខ្ញុំគេឲ្យធ្វើចម្ការនៅក្បែរហ្នឹង វំលងពីវត្ត ទៅពីវត្តមួយគីឡូពីរហ្នឹង គេឲ្យកាត់ពោត។ ពេលនោះនាងខ្ញុំ គេឲ្យមកយកបាយនៅកន្លែងវត្តហ្នឹង យកចានដែកមកយកបាយ។ តែសម្រាប់តែមាន មុំ ពេលខ្ញុំឈរនៅកន្លែងចុងភៅគេ ស្រាប់តែ មុំ ដែលនៅភូមិជាមួយនាងខ្ញុំអ្នកថ្មីដូចគ្នាហ្នឹង នៅកងចល័តហ្នឹង គេរត់មក គេប្រាប់ថា "បង ព្រឹកមិញគេយកម៉ែឪយើងទៅសម្លាប់អស់ហើយ"។ ពេលនោះនាងខ្ញុំដូចថា ដូចៗបាត់ព្រលឹងអស់ គឺខ្ញុំចង់ជ្រុះចានដែកៗពីដៃហើយ។ ហើយៗខ្ញុំសួរ មុំ ថា "ចុះយើង មុំ យើងត្រូវទៅអត់?" ហើយ មុំ ថា "គេយកតាំងពីព្រឹកម្ល៉េះបងអើយ។ យើងៗដូចថា យើងមិនអាចទៅបានទេ វាហួសពេលហើយ"។ ពេលនោះខ្ញុំនៅទ្រាំយកបាយ គេដួសបាយឲ្យខ្ញុំយកទៅចម្ការ ខ្ញុំទៅចម្ការ ខ្ញុំឲ្យបងកាត់ពោតជាមួយហ្នឹង ឲ្យគាត់ហូបទៅ ហើយគាត់ហៅខ្ញុំហូប។ គាត់ថា "អ្ហែងហូបបាយ" ខ្ញុំថា "ខ្ញុំអត់ឃ្លានទេបងអើយ" ទៅខ្ញុំគេចរត់ចូលក្នុងព្រៃ ក្នុងពោតហ្នឹងសំងំយំតែឯងទៅ។ ដែលរបៀបហ្នឹង ប្រហែលជាបួនថ្ងៃ វាបួនថ្ងៃហ្នឹង ខ្ញុំមិនដែលបានហូបបាយអីមួយម៉ាត់ហើយក៏ទឹកអត់ គឺខ្ញុំសំងំកើតទុក្ខ។

[០៩:៤៤:៣៥]

ដល់គេប្រហែលជាបានជាបួនប្រាំថ្ងៃ គេមកយកពួកកូននៅកងចល័ត ដែលពួកអ្នកថ្មីភូមិខ្ញុំហ្នឹងមានបួនប្រាំនាក់។ ថ្ងៃហ្នឹងគេចាត់តាំង គេព្រលឹមឡើង ងងឹតឡើង ប្រធានកងគេចាត់តាំងថា ពួកភូមិបី

ឲ្យនៅប្រលេះសណ្ដែកដីក្រោមកុដិ ព្រោះខែហ្នឹង គេមានគេដកសណ្ដែកដី ហើយគេយកមកដាក់ក្រោមកុដិលោក។ ដល់គេត្រូវយកពួកភូមិណាទៅសម្លាប់ គេឲ្យនៅហ្នឹង។ ហើយខ្ញុំឮសួរអ៊ីចឹងៗ សួរប្រធានកងគេចាត់តាំងអ៊ីចឹង ខ្ញុំបាត់ព្រលឹងមួយសាទៀត ខ្ញុំថាដល់វេនអញហើយ។ នៅពេលហ្នឹង នាងខ្ញុំអត់ដូចថាបាត់ព្រលឹង ខ្ញុំនាងខ្ញុំចុះពីលើកុដិលោកហ្នឹងមកកន្លែងនៅហ្នឹង រួចស្បែកជើងក៏មិនបានយកដែរ បានតែក្រមាមួយ ហើយខោអាវកញ្ចាស់ហ្នឹង។ នាងខ្ញុំដើរមកផ្លូវកន្លែងកាច់ពោតនេះ ពេលដើរទៅហ្នឹង នាងខ្ញុំក្រឡេកឃើញប្រធានកង ប្រធានភូមិគេកាន់ដាវវែង។ នាងខ្ញុំឃើញអ៊ីចឹង ខ្ញុំឃើញគេមុន ខ្ញុំគេចពួនក្នុងព្រៃ ហើយគេដើរទៅផុត បានខ្ញុំដើរទៅទៀត។ ដើរទៅខ្ញុំនាងខ្ញុំដើរទៅកន្លែងកាច់ពោតហ្នឹង ហើយខ្ញុំប្រាប់បងហ្នឹង កាច់ពោតជាមួយហ្នឹងថា "ថ្ងៃហ្នឹងគេយកពួកខ្ញុំហើយបងអើយ"។ ដល់ពេលហ្នឹង គាត់ថាៗ "យើងគេចទៅណាក៏មិនរួចដែរអ្អែង!" អ៊ីចឹង។

ពេលនុ៎ងនាងខ្ញុំដើរទៅភូមិបងជីទូតមួយហ្នឹង នៅក្បែរភូមិ ក្បែរកន្លែងកាច់ពោតហ្នឹងដែរ។ ទៅដល់គាត់ រោងបាយគាត់នៅមុខផ្ទះ គាត់ជាអ្នក គេឲ្យដាំបាយ បាយរួមហ្នឹង។ ហើយគាត់សួរខ្ញុំថា "អ្អែងទៅណា?" ខ្ញុំថា "ខ្ញុំគេឲ្យកាច់ពោតនៅក្បែរនេះបង។ អាហ្នឹងខ្ញុំសូមមកលេង សុំច្បាប់គេមួយថ្ងៃមកលេង"។ គាត់ទៅ គាត់ដើរទៅដាំបាយបាត់ទៅ ខ្ញុំឡើងពួនលើផ្ទះគាត់។ ហើយផ្ទះគាត់ហ្នឹងមានជញ្ជាំងស្លឹកត្នោត ហើយរហែកៗ។ ពេលខ្ញុំឡើងពួនហ្នឹង ខ្ញុំផ្ទះគាត់មានផ្លូវដើរពីមុខហ្នឹង ខ្ញុំឃើញប្រធានយុវជន ឃើញយុវជនគេ គេនៅម្ខាងណោះ។ ឃើញប្រធានយុវជនហ្នឹង គេកាន់ដាវវែង ដើរកាត់។ ខ្ញុំថា គេដើររកខ្ញុំហើយ។ ពេលគេដើរទៅផុត នាងខ្ញុំចុះៗពីផ្ទះគាត់ហ្នឹង ទៅផ្ទះម្ដាយគាត់ ជាប់ហ្នឹង។ ខ្ញុំថាសុំថ្នាំ មានថ្នាំអីដែរ ខ្ញុំសុំប្អូនប្រាំគ្រាប់មក។ ហើយគាត់ក៏រកថ្នាំឲ្យខ្ញុំបានពីរបីគ្រាប់ហ្នឹង ថ្នាំពុកៗផុយៗតិចៗហ្នឹង។ ពេលនោះខ្ញុំចុះមក ខ្ញុំទៅក្រោយផ្ទះគាត់ហ្នឹងមានដាំដំឡូងមី មានអណ្ដូង មានក្រវាញជ្រូកត្រឹមៗចង្កេះ នាងខ្ញុំនៅក្រាបនៅហ្នឹង។ នៅក្រាបនៅហ្នឹង ហើយថ្ងៃហ្នឹង គេយកពួកភូមិហ្នឹង គេយក គេដឹករទេះហ្នឹង។ ខ្ញុំក្រាបទៅ ខ្ញុំមើលទៅឃើញ ព្រោះនៅផ្ទះគាត់នៅជាប់ផ្លូវកាច់ជ្រុង។ យំរញ៉ៀចរញ៉ោចមានក្មេង មានចាស់ដូចគ្រួសារខ្ញុំអ៊ីចឹង មានកូនតូចៗច្រើនអ៊ីចឹង។ ពេលនោះខ្ញុំៗពួននៅហ្នឹង ដល់ពេលថ្ងៃជិតលិច ខ្ញុំថា ខ្ញុំមិនដឹងទៅណាទៀត ព្រោះទៅណាក៏មិនរួច។ ពេលនោះ ជិតយប់ខ្ញុំដើរ ខ្ញុំថាខ្ញុំទៅកន្លែងកងចល័តវិញហើយ ព្រោះឲ្យស្លាប់ចុះ ព្រោះទៅណាក៏មិនរួច។ ពេលខ្ញុំដើរទៅកាត់ ដើរទៅភូមិបងកាច់ពោតជាមួយហ្នឹង គាត់នៅផ្ទះហ្នឹង គាត់នៅអង្គុយមាត់ជណ្ដើរហ្នឹង ឃើញខ្ញុំដើរទៅ គាត់ថា "ព្រឹកមិញអ្អែងទៅណា គេត្រួសព្រៃពោតរកអ្អែងដល់ហើយ", ខ្ញុំថា "ខ្ញុំពួនក្បែរហ្នឹង បងអើយ"។ "ថាឥឡូវ ចុះ

អ្អែងទៅណាទៀត?" ថា "ខ្ញុំទៅវិញ ទៅកន្លែងវិញហើយបងអើយ យើងមិនដឹងទៅណាៗក៏ស្លាប់ដែរ"។

[០៩:៤៨:៥៤]

ពេលខ្ញុំដើរទៅ ខ្ញុំចេះតែដើរបង្អង់ចូលផ្ទះញាតិមិត្តអីអ៊ីចឹង ចូលបង្អង់ឲ្យយប់ ខ្ញុំចូលទៅវត្តនោះវិញ។ ដល់ពេលជិតយប់មែនទែន ខ្ញុំដើរទៅៗជិតដល់វត្តហ្នឹងនៅសល់ប្រហែល២០ម៉ែត្រ អ្នកកងចល័តជាមួយនឹងខ្ញុំហ្នឹង គេនៅភូមិក្បែរហ្នឹង គេឈ្មោះ អាម៉េង គេសុំគេមកសម្រាកផ្ទះម្យប់។ ពេលឃើញខ្ញុំដើរទៅអ៊ីចឹង វាចេះ វាដើរមក វាថា "បងទៅណា?" ខ្ញុំថា "បងទៅកន្លែងវិញហើយ ព្រោះយើងគេចទៅណាក៏មិនរួចដែរសម័យនេះ"។ វាថា "បងកុំទៅអី ល្ងាចមិញគេយកពួកបងទៅអស់ហើយម៉ោងប្រាំ"។ ពេលនោះ ខ្ញុំបាត់ព្រលឹងម្តងទៀត ខ្ញុំមិនដឹងទៅណា ខ្ញុំបែរក្រោយមក ខ្ញុំក៏គេចបែរក្រោយមក ក៏ចូលផ្ទះធំដែលជាញាតិមិត្តរបស់ម្តាយខ្ញុំពីដើម។ គាត់ចាស់ៗហើយ គាត់នៅតែពីរនាក់ប្តីប្រពន្ធ និងកូនគាត់ទៅធ្វើការអស់។ ពេលនោះខ្ញុំ គាត់អង្គុយមាត់ជណ្តើរត្រឹម*(ឮមិនច្បាស់)* ហ្នឹង គាត់អង្គុយហើយ គាត់មានបង្វេចមួយ ហើយកាំបិតប្រគាក់មួយ។ ដល់ឃើញខ្ញុំដើរទៅ គាត់ថា "អ្អែងទៅណា?" ខ្ញុំថា "គេឲ្យខ្ញុំកាប់ពោតនៅក្បែរនេះធំអើយ។ ឥឡូវខ្ញុំសុំសម្រាកជាមួយធំមួយយប់។" ហើយគាត់ថា "អឺ ឡើងសម្រាកមួយធំអ្អែងទៅ អញគេឲ្យទៅយាមជង្រុកពោត។" ដល់ពេលឡើងទៅ នៅតែធំម្នាក់ឯងហ្នឹង គាត់រៀប គេយកបាយមកឲ្យគាត់ គាត់ចាស់។ ហើយគាត់ហៅខ្ញុំហូបបាយ គាត់ថា "អឺ ម៉ែអ្អែងសុខសប្បាយទេ? អញនឹកម៉ែអ្អែងណាស់ ខានមកលេងអញយូរហើយ។" ហើយគាត់ -- ខ្ញុំថា ខ្ញុំឆ្លើយតិចៗ ព្រោះវាយប់ហើយ តែយប់គេឈ្លបក្រោមផ្ទះស្តាប់យើង យកការណ៍យើងរហូត។ ខ្ញុំឆ្លើយតិចថាខ្ញុំថា "គាត់សុខសប្បាយទេធំអើយ។" ដល់ពេលគាត់ហៅហូបបាយ ហើយខ្ញុំអត់ហូប ខ្ញុំអត់ឃ្លានទេ។ តាមពិតខ្ញុំអត់បួនប្រាំថ្ងៃហើយ។ ពេលនោះខ្ញុំក៏ចូលសម្រាកក្នុងមុងគាត់ទៅ គឺថាពេលចូលសម្រាកទៅដូចសន្លប់អ៊ីចឹង ដាក់ទៅគឺឈឹង។ ពេលខ្ញុំដឹងខ្លួនឡើងឮមាន់រងាវ ខ្ញុំថា ខ្ញុំទៅណាទៀត? ពេលនោះខ្ញុំនឹកឃើញផ្ទះបងជីដូនមួយខ្ញុំនៅបន្ទាយជ័យ ឆ្ងាយ៦គីឡូ។ ខ្ញុំងើបៗចុះទៅដោយងងឹតឈឹង មិនដឹងជាម៉ោងប៉ុន្មាន ខ្ញុំរាវ ដើរហ្នឹងរាវ ខ្លាចប៉ះអី។ ដើរហ្នឹងមើលខ្លាចគេបាត់យើង គេឈ្លបរកយើង។ ខ្ញុំដើរកាត់ទៅកន្លែងកាត់ ផ្លូវកាច់ពោតហ្នឹង ដើរទៅចុះតាមក្បាលហុងហ្នឹង វាមានវាលស្រែ ខ្ញុំដើរកាត់តាមហ្នឹងងងឹតឈឹង គ្មានអីទេ។ ខ្ញុំដើរ ខ្ញុំឈានមួយជំហាន ខ្ញុំក្រឡេកមើលឆ្វេងស្តាំ ខ្ញុំខ្លាចឃើញមនុស្ស។ ខ្ញុំដើរតិចៗ ខ្ញុំដើរងាក។ ពេលដើរទៅដល់កន្លែងកាច់ពោតហ្នឹង ផ្លូវវាៗតូចមួយដានជើងហ្នឹង សុទ្ធតែបន្លាស្អិត។ ខ្ញុំដើរចូលបន្លា ទាក់ដាច់អាវដាច់ខោ មើលផ្លូវមិនឃើញ ខ្ញុំទ្រាំដើររហូត។ រហូតដល់ចុះទៅ

ស្រែកាត់ទៅភូមិហ្នឹង ភូមិបន្ទាយជ័យហ្នឹង។ ពេលដើរទៅ អត់មានជួបមនុស្សអីម្នាក់។

[០៩:៥២:១៨]

ពេលដើរទៅដល់ល្អះៗ ខ្ញុំឡើងលើផ្ទះគាត់ទៅ គាត់ ប្តីគាត់ទៅដេកពេទ្យនៅស្រុក នៅក្មួយតូចៗ ប្អូនប្រាំនាក់ហ្នឹង។ ពេលនុំងខ្ញុំក៏ប្រើវាទៅបោចត្រកួនកញ្ឆែត ហើយវាតូចៗ វាទៅបោចមកមួយកង ហើយ ខ្ញុំដាំទឹកផឹក ថាឲ្យស្លាប់។ ពេលខ្ញុំដាំទឹកហ្នឹងទៅ ស្រាប់តែប្រធានភូមិគេដើរមក។ ប្រធានភូមិ ហើយនិងឈ្លបគេមក គេហៅឈ្មោះបងថ្លៃខ្ញុំហ្នឹង បងថ្លៃជីដូនមួយហ្នឹង។ ហៅបណ្តើរ គេឈានឡើងបណ្តើរ ហើយខ្ញុំមិនដឹងឆ្លើយថាម៉េច ខ្ញុំថា គាត់អត់នៅអ៊ីចឹង។ ខ្ញុំលើកផឹកទឹកហ្នឹង ហើយនិងអាថ្នាំរើក្នុងផ្ទះបង ទូបងហ្នឹង សល់ចាស់ៗប្អូនប្រាំគ្រាប់ហ្នឹង ផឹកទៅ។ ពេលនោះគេឃើញខ្ញុំ គេសួរ “មិត្តឯងមកពីណាអ៊ីចឹង?” ខ្ញុំថា ខ្ញុំភរគេ ពេលនោះខ្ញុំភ័យពេក ខ្ញុំភរគេថា ខ្ញុំមកពីដេកពេទ្យស្រុកអី។ ខ្ញុំភរគេដោយសារការភ័យពេក ដោយគេហៅខ្ញុំទៅមន្ទីរ។ មន្ទីរគេហ្នឹងជាប់ផ្ទះបងប្អូនខ្ញុំហ្នឹង។ ទៅដល់គេឃាមកាម គេសួរខ្ញុំថា អីខ្ញុំប្រាប់តាមអ៊ីចឹងទៅ។ ដល់ពេលនេះ គេថាគេចាំជួបសង្កាត់ ថ្ងៃបន្តិចសង្កាត់គេមកហើយ ចាំជួប។ ដល់ថ្ងៃបន្តិច សង្កាត់គេមក។ សង្កាត់គេមក គេសួរខ្ញុំថា “មិត្តឯងមកពីណា?” ហើយខ្ញុំប្រាប់តាមដំណើរទំនងអ៊ីចឹងទៅ។ ថា “មិត្តឯងមកពីបូព៌ាទេអី?” ខ្ញុំថា “ខ្ញុំមិនស្គាល់បូព៌ាអីឯណាទេ។ ខ្ញុំមិនមែនមកពីបូព៌ាទេ ខ្ញុំមិនស្គាល់បូព៌ាអីទេ។” ហើយគេសួរនៅភូមិណា ខ្ញុំថានៅភូមិបីអ៊ីចឹង។ គេថាចាំឲ្យគេមកយកវិញ គេថាអ៊ីចឹង ហើយគេចុះទៅបាត់ទៅ។ ដល់ពេលខ្ញុំនៅសម្រាកហ្នឹង គេឲ្យសម្រាកហ្នឹង ខ្ញុំសម្រាកទៅ គឺខ្ញុំធ្វើទុក្ខថ្នាំ វាពុល វាចង់ក្អួត ខ្ញុំធ្វើទុក្ខ។ គេទៅបាត់ទៅ ខ្ញុំប្រះខ្លួនទៅ ដេកលក់ទៅ។ មានឈ្លបគេឃាមខ្ញុំ គេយកបាយមកឲ្យអ៊ីចឹង ហៅខ្ញុំហូបបាយ។ ខ្ញុំថា ខ្ញុំអត់ឃ្លាន។ ហើយគេថា “មិត្តឯងកុំភ័យ ឲ្យតែស្មោះត្រង់អង្គការ កុំភ័យអី”។ ពេលនោះគេនិយាយអាម៉េច ក៏ខ្ញុំមិនជឿដែរ។ ដល់ពេលយប់បន្តិច មានសង្កាត់ហ្នឹង គេមកម្តងទៀត។ គេមក គេហៅខ្ញុំឲ្យងើបអង្គុយ ព្រោះខ្ញុំអត់ស្រួលក្នុងខ្លួន ខ្ញុំរកក្អួត ខ្ញុំពុលថ្នាំ។ ដល់អង្គុយ គេសួរថា “មិត្តឯងៗ ដែលពីមុនធ្លាប់នៅហ្នឹង” អីអ៊ីចឹងៗ ខ្ញុំថា “ចាស វាជាស្រុកកំណើតខ្ញុំ ប៉ុន្តែខ្ញុំឃប់នៅតាំងពីខ្ញុំតូច គេមិនសូវស្គាល់” អីអ៊ីចឹង។ ពេលនោះក៏គេថា “មិត្តឯង កុំភ័យណា ថ្ងៃមិញខ្ញុំអត់ស្គាល់មិត្តឯង មិត្តឯងកុំខឹងណា” ខ្ញុំថា “ខ្ញុំគ្មានខឹងអីទេ”។ តាមពិតគេនិយាយយ៉ាងម៉េច ក៏ខ្ញុំអត់មានជឿដែរ។ គេហៅខ្ញុំ ដល់ពេលគេសួរអីអ៊ីចឹងទៅ ថា “អ៊ីចឹងមិត្តឯងកុំសម្រាកនៅហ្នឹង ទៅសម្រាកផ្ទះអ៊ំមុខនោះ មិត្តឯងទៅសម្រាកនុំងទៅ”។ ដល់ពេលខ្ញុំទៅសម្រាកនុំងទៅ ដែលអ៊ំហ្នឹងៗ ជាៗម្តាយធំរបស់សង្កាត់ហ្នឹង ហើយក៏ជាញាតិមិត្តរបស់ម្តាយខ្ញុំអីពីដើមដែរ។ ដល់

ពេលទៅគាត់ ដូចថាគាត់ឃើញអ៊ីចឹង គាត់ទឹកភ្នែកគាត់អីអ៊ីចឹង។ ខ្ញុំថាខ្ញុំ គាត់យកបាយមកឲ្យ ខ្ញុំថា "ខ្ញុំអត់ឃ្លានទេអ៊ំអើយ ខ្ញុំចង់ក្អួតណាស់"។ ហើយទៅគាត់កោសខ្យល់គាត់អីទៅ គាត់ៗដណ្តប់ភួយឲ្យ គាត់ដេកឱបទៅ គាត់ៗឃុំអីអ៊ីចឹងទៅណា។ ដល់ពេលហ្នឹងនាងខ្ញុំត្រូវគេឲ្យរស់នៅនៅហ្នឹង។ រស់នៅកន្លែងហ្នឹងបានបួនប្រាំខែ។ តែពេលនោះអ្នកជួយយើងថ្ងៃមួយនោះ អ្នកជួយៗនាងខ្ញុំនៅសង្កាត់ហ្នឹង គេរកចាប់នាងខ្ញុំ។ នាងខ្ញុំត្រូវលោតពីលើផ្ទះហ្នឹង លោតពីលើផ្ទះហ្នឹងហើយ នាងខ្ញុំតាំងពីថ្ងៃនោះមក នាងខ្ញុំទៅនៅផ្ទះបងជីដូនមួយខ្ញុំទល់មុខហ្នឹងវិញ។ ដោយសារការ -- តែនាងខ្ញុំរស់នៅកន្លែងហ្នឹងបានប្រហែលជាបីបួនខែ ក៏៧៩ហ្នឹងទៅ ក៏បានរស់។ ដល់ពេលដាច់៧៩ហ្នឹងទៅ អ្នកស្រុកភូមិហ្នឹងគេប្រាប់ខ្ញុំថា "អ្ហែង កុំតែគេបិទសារាចរលែងសម្លាប់មនុស្សទេ កុំអីហ្នឹងក៏មិនរស់ដែរ"។ គេអ្នកស្រុក គេអ្នកប្រជាជនចាស់ហ្នឹង គេចេះប្រាប់អ៊ីចឹង។ ដល់ខ្ញុំបានរស់អ៊ីចឹងទៅ។

[០៩:៥៧:០៨]

ការរស់របស់ខ្ញុំៗដាច់ហើយហ្នឹង ក៏ជីវិតខ្ញុំតែលតោល ខ្ញុំគ្មានគោលដៅ គឺមានការលំបាកខ្លាំង។ យើងគ្មានចេះ ដើរទៅនេះបន្តិច ទៅនោះបន្តិច គ្មានបងប្អូនបង្កើត ហើយមាននៅតែម្នាក់ឯង គ្មានបងប្អូនបង្កើត យើងត្រូវរស់តែលតោលគ្មានគោលដៅ។ ដល់ពេលឆ្នាំ៨២ បានបងប្អូនញាតិសន្តានដែលនៅក្នុងភូមិហ្នឹង គេមកធ្វើការនៅភ្នំពេញហ្នឹង ក៏បានមកនៅជាមួយគាត់ទៅ បានគាត់ជួយឲ្យធ្វើការនៅឯក្រសួង អេស.ប៉េ.កា ហ្នឹងទៅ។ ដូចថាវា ជីវិតវាជួរចត់ពេក រកអីមកប្រៀបផ្ទៀបមិនបាន។ ក្រោយមកនៅឆ្នាំ១៩៨៦ បានគ្រួសារខ្ញុំ ប្តីរបស់ខ្ញុំហ្នឹងគ្នាធ្វើការនៅកសិកម្ម ក៏បានចូលស្តី បងប្អូនក៏រៀបឲ្យទៅ។ រហូតមកដល់ពេលបច្ចុប្បន្នឥឡូវ ខ្ញុំបានកូនពីរ ប្រុសមួយ ស្រីមួយ។

**សៈ** សូមអរគុណលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ពេលវេលាកាន់តែខិតទៅហើយ ខ្ញុំចង់សួរលោកស្រីថា តើលោកស្រីមានអារម្មណ៍បែបណានៅពេលដែលលោកស្រីនឹកឃើញឡើងវិញដល់រយៈកាលនៅសម័យខ្មែរក្រហមនោះ?

**ឆៈ** មានការឈឺចាប់ណាស់។ ខ្ញុំចង់សួរលោកថា នៅតាមរយៈលោកប្រធាន តាមរយៈមេធាវី ខ្ញុំចង់សួរលោកចុងចោទថា ការជម្លៀសប្រជាជន ចេញពីទីក្រុងយកទៅប្រើឲ្យធ្វើការហួសកម្លាំងមិនឲ្យហូបឆ្អែត តើលោកធ្វើដើម្បីអ្វី? លោកថា លោកស្រឡាញ់ប្រជាជន ហើយប្រជាជនគ្នាស្រុកកើតសង្គ្រាម គ្នាត្រូវរត់រកកន្លែងជម្រក។ ពេលជម្លៀសទៅវិញ លោកថាជាខ្មាំង គ្នាអត់ដឹងអីទេ។ ខ្ញុំចង់សួរលោក ក្មួយខ្ញុំតូចៗ គ្នាមិនដឹងអ្វីទេ ប្រាំពីរប្រាំបីនាក់។ លោក មួយទៀតលោកសម្លាប់មនុស្សម្តងហើយ

ម្តងទៀតៗ រង្គាល គំនិតលោក ខ្ញុំចង់សួរលោក តើលោកសម្លាប់ខ្មែរឲ្យអស់ ចង់យកជាតិសាសន៍ណាមកដាក់ស្រុកខ្មែរ ឬយ៉ាងណា? នេះជាសំណួររបស់ខ្ញុំ។

នៅតំបន់ខ្មែរក្រហម កប៉ាល់ហោះទម្លាក់ នៅស្រុកភូមិខ្ញុំ ទៅមើលចុះរណ្តៅនៅទល់ឥឡូវ ជាស្រះ។ មានការភ័យខ្លាចរត់មកកំពង់ចាម រត់ទៅភ្នំពេញ កំពង់ចាមផ្តោងពេក។ លោកជម្លៀសមកវិញ លោកថា ពួកយើងខ្លាំង។ អាហ្នឹងមិនខុសអីពីពាក្យថា "ចុះទឹកក្រពើឡើងលើខ្លា" នោះទេ។ គ្នាមិនដឹងថាអីខ្សែ សេ.អ៊ី.អា អីយ៉ាងម៉េចទេ។ ពេលនោះលោក អស់លោកនៅឯណា ខ្មែរវេទនា លោកនៅឯណា? លោកបញ្ជាឲ្យពួកមូលដ្ឋានធ្វើបាបពួកយើង សង្កេតការណ៍គ្រប់កន្លែងគ្រប់ មើល ក្រសែភ្នែកមើលមកពួកយើងជាមនុស្សថោកទាប។ ចំពោះរូបខ្ញុំ--

[១០:០៣:១៨]

**ប្រធានអង្គជំនុំ៖**

អស់សំណួរនៅលោកស្រី នួន ណារុំ?

**លោកស្រី នួន ណារុំ៖**

សំណួរអស់ហើយ តែពីរហ្នឹងទេលោក។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមជម្រាបលោកស្រីថា នៅក្នុងសវនាការកាលពីថ្ងៃ០៨ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានស្តាប់ជនជាប់ចោទទាំងពីររូប ឆ្លើយបញ្ជាក់ពីការដែលពួកគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ អង្គជំនុំជម្រះបានកត់សម្គាល់ថា ជនជាប់ចោទទាំងពីររូបនៅតែរក្សាជំហររបស់ខ្លួនបន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកឡើងតែ និងរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានព័ត៌មានជាក់ច្បាស់ផ្សេងពីជនជាប់ចោទ ឬពីសហមេធាវីការពារក្តីរបស់ជនជាប់ចោទ។ ហើយនៅក្នុងសវនាការថ្ងៃនោះ អង្គជំនុំជម្រះបានកំណត់ឲ្យជនជាប់ចោទ និង/ឬមេធាវីការពារក្តីការពារជនជាប់ចោទ ត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការជូនដំណឹងមកដល់អង្គជំនុំជម្រះឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបនឹងសំណួរដោយអង្គជំនុំជម្រះ ឬក៏ភាគីនៅក្នុងកិច្ចដំណើរការណាមួយនៃកិច្ចដំណើរការសវនាការ។

[១០:០៤:២២]

ហើយអង្គជំនុំជម្រះរហូតដល់ពេលនេះ អង្គជំនុំជម្រះនៅមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្តូរជំហររបស់ជនជាប់ចោទទាំងពីររូប ពីការលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប មកជាយល់ព្រមឆ្លើយតបនឹងសំណួរនៅឡើយទេ។ ហេតុដូច្នេះ យើងចង់បញ្ជាក់ថា យើងមិនអាចបង្គាប់ ឬក៏បង្ខំឲ្យជនជាប់ចោទឆ្លើយតបទៅនឹងសំណួរដែលលោកសួរអម្បាញ់មិញនេះទេ ដោយសារគាត់បានរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយគាត់មិនទាន់មានជំហរក្នុងការកែប្រែ ក្នុងការរក្សាសិទ្ធិរបស់គាត់នៅឡើយទេ។ នេះសូមលោកស្រីជ្រាប។

មានអីបន្តទៀតទេ លោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី?

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

គឺចំពោះដើមបណ្តឹងរដ្ឋប្បវេណី គឺអត់មានអ្វីទៀតទេ លោកប្រធាន អស់ហើយ។ យើងសូមផ្តល់វេទិកានេះ ជូនភាគីផ្សេងទៀត លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយប៉ុន្តែឥឡូវនេះ ដល់ពេលសមស្របសម្រាកដែរហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងដល់សក្ខី -- មកដល់កន្លែងថ្លែងរៀបរាប់អំពីទុក្ខសោកវេទនាដែលរៀបចំដោយរដ្ឋបាលតុលាការ នៅចំពោះមុខអង្គជំនុំជម្រះនេះ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:០៦ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:២០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយបន្តទៅនេះផ្ដល់វេទិកាជូនទៅភាគីដទៃទៀត ដែលដំបូងនេះ ផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញា តើមានសំណួរអ្វីចង់សួរបញ្ជាក់ទៅដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះដែរឬទេ? បើមានសូមអញ្ជើញបាទ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់យើងមានសំណួរមួយចំនួន ដើម្បីសួរទៅកាន់លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំឈ្មោះ វាំងសង់ វ៉ាយដ៍ ខ្ញុំនឹងសំណួរលោកស្រីតាងនាមឲ្យការិយាល័យសហព្រះរាជ-អាជ្ញា។ ជាដំបូងខ្ញុំចង់អរគុណលោកស្រី ដែលលោកស្រីមករៀបរាប់អំពីប្រវត្តិរឿងរ៉ាវរបស់លោកស្រីវាជាការសំខាន់សម្រាប់យើង។ ប្រសិនបើលោកស្រីមិនដឹងចម្លើយទេ សូមលោកស្រីប្រាប់ថាលោកស្រីមិនដឹងទេ ឬក៏លោកស្រីប្រាប់ខ្ញុំមកថា លោកស្រីនឹកមិនឃើញទេ សូមលោកស្រីប្រាប់ត្រង់ៗតែម្ដង។ ខ្ញុំនឹងនិយាយអំពីទំនប់១មករា។ លោកស្រីបានឆ្លើយថា លោកស្រីធ្វើការនៅទីនោះ អស់រយៈពេលជាច្រើនខែ។ ដូច្នេះ តើលោកស្រីអាចជម្រាបបានទេ ថាអ្នកធ្វើការនៅទំនប់១មករានោះ ជាមនុស្សប្រភេទណាខ្លះ? មានប្រជាជនថ្មី ប្រជាជនចាស់ ធ្វើការចម្រុះគ្នា ឬក៏យ៉ាងម៉េច?

[១០:៣៣:៣២]

**លោកស្រី នួន ណារុំ៖**

**ឆ៖** ចាស អរគុណ។ ដែលនៅទីនោះប្រជាជនចាស់ ប្រជាជនថ្មីចម្រុះគ្នា។

**ស៖** ចុះមេធំៗដូចជា មេក្រុម មេកង មេកងធំ មេវរសេនាតូចនោះ មានប្រជាជនថ្មី គេកាន់តំណែងជាមេៗទាំងអស់ទាំងអស់ហ្នឹងទេ?

**ឆ៖** ចាស អរគុណ។ មិនមានទេ។

**ស៖** តើលោកស្រីអាចពន្យល់បានទេ ថាការងារប្រចាំថ្ងៃហ្នឹង លោកស្រីធ្វើអ្វីខ្លះនៅទំនប់១មករានោះ? លោកស្រីត្រូវជីកដី រែកដី សង់ទំនប់ហ្នឹង ឬក៏ធ្វើអ្វីផ្សេងទៀត?

**ឆ៖** ចាស អរគុណ។ ចំពោះនាងខ្ញុំៗគ្រាន់តែជារែកដីទេ រែកដីតែមួយមុខទេ មិនមានកាប់ដីទេ ព្រោះពួកបុរសៗគេអ្នកកាប់ដី។

**ស៖** គេមានកំណត់ផែនការឲ្យលោកស្រីរែកដីហ្នឹងទេ ឧទាហរណ៍ដូចជាថា មួយថ្ងៃត្រូវរែកប៉ុន្មានម៉ែត្រគូបអី គេមានកំណត់ទេ?

**ឆ៖** ចាស អរគុណ។ កាលពីយើងទៅលើកដំបូង គេកំណត់ឲ្យស្រីៗ ១,៥ម៉ែត្រ បុរស ២ម៉ែត្រ។ តែក្រោយមក គឺយើងចេះតែទៅដូរកន្លែង ទៅនេះនោះអីចឹងទៅ មានអត់ចែកគ្នាៗដែរ ព្រោះបុរសអ្នកកាប់ទៅ នារីអ្នករែកទៅ។

[១០:៣៦:០៥]

**ស៖** តើលោកស្រីត្រូវតែធ្វើការឲ្យសម្រេចតាមផែនការហ្នឹងឲ្យបានជាដាច់ខាត ឬក៏យ៉ាងម៉េច គឺថាមួយថ្ងៃដាច់ខាតត្រូវតែរែកឲ្យបាន១,៥ម៉ែត្រគូបហ្នឹង មែនទេ?

**ឆ៖** ចាស មួយថ្ងៃត្រូវតែឲ្យអស់ ឲ្យរួចផែនការ ព្រោះយើងមិនដែលធ្វើអត់រួចទេ ព្រោះកាលណាដូចថា អ្នកមានកម្លាំងមិនខ្លាំងអី ដល់ពេលជិតចុងម៉ោងអីអីចឹង មានពួកមិត្តយើងជួយ ជួយបង្ហើយការងារហ្នឹង។

**ស៖** តើលោកស្រីអាចរៀបរាប់អំពីការលំបាកប្រចាំថ្ងៃ ដោយសារការរែកដីហ្នឹងទេ? គឺថាលោកស្រីអាចឈឺស្មា ដោយសារតែអំរែករែកហ្នឹង លោកស្រីអាចរៀបរាប់លម្អិតបន្តិចបានទេថា មានការលំបាក ឬក៏ការឈឺអ្វីកន្លែងណាផ្សេងទៀតទេ ដោយសារតែការងាររែកដីជាប្រចាំថ្ងៃនុ៎ង?

**ឆ៖** ចាស អរគុណ។ វាពិបាក យើងមិនអាចថ្លែងបាន ដោយសារយើងមិនដែលបានធ្វើអីចឹងរែកដី។ ដល់ពេលយើងទៅសម្រុកការងារទាំងយប់ទាំងថ្ងៃអីចឹង ធ្វើឲ្យស្មាយើងឈឺជាំខ្មៅ ហើយរបកៗហើយពេលយើងរែកហ្នឹង គឺយើងដូរស្មាខាងឆ្វេងម្តងទៅ ព្រោះស្មាស្តាំវារបក វាជាំអីចឹងទៅ ប៉ុន្តែរឿងស្មាឆ្វេងហ្នឹងវាមិនសូវៗចេះ។ ដាក់បានតែម្តងៗ ដល់ស្មាស្តាំយើងត្រូវ ឈឺយ៉ាងណាក៏យើងទ្រាំ គឺមានការឈឺ ឈឺខ្លាំង។ ហើយនៅក្នុងការងារប្រចាំថ្ងៃហ្នឹង គឺយើងសម្រុកទាំងយប់ទាំងថ្ងៃ គឺមានការហត់ៗនឿយអស់កម្លាំងតែយើងប្រឹងៗ ចិត្តយើងៗខំប្រឹងដើម្បីឲ្យបានរស់។

[១០:៣៨:៤៩]

**ស៖** សូមអរគុណ។ លោកស្រីអាចជម្រាបបានទេថា ចម្ងាយដែលលោកស្រីរែកដីពីកន្លែងកាប់ទៅកន្លែងចាក់ដីហ្នឹង គឺប៉ុន្មានម៉ែត្រដែរ? ហើយទម្ងន់បង្គីទាំងពីរហ្នឹង បើយើងគិតទៅដីក្នុងបង្គីទាំងពីរហ្នឹងទម្ងន់ប្រហែលប៉ុន្មានគីឡូក្រាមដែរ?

**ផ៖** ចាស អរគុណ។ ក្នុងកន្លែងចម្ងាយដែលយើងរែកទៅចាក់ហ្នឹងវាមិនទៀង មានកន្លែងឆ្ងាយ មានកន្លែងជិត។ ចម្ងាយប្រហែលជា៣០ម៉ែត្រអីអ៊ីចឹងទៅ ៥០ម៉ែត្រ ជួនកាល២០ យើងតាមកន្លែងឆ្ងាយ កន្លែងជិត។

**ស៖** ចុះទម្ងន់ដីដែលលោកស្រីរែកនៅក្នុងបង្គីទាំងពីរហ្នឹង បើសរុបទៅប្រហែលជាប៉ុន្មានគីឡូក្រាមដែរ លោកស្រី?

**ផ៖** ចាស អរគុណ។ ដូចពេលហ្នឹង យើងដូចពិបាកស្មាន។ បើយើងអាចថាស្មានៗប្រហែលជាម្ខាង២០គីឡូអីអ៊ីចឹង ព្រោះយើងរែកឡើងនេះដែរ រាងដូចទន់ដងរែងដែរ។

**ស៖** ក្រោយពីធ្វើការបានប៉ុន្មានសប្តាហ៍ ឬក៏ប៉ុន្មានខែក្រោយមកហ្នឹង តើស្ថានភាពរូបរាងកាយរបស់ពលករទាំងអស់ហ្នឹងយ៉ាងម៉េចដែរ? ហើយចុះលោកស្រីផ្ទាល់ហ្នឹង រាងកាយយ៉ាងម៉េចដែរ មានចុះស្គមអីទេ?

**ផ៖** ចាស អរគុណ។ ក្រោយប៉ុន្មានខែក្រោយមក រាងកាយក៏ចាប់ផ្តើមចុះស្គម កម្លាំងចាប់ផ្តើមខ្សោយ មិនថាតែរូបនាងខ្ញុំទេ ដូចថាអ្នកធ្វើការជាមួយហ្នឹងក៏ដូចគ្នាដែរ។ បើដោយឡែកអ្នកប្រធានក្រុម ប្រធានកងដែលថានេះហ្នឹង ដូចថាមើលទៅរាងកាយគេ សុខភាពគេដូចនៅដដែល ព្រោះគេមិនមានការរែកដីដូចពួកយើង។

[១០:៤១:៣៣]

**ស៖** អម្បាញ់មិញនេះ លោកស្រីបាននិយាយថា លោកស្រីជួយធ្វើការពេលយប់សម្រាប់អ្នកដែលខ្វាក់មាន់។ តើលោកស្រីអាចជម្រាបបានទេថា ហេតុអ្វីបានជាអ្នកធ្វើការនៅទីនោះកើតជំងឺខ្វាក់មាន់? ហើយហេតុអីបានជាមានមនុស្សច្រើនកើតបែបនេះ?

**ផ៖** ចាសអរគុណ។ នាងខ្ញុំមិនដឹងមូលហេតុដែរ មិនដឹងមូលហេតុពិតប្រាកដដែរ។ ពេលដែលនាងខ្ញុំដឹកហ្នឹង អ្នកមិត្តជិតខាងហ្នឹងមានដឹកពីរនាក់ ព្រោះយើងទៅសុទ្ធតែពេលយប់ ពេលយប់ទៅហ្នឹងអាមកក៏យប់ តែនាងខ្ញុំឃើញមានច្រើន ព្រោះនៅគ្រប់សង្កាត់ យើងដើរទៅយើងឃើញមានអ៊ីចឹងច្រើនកន្លែង មិនដឹងជាមូលហេតុអី ព្រោះនាងខ្ញុំអត់ដឹង។

**ស៖** នៅពេលដែលពួកគាត់មើលយប់មិនសូវឃើញអ៊ីចឹង ខ្វាក់មាន់អ៊ីចឹង តើវាគ្រោះថ្នាក់ទេ ដែលគេប្រើឲ្យគាត់ធ្វើការនៅពេលយប់បែបនេះនោះ?

**ឆ៖** នៅពេលយប់គេមានបង្គោលភ្លើងបំភ្លឺ មានភ្លើងនៅលើទំនប់ហ្នឹង គឺមានបង្គោលភ្លើងបំភ្លឺ គេអាចធ្វើបាន។ ប៉ុន្តែពេលគ្នាដើរទៅ គឺមើលផ្លូវអត់ឃើញ ត្រូវដឹកគ្នាតោងៗដងរែកនាងខ្ញុំពីក្រោយអ៊ីចឹង។

**ស៖** នៅការដ្ឋានធ្វើការហ្នឹងមានអ្នកយាម ឬក៏ឈ្លបគេតាមដានឃ្លាំមើលទេ?

**ឆ៖** ចាស អរគុណ។ ឃើញមានដែរ ប៉ុន្តែមិនច្រើនទេ ព្រោះប្រធានកងប្រធានអីយើង គឺនៅជាមួយយើងរហូតដែរ។ គេសង្កេតការណ៍ អ្នកណាដូចថាសកម្ម អត់សកម្មអីអ៊ីចឹង មាន។

[១០:៤៥:១៥]

**ស៖** តើមេកងរបស់លោកស្រីមាននិយាយពាក្យថា "ខ្មាំងប្រឆាំងនឹងបដិវត្តន៍" ទេ? ហើយប្រសិនបើមាននិយាយនោះ តើអ្នកណាដែលគេចាត់ទុកថាជាខ្មាំងប្រឆាំងនឹងបដិវត្តន៍នោះ?

**ឆ៖** ចាស អរគុណ។ រាល់ពេលមកពីធ្វើការពេលយប់វិញ គេត្រូវប្រជុំក្នុងពីរបីថ្ងៃម្តង គេប្រជុំ។ គេប្រជុំថា បើអ្នកណាខ្ជិលច្រអូស នេះជាខ្មាំងៗប្រឆាំងនឹងបដិវត្តន៍ អ្នកត្រូវវិលកង់ប្រវត្តិសាស្ត្រវិលហើយ អ្នកត្រូវវិលឲ្យទាន់ តែមិនទាន់ចាត់ទុកថាជាខ្មាំងប្រឆាំងនឹងបដិវត្តន៍។

**ស៖** អម្បាញ់មិញនេះ លោកស្រីបាននិយាយផងដែរថា អ្នកដែលខ្ជិលច្រអូសហ្នឹងត្រូវគេវាយដំ អ្នកណាជាអ្នកវាយដំអ្នកខ្ជិលច្រអូសហ្នឹង? ហើយគេប្រើអ្វី ឧបករណ៍អ្វីទៅវាយដំអ្នកខ្ជិលច្រអូលនុ៎ង?

**ឆ៖** ចាស អរគុណ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ តាមខ្ញុំស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីអម្បាញ់មិញនេះ ដូចជាមិនមានពាក្យថា "វាយដំ" ទេ គ្រាន់បញ្ជាក់ថា អ្នកខ្ជិលហ្នឹង គឺត្រូវចាត់ទុកថាជាខ្មាំងប្រឆាំងបដិវត្តន៍ ហើយតែថាត្រូវឲ្យវិលឲ្យទាន់នឹងកង់ប្រវត្តិសាស្ត្រ។ បាទ សូមអរគុណ។

[១០:៤៦:២២]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំកត់ត្រាទុក ឮគាត់ឆ្លើយថា អ្នកខ្លះហ្នឹងឈឺ ហើយអ្នកខ្លះខ្ជិលច្រអូលនោះ ត្រូវគេវាយដំ កាលពីព្រឹកមិញនេះ។ អ៊ីចឹងហើយបានជាខ្ញុំសួរបំភ្លឺគាត់ អ៊ីចឹងខ្ញុំចង់ដឹងថា តើមានអ្នកដែលត្រូវគេ វាយដំ ដោយសារតែធ្វើការមិនគ្រាប់គ្រាន់ ឬក៏ខ្ជិលច្រអូសទេ? ហើយអ្នកដែលវាយដំហ្នឹង ជាអ្នកណា? ហើយគេប្រើឧបករណ៍អ្វីទៅវាយដំនោះ?

**លោកស្រី នួន ណារុំ៖**

**ឆ៖** ចាស នាងខ្ញុំនិយាយព្រឹកមិញហ្នឹង មិនមែនជាអ្នកខ្ជិលច្រអូសទេ អ្នកជាអ្នកឈឺ អ្នកសុំ ច្បាប់ឈប់។ គ្នាឈឺ ថ្ងៃនុំងគ្នាថាឈឺពោះ រាក គ្នាសុំឈប់មួយថ្ងៃ តែប្រធានកងគេថា ប៉ុណ្ណឹងទៅធ្វើការ បាន អត់ឲ្យឈប់ទេ។ ហើយគ្នាតមាត់ថា "ហើយបើខ្ញុំឈឺមែន មិនឲ្យខ្ញុំឈប់" ពេលនោះគេស្រែក ហើយគេវាយ គេយកដងរែកវាយនៅមុខនាងខ្ញុំ។ គេដេញទាល់តែទៅ។ ខ្ញុំចាំនាង មិត្តនុំងឈ្មោះ អេង ជាអ្នកថ្មីដែរ ជាកូនចៅចិន។ ដល់ទៅដល់កន្លែងធ្វើការ គេឲ្យវាស់ដីឲ្យគាត់២ម៉ែត្រ ហើយយកបង្គី អាធំៗ យកមកបោះឲ្យគាត់ពីរ ឲ្យគាត់រែក។ គេថា បើមិនហើយ មិនឲ្យទៅហូបបាយទេ។

**ស៖** អ្នកណាជាអ្នកវាយឈ្មោះ អេង ហ្នឹង? ជាឈ្លប ជាប្រធានកង ឬក៏ជាអ្នកណា?

**ឆ៖** ចាស អរគុណ។ ជាប្រធានក្រុមដែលទៅមើលពួកយើងនៅតាមកងចល័តហ្នឹង ជាស្រី។

**ស៖** សូមអរគុណ។ តើអ្នកធ្វើការផ្ដាច់សន្លប់ ឬក៏ដួលដោយសារតែអស់កម្លាំងពេកទេ? គឺខ្ញុំ សំដៅលើអ្នកធ្វើការក្នុងកងលោកស្រីនោះ មានអ្នកអ៊ីចឹងទេ?

[១០:៤៨:៥៥]

**ឆ៖** ចាស អរគុណ។ នៅក្នុងកងនាងខ្ញុំមានៗ អ្នក មានៗអ្នកសន្លប់។ ពេលនោះគេសែង គេ មានអង្រឹងសែងមកៗរោងវិញ។

**ស៖** មានអ្នកស្លាប់ទេ នៅក្នុងកងចល័តលោកស្រីនៅពេលដែលលោកស្រីធ្វើការនៅទីនោះនុំង?

**ឆ៖** ចាស អរគុណ។ នៅពេលយើងកំពុងធ្វើការរយៈពេលប្រាំមួយប្រាំពីរខែហ្នឹង មិនមានទេ ប៉ុន្តែពេលចប់ការដ្ឋានហើយ មិត្តៗដែលគេដឹងហ្នឹង គេខ្សឹបប្រាប់ខ្ញុំថា សង្កាត់យើងមានបាត់មនុស្សបី បួននាក់។ បាត់ តែខ្ញុំមានស្គាល់តែម្នាក់ហ្នឹងទេ ឈ្មោះ ដានិច អ្នកថ្មី ឈ្មោះ ដានិច។ នាងហ្នឹងស្អាត ណាស់។ នាងហ្នឹង តាមឮតាមមិត្តភក្តិ ថាជាកូនមេធាវី ស្អាតៗដូចបវរកញ្ញាអ៊ីចឹង។ នាងខ្ញុំស្គាល់តែ ម្នាក់ហ្នឹង គេថាបាត់ពីរបីនាក់ ប៉ុន្តែនាងខ្ញុំអត់ស្គាល់ ស្គាល់តែម្នាក់ហ្នឹង។ ពេលចប់ការងារគឺបាត់ខ្លួន។

**ស៖** ខ្ញុំនៅមានសំណួរពីរបីទៀត។ នៅក្នុងកងរបស់លោកស្រី ឬក្នុងកងផ្សេងទៀតហ្នឹង មានស្ត្រីជនជាតិចាមធ្វើការជាមួយទេ?

**ឆ៖** ចាស អរគុណ។ ដូចជាគ្មានចាមទេ នៅកងចល័តហ្នឹងដូចជាគ្មានចាមទេ។ បើនៅភូមិ ភូមិបី ដែលគ្រួសារនាងខ្ញុំរស់នៅម្ដាយឪពុកហ្នឹងមានចាម ប៉ុន្តែមកកងចល័តហ្នឹង អត់មានចាមទេ ដោយសារតែគ្មាន ដូចថានៅលីវអីអ៊ីចឹង។

**ស៖** នៅការដ្ឋានទំនប់១មករា តើលោកស្រីមានសិទ្ធិសេរីភាពទេ ឬក៏លោកស្រីត្រូវតែស្តាប់បង្គាប់តាមអ្វីដែលគេកំណត់ជាដាច់ខាត អត់មានសិទ្ធិសេរីភាពអីទេ?

[១០:៥១:៥៧]

**ឆ៖** ចាស អរគុណ។ គឺកន្លែងការដ្ឋាន១មករា គឺគ្មានសិទ្ធិអ្វីទាំងអស់។ ថ្ងៃមួយនោះ ខ្ញុំឈឺ ខ្ញុំក្តៅខ្លួន ខ្ញុំសុំឈប់ មិត្តម្នាក់ហ្នឹង ក៏គាត់ឈឺ គាត់សុំឈប់ដែរ អ្នកថ្មីដូចគ្នា។ មិត្តហ្នឹងគាត់រែកដីទៅ គឺគាត់ឃើញជួបបងជីដូនមួយប្រុសរបស់គាត់ ឃើញគ្នានៅក្នុងការដ្ឋានរែកដីហ្នឹង។ ហើយយើងបែកគ្នាយូរ ក៏សួរនាំមួយម៉ាត់ពីរនៅកន្លែងណា ថានៅរោងសង្កាត់កំពង់ថ្ម ហើយរោងហ្នឹងនៅចម្ងាយប្រហែល១៥ម៉ែត្រពីរោងដែលនាងខ្ញុំរស់នៅហ្នឹង។ ពេលដែលសម្រាកមួយថ្ងៃដែលឈឺសុំគេឈប់ហ្នឹង មិត្តខ្ញុំក៏ហៅនាងខ្ញុំ បបួលនាងខ្ញុំទៅថា "ទៅរោងបងជីដូនមួយនាងខ្ញុំពីរនាក់មួយភ្លែតទៅ រោងនៅកន្លែងនេះ ជិតគ្នា។ ខ្ញុំជួបនៅកាលកន្លែងរែកដី តែគាត់ប្រាប់ថា រោងគាត់នៅហ្នឹង"។ ពេលទៅក៏ទៅជាមួយគ្នា។ ដល់ពេលមកវិញ ប្រធានកងគេសួរថា "មិត្តឯងមកពីណា?" ហើយ មិត្តវន ហ្នឹងគាត់ឆ្លើយថា "ខ្ញុំជួបបងជីដូនមួយខ្ញុំ ហើយខ្ញុំចង់ គាត់ថារោងគាត់នៅត្រង់ហ្នឹង ខ្ញុំចង់ដើរទៅជួបគាត់មួយភ្លែត"។ តែគេស្តីឲ្យៗគេវ៉ៃ ហើយគេយកកន្សែងដែលគាត់ទទួរហ្នឹងពណ៌ក្រហម ទទួរដូចក្រមាហ្នឹងពណ៌ក្រហមចងគាត់ ចងដៃទៅក្រោយអ៊ីចឹង ហើយនាងខ្ញុំភ័យណាស់។ នាងខ្ញុំអត់មាត់អីទាំងអស់ ព្រោះនាងខ្ញុំទៅដោយសារគេអ៊ីចឹង គេអត់ចងខ្ញុំទេណា។ គេចងមិត្តខ្ញុំហ្នឹង នៅនឹងមុខនាងខ្ញុំហ្នឹង តែនាងខ្ញុំអត់មាត់អីមួយម៉ាត់ទេ។ គេសួរៗតែមិត្តខ្ញុំហ្នឹង គេឆ្លើយទៅ។ គេថា "មិត្តឯងគ្មានសិទ្ធិដើរទៅណាក្រៅពីក្នុងរោងទេ!"។ គេស្តីគេជេរ ហើយគេចង។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាងឈេ៖**

សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។

លោកប្រធាន ខាងសហព្រះរាជអាជ្ញាអស់សំណួរហើយលោកប្រធាន។

[១០:៥៤:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះខាងមេធាវីការពារក្ដីមានសំណួរអ្វីចង់សួរបញ្ជាក់ពាក់ព័ន្ធនឹងស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មដែលលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីបានថ្លែងរៀបរាប់អម្បាញ់មិញដែរឬទេ? បើមានសូមអញ្ជើញ! ដំបូងនេះ សូមផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក នួន ជា។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកស្រីដើមបណ្ដឹង។ ខ្ញុំមានសំណួរពីរបីដែរដើម្បីសាកសួរលោកស្រីនៅព្រឹកនេះ។ តើលោកស្រីអាចប្រាប់បានទេ ថាតើនៅក្នុងកងរបស់ៗលោកស្រីហ្នឹងមាននារីប៉ុន្មាននាក់ដែរ?

**លោកស្រី នួន ណារុំ៖**

**ឆ៖** ចាស អរគុណ។ នាងខ្ញុំមិនបានចាំដែរ ព្រោះនៅក្នុងទំនប់១មករាហ្នឹង យើងត្រូវទៅមួយសង្កាត់។ មួយសង្កាត់ តែខ្ញុំ នាងខ្ញុំស្គាល់តែ ដូចថាពួកនៅភូមិជាមួយគ្នាទេ តែភូមិៗគេៗ យើងគ្រាន់តែឃើញមុខគ្នាអ៊ីចឹង ខ្ញុំអត់អាចរាប់បានថាជាប៉ុន្មានទេ ព្រោះរោងៗដែលយើងនៅហ្នឹងវាវែង វាប្រហែលជា២០ម៉ែត្រ ហើយយើងសម្រាកទល់ជើងគ្នា ផ្លូវដើរកណ្ដាលបន្តិច។ ព្រោះមួយសង្កាត់នាងខ្ញុំមិនអាចស្មានបានទេ មិនដឹងជាប៉ុន្មានដែរ។

[១០:៥៦:០៧]

**ស៖** ប៉ុន្តែតើលោកស្រីខ្លួនឯងហ្នឹងនៅក្នុងកងនារី តើមែនទេ?

**ឆ៖** ចាស ពិតមែន។

**ស៖** តើលោកស្រីអាចប្រាប់បានទេ អាចប៉ាន់ប្រមាណបានទេ ថាតើក្នុងកងលោកស្រីហ្នឹងមាននារីប៉ុន្មាននាក់?

**ឆ៖** ចាស ពេលដែលខ្ញុំស្មាន ព្រោះយើងធ្វើដំណើរពីកងចល័តទៅ យើងដើរទេ យើងដើរកាត់ព្រៃ ទៅកន្លែងការដ្ឋានហ្នឹង យើងដើរទេ យើងដើរកាត់ព្រៃអ៊ីចឹង មានប្រធានកងគេពីរនាក់អីអ៊ីចឹងនាំផ្លូវ

បើថាអាចស្មានទៅប្រហែលជា ជាង២០នាក់អី។

**ស៖** តើស្ត្រីទាំង២០នាក់នៅក្នុងកងរបស់លោកស្រីហ្នឹង គឺពួកគាត់ហ្នឹងមកពីភូមិជាមួយគ្នាមែនទេ?

**ឆ៖** ចាស មិនមែនទេ។ ជាង២០នាក់ហ្នឹងមកមួយសង្កាត់ ព្រោះនៅកងចល័តហ្នឹង វាមានគ្រប់ភូមិ មួយសង្កាត់ល្វាហ្នឹង វាមានច្រើនភូមិ វាមិនមែនជាមួយភូមិទេ។ មួយភូមិនាងខ្ញុំតែប្រាំប្រាំមួយនាក់ទេ។

**ស៖** ប្រសិនបើខ្ញុំយល់មិនខុសទេ គឺមានន័យថា មានស្ត្រីម្នាក់ គឺជាអ្នកដឹកនាំកងស្ត្រី ឬក៏អាចនិយាយថា មានស្ត្រីម្នាក់ជាអ្នកបញ្ជាទៅលើកងស្ត្រីហ្នឹង។ តើអ៊ីចឹងមែនទេ?

**ឆ៖** នៅសង្កាត់របស់ខ្ញុំហ្នឹងមានពីរនាក់។ មានប្រធានគេពីរនាក់ ស្រីៗទាំងពីរអ៊ីចឹង។

[១០:៥៨:៥៤]

**ស៖** តើមេកងស្ត្រីទាំងពីរនាក់ហ្នឹងមានឈ្មោះអីដែរ លោកស្រី?

**ឆ៖** មានឈ្មោះ មិត្តវ៉ាត មួយហើយនិង មិត្តលី មួយ។

**ស៖** តើ មិត្តវ៉ាត ហើយនិង មិត្តលី ហ្នឹងជាអ្នកទទួលខុសត្រូវលើស្បៀងអាហារ ទៅលើកន្លែងស្នាក់នៅ ឬមួយក៏មានម្នាក់ទទួលខុសត្រូវការងារម្ហូបអាហារ ម្នាក់ខាងកម្មករអី? តើពួកគាត់ធ្វើការយ៉ាងម៉េចដែរ?

**ឆ៖** ចាស អរគុណ។ មិត្តពីរនាក់ហ្នឹងមិនមែនជាទទួលខុសត្រូវខាងម្ហូបអាហារទេ គ្រាន់តែជាមើលការខុសត្រូវនៅក្នុងការដ្ឋានពួកនារីៗប៉ុន្មាននាក់ហ្នឹងទេ ខាងម្ហូបអាហារ គឺជាខាងផ្សេងរបស់ចុងភៅ។

**ស៖** ប៉ុន្តែនៅពេលព្រឹក នៅពេលដែលលោកស្រី ហើយនិងអ្នកធ្វើការជាមួយលោកស្រីហ្នឹងងើបពីគេងហ្នឹង តើអ្នកណាជាអ្នកប្រាប់ ថាតើអ្នកណាជាអ្នកបញ្ជាថា លោកស្រីទៅទីណា ត្រូវទៅធ្វើអីហ្នឹង? ខ្ញុំចង់ដឹងអ្នកណាជាអ្នកបញ្ជាហ្នឹង?

**ឆ៖** ចាស អរគុណ។ យើងដឹងហើយ កន្លែងដែលយើងធ្វើការហ្នឹង គឺការដ្ឋានគឺបិទស្ទឹង។ ដូច្នេះពេលអ្នកដែលដាស់ហៅពួកកងចល័តនាងខ្ញុំ គឺប្រធានកងគេហ្នឹង មិត្តវ៉ាត ហ្នឹងគឺគាត់អ្នកផ្លុំកញ្ចែ។ ផ្លុំកញ្ចែហើយ គឺមានទះដៃទៀត ពេលយប់ឲ្យយើងងើបហ្នឹង។

**ស៖** តើ មិត្តអេង ដែលលោកស្រីនិយាយពីមុនហ្នឹង តើមែនទេ?

**ឆ៖** មិនមែនទេ។ មិត្តអេង គឺជាអ្នក គឺជាប្រជាជនថ្មី។ ប្រធានកងគេហ្នឹងដែលឈ្មោះ មិត្តវ៉ាត ហ្នឹង ដែលជាអ្នកបញ្ជាឲ្យពួកយើងរើបថ្មើរណា ដែលជាអ្នកធ្វើទារុណកម្មអ្នកដែលឈឺអីហ្នឹង គឺមិត្តហ្នឹង មិត្តវ៉ាត ហ្នឹង។

[១១:០២:០០]

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកស្រីអ៊ីចេះវិញ។ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលលោកស្រីធ្លាក់ខ្លួនឈឺ នៅពេលលោកស្រីធ្វើការនៅទំនប់ហ្នឹង លោកស្រីត្រូវទៅពេទ្យ។ ដូច្នេះ ខ្ញុំចង់ដឹងថា តើលោកស្រីសុំការអនុញ្ញាតពីអ្នកណា? ឧទាហរណ៍ថាសុំអនុញ្ញាតពីពេទ្យ សុំអនុញ្ញាតទៅពេទ្យ ឬក៏សុំអនុញ្ញាតសម្រាក ដោយសារឈឺហ្នឹង។ ដូច្នេះ ខ្ញុំចង់ដឹងថា តើអ្នកណាជាមនុស្សដែលលោកស្រីទៅត្រូវការសុំការអនុញ្ញាត?

**ឆ៖** ចាស អរគុណ។ ពេលដែលយើងឈឺហ្នឹង គឺយើងសុំប្រធានកងយើង ដែលគ្រប់គ្រងយើងហ្នឹង។ ប្រធានកងហ្នឹង ក៏បញ្ជូនយើងមកពេទ្យ មកសម្រាកពេទ្យទៅ ព្រោះពេទ្យនៅក្នុងវត្តហ្នឹង ហើយគេយកវិហារធ្វើជាពេទ្យ។

**ស៖** តើអ្នកណាជាមេកងដែលអាចសម្រេចអនុញ្ញាតឲ្យលោកស្រីទៅពេទ្យ គឺពេទ្យនៅក្នុងវត្តហ្នឹង តើអ្នកណា?

**ឆ៖** នៅកងចល័តហ្នឹង វាមានក្នុងមួយក្រុម ភូមិខ្ញុំអ៊ីចឹងមានមិត្ត មានប្រធានក្រុមគេម្នាក់ ស្រី។ កាលណាយើងឈឺ គឺយើងសុំម្នាក់ហ្នឹង សុំប្រធានក្រុមហ្នឹង ហើយគេ ក៏គេបញ្ជូនយើងឲ្យមកសម្រាកពេទ្យទៅ។

[១១:០៣:៥០]

**ស៖** ប៉ុន្តែខ្ញុំចង់សួរថា តើមិត្តហ្នឹងឈ្មោះអី គឺមិត្តដែលអនុញ្ញាតឲ្យលោកស្រីទៅពេទ្យ តើមិត្តហ្នឹងឈ្មោះអីដែរ?

**ឆ៖** ប្រធានក្រុមនៅកងចល័តខ្ញុំហ្នឹង ឈ្មោះ មិត្តយឿន ជាស្រី មិត្តយឿន – ឈ្មោះ យឿន។

**ស៖** តើលោកស្រីអាចពន្យល់បានទេ នៅពេលដែលលោកស្រីឈឺ ឧទាហរណ៍ឈឺនៅមួយពេលណាមួយ បន្ទាប់មកលោកស្រីសុំ មិត្តយឿន សុំឈប់សម្រាក។ ប្រសិនបើ មិត្តយឿន អនុញ្ញាតឲ្យលោកស្រីឈប់សម្រាក តើមានអ្វីកើតឡើងបន្តទៀត?

**ឆ៖** ចាស ពេលខ្ញុំធ្លាក់ខ្លួនឈឺ គឺពេលអាការបញ្ចប់ការដ្ឋាន១មករា មុននឹងប៉ុន្មានថ្ងៃ គឺខ្ញុំធ្លាក់

ខ្លួនឈឺ ក្តៅខ្លួន គ្រុន។ ពេលមកកន្លែងវិញអ៊ីចឹង មិនអាចដើរបាន គេឲ្យ -- សុំរទេះគេជិះ។ មកដល់កងចល័តហ្នឹង នាងខ្ញុំទៅភូមិសិន ព្រោះនាងខ្ញុំសុំគេទៅម្តាយ ទៅជួបម្តាយសិន។ នាងខ្ញុំឈឺ ឈឺខ្លាំងនាងខ្ញុំត្រូវមកកងចល័តវិញ គេឲ្យមកកងចល័តវិញ ហើយប្រធានក្រុមហ្នឹង គេនាំឲ្យសម្រាកពេទ្យ នៅក្នុងកងចល័តហ្នឹង។

**ស៖** នៅពេលដែលលោកស្រីសុំអនុញ្ញាតពី យឿន ទៅស្នាក់នៅពេទ្យ។ តើ មិត្តយឿន ហ្នឹងអនុញ្ញាតភ្លាមៗ ឬក៏អត់ទេ?

**ឆ៖** ចាស ពេលយើងជាក់ស្តែង យើងឈឺជាក់ស្តែង ក្តៅខ្លាំងអីអ៊ីចឹង គេសុំទៅ មិត្តយឿន ហ្នឹងគេឲ្យទៅពេទ្យភ្លាម។ ប៉ុន្តែប្រធានក្រុមហ្នឹង គេត្រូវរាយការណ៍ទៅប្រធានកងចល័ត ឯលើៗទៀតអ៊ីចឹងទៅ ដូចថាតាមរយៈប្រធានក្រុមអ៊ីចឹងទៅ។

[១១:០៦:១៨]

**ស៖** ប៉ុន្តែក្នុងករណីអ្នកស្រី នៅពេលដែលអ្នកស្រីឈឺ តើ មិត្តយឿន ហ្នឹងអនុញ្ញាតឲ្យអ្នកស្រីជិះរទេះគោទៅពេទ្យទេ?

**ឆ៖** ពេលនាងខ្ញុំត្រឡប់មកពី១មករាវិញ ឈឺហ្នឹង ពេទ្យហ្នឹងគឺនៅក្នុងកន្លែងវត្តហ្នឹងទេ នៅកន្លែងកងចល័តហ្នឹងទេ។ តែនាងខ្ញុំសម្រាកពេទ្យហ្នឹងអស់ប្រហែលជា១០ថ្ងៃ នាងខ្ញុំអត់ជា អត់ជាពេទ្យហ្នឹង គេបញ្ជូនទៅពេទ្យស្រុក នៅឯស្ពឺណោះ គេមានរទេះគោ គេឲ្យរទេះគោដឹកយើងទៅ។

**ស៖** អ្នកស្រីនិយាយថា អ្នកស្រីឈឺ បន្ទាប់មកអ្នកស្រីសុំគេ ហើយគេក៏បញ្ជូនទៅពេទ្យក្នុងការដ្ឋាន។ បន្ទាប់មកទៀត បញ្ជូនទៅពេទ្យស្រុក។ ដូច្នេះខ្ញុំចង់សួរថា ចុះអ្នកដទៃ ដែលអ្នកដទៃហ្នឹងគាត់ឈឺ ហើយគាត់សុំគេដែរ ប៉ុន្តែគេបដិសេធមិនឲ្យទៅ តើមានអ្វីកើតឡើងអ្វីដែរ ចំពោះអ្នកដែលឈឺហើយ សុំគេទៅ គេអត់ឲ្យទៅនោះ?

**ឆ៖** ចាស លោកស្តាប់ខ្ញុំច្រឡំហើយ។ ដែលពេលខ្ញុំឈឺហ្នឹង នាងខ្ញុំមកដល់ភូមិវិញហើយ មកដល់កងចល័តវិញហើយ មិនមែននៅការដ្ឋានទេ។ ពេលដែលចប់ការដ្ឋានហើយហ្នឹង ប្រាំប្រាំមួយខែហ្នឹង មិនមែនឈឺនៅកន្លែងការដ្ឋានហ្នឹងទេ ពេលចប់ហើយទេ បាននាងខ្ញុំឈឺនោះ។ ពេលមកកងចល័តវិញ ពេលកងចល័តហ្នឹង យើងនៅក្នុងវត្ត កងចល័តហ្នឹងគេមានឲ្យនៅតាមកុដិលោកហ្នឹង ហើយវិហារនៅជិតហ្នឹង គេដាក់ពេទ្យ។ ពេលយើងឈឺអ៊ីចឹង ប្រធានក្រុមហ្នឹង យកយើងទៅសម្រាកពេទ្យ មិនមែននៅការដ្ឋានទេ។ ហើយអ្នកដទៃឈឺ ឈឺជាក់ស្តែងអ៊ីចឹង គេ ប្រធានក្រុមគេបញ្ជូនទៅពេទ្យដូចគ្នា។

[១១:០៨:៣៣]

**ស៖** ប្រហែលជាខ្ញុំស្ដាប់អត់ច្បាស់ ប៉ុន្តែខ្ញុំគិតថា មុនពេលឈប់សម្រាក អ្នកស្រីនិយាយអំពីមនុស្សម្នាក់ដែលឈឺ ហើយគាត់សុំទៅពេទ្យ ប៉ុន្តែគេបដិសេធសំណើហ្នឹង ហើយគេវ៉ៃអ្នកនោះទៀត។ ដូច្នេះ ខ្ញុំចង់សួរអ្នកស្រីអំពីរឿងរ៉ាវនេះទេ។

**ឆ៖** នៅពេលក្នុងការដ្ឋានហ្នឹង ខ្ញុំដូចអត់បាននិយាយអ្នកឈឺទេ។ ខ្ញុំបាននិយាយ -- អ្នកឈឺៗហ្នឹង អ្នកដែលថាឈឺពោះរាកហ្នឹងទេ មិត្តអេង ហ្នឹងទេ ខ្ញុំនិយាយមិត្តហ្នឹង ដែលឈឺហើយ សុំច្បាប់ គេមិនឲ្យឈប់ហ្នឹង ខ្ញុំនិយាយមិត្តហ្នឹង។ គេមិនឲ្យឈប់ សូម្បីគ្នាសុំសម្រាកមួយថ្ងៃ គេមិនឲ្យឈប់ហ្នឹង គេ គ្រាន់តែនិយាយតមាត់ ថាបើខ្ញុំឈឺមែន មិនឲ្យខ្ញុំឈប់។ តមាត់គេ គឺគេវ៉ៃ គេយកដងរែកវ៉ៃ ហើយគេឲ្យវាស់ដីឲ្យលើសផែនការគេ ឲ្យបង្គីធំៗ។ ហ្នឹងខ្ញុំនិយាយចំពោះអ្នកឈឺនោះ ដែលនៅក្នុងការដ្ឋាននោះទេ ដែលសុំគេ គេមិនឲ្យឈប់នោះ។

**ស៖** ខ្ញុំយល់ច្បាស់ហើយអ្នកស្រី។ តើអ្នកស្រីធ្លាប់ត្រូវគេវ៉ៃទេ នៅពេលដែលអ្នកស្រីធ្វើការនៅការដ្ឋានទំនប់នោះ?

[១១:១០:០៥]

**ឆ៖** ចាស អរគុណ។ ខ្ញុំអត់ដែលបានគេវ៉ៃទេ ព្រោះខ្ញុំខ្លាច ទោះបីខ្ញុំឈឺតិចតួច ខ្ញុំមិនប៊ានសុំច្បាប់គេទេ ខ្ញុំសុខចិត្តទៅ។ ខ្ញុំមិនប៊ានទេ តែប្រាំប្រាំមួយខែហ្នឹង ដែលខ្ញុំឈឺក្ដៅខ្លួនជាក់ស្ដែងហ្នឹង ឈប់បានប្រហែលជាពីរបីដងអីដែរ។ តែអាការថាអស់កម្លាំងអីអ៊ីចឹង មិនប៊ានដែលសុំគេឈប់ទេ មិនស្រួលខ្លួនតិចតួចអី នាងខ្ញុំទៅ។ តែដល់ពេលថ្ងៃណាក្ដៅខ្លួនអ៊ីចឹង គេស្ទាបទៅដឹងថាក្ដៅខ្លួនមែន គេឲ្យយើងឈប់មួយថ្ងៃអ៊ីចឹងទៅ។ តែខ្ញុំខ្លាចគេ ខ្ញុំត្រូវធ្វើការឲ្យគ្រប់ មិនដែលមានគេវ៉ៃខ្ញុំទេ។ ដែលតែគេកសាងដូចថាឲ្យយើងប្រឹងអីតទៅទៀតអីអ៊ីចឹង។

**ស៖** អ្នកស្រីដឹងទេ ហេតុអ្វីបានជាអ្នកស្រីមិនដែលត្រូវគេវ៉ៃ ចំណែក អេង គេវ៉ៃទៅវិញ? អ្នកស្រីដឹងទេថា ដោយសារហេតុអ្វី ឬក៏មានភាពខុសគ្នាយ៉ាងម៉េចដែរ?

**ឆ៖** នាងខ្ញុំមិនដឹងជាភាពខុសគ្នាយ៉ាងម៉េចដែរ ព្រោះគេជារូបគេផ្សេង នាងខ្ញុំផ្សេង ខ្ញុំដូចមិនដឹងយ៉ាងម៉េចដែរ ព្រោះមានពេលខ្ញុំ ជួនកាលដូចថាមិនស្រួលខ្លួនអីខ្លាំងពេកអីអ៊ីចឹងអស់ពេកទៅ សុំគេមានសុំគេឈប់ដែរ គេថាមិនឲ្យឈប់ “ទៅ ប៉ុណ្ណឹងមិនអីទេទៅ”។ នាងខ្ញុំទៅ អត់តមាត់អីទេ ដូច្នេះនាងខ្ញុំខ្លាចគេធ្វើបាប នាងខ្ញុំត្រូវទៅ។ មានៗអ៊ីចឹងមាន។

**ស៖** ប្រសិនបើខ្ញុំយល់មិនខុសទេ អ៊ីចឹងមានតែ អេង ម្នាក់ទេដែលត្រូវគេរើនៅក្នុងសង្កាត់របស់អ្នកស្រី តើអ៊ីចឹងមែនទេ ឬមួយក៏មានអ្នកផ្សេងទៀតត្រូវគេរើដែរនៅក្នុងសង្កាត់របស់អ្នកស្រីនោះ?

[១១:១២:៣៣]

**ឆ៖** ពេលនុំងមនុស្សដូចថា មួយរោងវែងដែរ នាងខ្ញុំមិនអាចចាំបាន មិនអាចចាំបានទេ ចាំតែអ្នកដែលនៅៗជិតៗខ្លួនយើង ព្រោះយើងមិនអាច គេមិនឲ្យយើងដើរទៅពិភាក្សាអី មើលគ្នាអី និយាយរឿងអីទេ។ មិនដែលបានទាំងឃើញមុខគ្នា រស់នៅរោងជាមួយគ្នា សូម្បីតែរោងចុង រោងដើម យើងមិនឃើញមុខគ្នាផង យើងឃើញតែគ្នាប៉ុន្មាននាក់ជិតយើងបួនប្រាំនាក់ហ្នឹងទេ។ ដូច្នេះ នាងខ្ញុំមិនអាចដឹងអស់។

**ស៖** ឥឡូវនេះ ខ្ញុំនិយាយអំពីពេលដែលអ្នកស្រីត្រូវបានគេបញ្ជូនទៅពេទ្យ គឺពេទ្យស្រុកនោះ។ នៅពេលដែលអ្នកស្រីត្រូវបានគេព្យាបាលជានៅពេទ្យស្រុកហើយ គេមិនបញ្ជូនអ្នកស្រីទៅទំនប់វិញទេ ប៉ុន្តែគេឲ្យអ្នកស្រីធ្វើការស្រាលៗនៅតាមស្រែ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ពេលនាងខ្ញុំត្រឡប់ពីពេទ្យស្រុកមកវិញ នាងខ្ញុំនៅមិនទាន់មានកម្លាំងនៅស្គម នៅដូចថាល្វិតល្វៃ ក៏នាងខ្ញុំសុំប្រធានកងគេទៅនៅភូមិជាមួយម្ដាយ។ ទៅនៅជាមួយម្ដាយប្រហែលជាពីរបីអាទិត្យដែរ ព្រោះម្ដាយនាងខ្ញុំ គាត់មកសុំគេអីអ៊ីចឹង ថាដើម្បីរកឫសឈើអីឲ្យនាងខ្ញុំដាំទឹកញ៉ាំ ព្រោះយើងពេលហ្នឹង យើងឈឺក្រពះហើយ ព្រោះឈឺក្នុងពោះ មិនទាន់មកកងចល័តភ្លាមទេ។ ដល់បានប្រហែលជា២០ថ្ងៃ បានប្រធានក្រុមភូមិហ្នឹង គេថាឲ្យយើងត្រូវមកកងចល័តវិញហើយ។ ដូច្នេះនាងខ្ញុំមកកងចល័តវិញហើយ បានទៅធ្វើការអីនៅចម្ការរំលងមួយគីឡូពីរគីឡូពីកន្លែងកងចល័តហ្នឹង ធ្វើចម្ការដាំពោតដាំអីអ៊ីចឹង។

**ស៖** នៅពេលដែលអ្នកស្រីនិយាយពីចម្ការ តើអ្នកស្រីចង់និយាយពីការធ្វើការស្រាលៗនៅស្រែនៅចម្ការហ្នឹងដោយអត់ឲ្យ -- ដោយគេមិនឲ្យលីសែងដី រែកដី តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ពេលហ្នឹង គេអត់មានបញ្ជូនពួកកងចល័តរបស់ខ្ញុំទៅការដ្ឋានទៀតទេ អត់មានទៅទេ។ អត់មានទៅទៀតទេ ដូច្នេះពួកកងចល័តទាំងប៉ុន្មានត្រូវនៅធ្វើស្រែចម្ការនៅផ្ទះហ្នឹង នៅកងចល័តហ្នឹង។

[១១:១៥:៤៧]

**ស៖** ឥឡូវនេះ មុននេះបន្តិចអ្នកស្រីឆ្លើយទៅនឹងព្រះរាជអាជ្ញា អ្នកស្រីឆ្លើយថា អត់មានអ្នកណា

ម្នាក់ស្លាប់ទេ នៅការដ្ឋានទំនប់នុ៎ង។ តើអ្នកស្រីធ្លាប់ឃើញមានមនុស្សទទួលរបួស ឬក៏ទទួលគ្រោះថ្នាក់អ្វីដែរឬទេ នៅការដ្ឋានទំនប់នោះ?

**ឆ៖** ចាស មានឃើញដែរ។ ឃើញអ្នកកាប់ ពួកយុវជនហ្នឹងកាប់ដី។ ដោយសារការលុងដីវាជ្រៅ បាក់សង្កត់។ បាក់សង្កត់ វាត្រូវជើងត្រូវអី អ៊ីចឹងរបួស មានឃើញ។

**ស៖** ខ្ញុំមើលទៅនាឡិកា ខ្ញុំឃើញថា ខ្ញុំនៅសល់សំណួរមួយទៀត។ អ្នកស្រីនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់អ្នកស្រី អ្នកស្រីនិយាយថា អ្នកស្រីត្រូវបានគេកំណត់គោលដៅដោយសារតែអ្នកស្រីមកពីខាងបូព៌ា។ តើអ្នកស្រីអាចពន្យល់បានទេថា អ្នកស្រីចង់មានន័យយ៉ាងម៉េច នៅពេលដែលអ្នកស្រីនិយាយពាក្យបែបនេះ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់អ្នកស្រី?

**ឆ៖** ចាស ពេលនាងខ្ញុំត្រឡប់មកពី១មករាវិញ មកនៅកងចល័តបានពីរបីខែ នាងខ្ញុំសុំទៅលេងផ្ទះ ក៏ជួបអ្នកប្រធានក្រុមតាមភូមិហ្នឹង គេដើរកត់ៗស្ថិតិអ្នកថ្មីហ្នឹង ហើយមកកត់ចំផ្ទះខ្ញុំ នាងខ្ញុំហ្នឹងទៅទាន់ឃើញ។ ថា គេសួរម្ដាយនាងខ្ញុំថា គ្រួសារអ៊ំពេលជម្លៀសពីភ្នំពេញមកមានបានឆ្លងទៅបូព៌ាអត់? ហើយពេលនោះម្ដាយនាងខ្ញុំក៏ប្រាប់គេតាមដំណើរហ្នឹងទៅ ព្រោះការជម្លៀស គឺការជម្លៀសដោយសារពួកខ្មែរក្រហមដឹកឡានទៅ ទៅក្រែកជីមាន់នោះ ត្រពាំងផ្ទុង ហើយបាននៅបានប្រាំប្រាំមួយខែជម្លៀសមកចំការលើវិញ។ ដូច្នេះនាងខ្ញុំក៏មិនដឹងដែរ ក្រោយមកបានប្រហែលជាបួនប្រាំខែ ក៏ត្រូវគេយកគ្រួសារនាងខ្ញុំ ព្រមទាំងអ្នកថ្មីនៅក្នុងភូមិ ដែលអ្នកបានឆ្លងទៅបូព៌ាហ្នឹង យកទៅសម្លាប់។ ហើយនាងខ្ញុំក៏មិនដឹងដែរ គ្នាដូចថា រស់នៅដូចកង្កែបក្នុងអណ្ដូងអ៊ីចឹង មិនដឹងជាបូព៌ាអី បះបោរបះអីក៏មិនដឹង ទើបតែពេលក្រោយមកហើយទេ ដែលយើងដឹងតាមៗ ដូចថា គ្នាទៅហ្នឹង។ ហើយគ្រួសារនាងខ្ញុំសុទ្ធតែស្រីទាំងអស់ក្មួយតូចៗនាងខ្ញុំប្រាំបីនាក់ ធំជាងគេ១២ឆ្នាំ តូចជាងគេ៣ឆ្នាំ គឺគ្នាមិនដឹងអីទេ។ មិនដឹងថា បូព៌ាហ្នឹងមិនដឹងថា អីគិញអី ស្អីសេ.អ៊ី.អា អី គឺមិនដឹងទាំងអស់។

[១១:១៩:០៧]

**ស៖** តើអ្នកស្រីធ្លាប់ឮនៅចុង -- ធ្លាប់ឮព័ត៌មានអីទាក់ទងនឹងចុង៧៨ ឬក៏ចូល៧៩ នុ៎ងទេ?

**ឆ៖** ចាស ពេលគេយកនាងខ្ញុំទៅសម្លាប់ នាងខ្ញុំរត់ទៅភូមិបងជីដូនមួយនៅភូមិបន្ទាយជ័យហ្នឹង ចម្ងាយប្រាំមួយប្រាំពីរគីឡូពីកន្លែងកងចល័តនាងខ្ញុំហ្នឹង។ ពេលនាងខ្ញុំទៅរស់នៅបានប្រហែលជាមួយខែ គឺមានៗគេជម្លៀសមក អ្នកបូព៌ា ហើយអ្នកស្រុកហ្នឹងគេចេះតែដឹងតាមខ្សឹបគ្នាទៅថា អ្នកបូព៌ា

មក ឃើញគេមក។ ឃើញគេមកមែន ហើយគេយកទៅសម្លាប់ទាំងយប់ៗនៅវាលស្រែត្រង់នេះៗអី។ អាហ្នឹងគេឃើញ អ្នកស្រុកហ្នឹងគេឃើញ គេប្រាប់នាងខ្ញុំអី បានដឹងតាមហ្នឹង។ បានដឹងត្រឹមពេលគេជម្លៀសអ្នកបូព៌ាហ្នឹងចេញពីណាពីណី ទៅតាមណាតាមណីយកទៅសម្លាប់ គឺនាងខ្ញុំដឹងពេលហ្នឹងថា គ្រួសារខ្ញុំ ដោយសារចម្លើយប្រាប់គេថា ជម្លៀសទៅបូព៌ាហ្នឹងហើយ ជាការសម្លាប់គ្រួសារខ្ញុំ។ ការជម្លៀសហ្នឹង គឺជាការពួកៗលោកជម្លៀស មិនមែននាងខ្ញុំទៅដោយខ្លួនឯងទេ គឺជម្លៀសខ្ញុំទៅហើយ មកវិញសួរចម្លើយហើយ យកពួកគ្រួសារនាងខ្ញុំទៅសម្លាប់ទៀត គឺដោយសារលោកទាំងអស់។

**ស៖** ខ្ញុំយល់តាមរយៈពាក្យសុំតាំងខ្លួនរបស់អ្នកស្រី ថាបងថ្លៃរបស់អ្នកស្រី គឺជាអតីតទាហាន លន់ នល់។ តើគាត់មានបានចូលរួមក្នុងការបះបោររបស់ខាងបូព៌ាដែរឬទេ?

[១១:២១:០០]

**ឆ៖** ចាស ដែលខ្ញុំជម្រាបលោកហើយ ព្រឹកមិញថា ពេលពួកខ្មែរក្រហមដឹកនាងខ្ញុំទៅដល់ស្លូង គេឲ្យនៅភូមិតាប៉ាវហ្នឹង គឺទៅដល់គេដាក់នៅម្ដុំហ្នឹង ពួកគេដើរប្រាប់ថាអ្នកទាំងអស់គ្នា កាត់សក់កាត់ក្រចក ហើយអ្នកណាដែលធ្វើការអី ត្រូវប្រាប់ឲ្យត្រង់ តែមិនត្រង់ថ្ងៃក្រោយគេដឹង គឺអត់បាន។ ពេលនោះគ្រួសារនាងខ្ញុំគឺប្រាប់គេត្រង់ ព្រោះលោកក៏អាចដឹងហើយ បើលោកនៅខាងខ្មែរក្រហម ប៉ុន្តែលោកដឹងហើយថា លន់ នល់ យ៉ាងណា គឺគ្មានមនុស្សប្រុសដើរទេ គឺចាប់បោះលើឡានតែម្ដង។ ចាប់សូម្បីតែគ្នាកូនសិស្សដើរទៅរៀនហ្នឹង គឺចាប់បោះលើឡានតែម្ដង ហ្នឹងដែលអ្នកដែលនៅ លន់ នល់ ដឹងហើយ។ ហើយបងថ្លៃនាងខ្ញុំក៏ប្រាប់ទៅថា ជាកំណែនៗរបស់គេ។ ហើយបងថ្លៃម្នាក់ទៀតធ្វើពេទ្យកាល់ម៉ែតក៏ប្រាប់ត្រង់អ៊ីចឹងទៅ ក្មួយប្រុសខ្ញុំ ឈាន ជីទួតមួយហ្នឹងជាទាហានដែរហ្នឹង គឺប្រាប់ទៅថានេះជាកំណែនរបស់គេទេ គឺមិនមែនចិត្តចង់។ យើងប្រាប់គេត្រង់អ៊ីចឹង ដោយសារការស្មោះត្រង់របស់ពួកយើង។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន។

សូមអញ្ជើញបាទ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រម។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ អត់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ខ្ញុំមានសំណួរខ្លីតែប៉ុណ្ណោះ ដើម្បីសូមការបំភ្លឺពីលោកស្រី។ នៅពេលដែលលោកស្រីនៅទំនប់១មករា បើសិនជាខ្ញុំអានមិនច្បាស់ទេ សូមអភ័យទោស។ គឺថាលោកស្រីធ្វើការនៅក្រោមបញ្ជារបស់ប្រធានក្រុមពីរនាក់ដែលថាមនុស្សស្រី គឺឈ្មោះ វ៉ាត ហើយនិង លី។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ មេកងមានពីរនាក់ហ្នឹង?

**លោកស្រី នួន ណារុំ៖**

**ឆ៖** ចាស ពិតជាត្រឹមត្រូវ។

**ស៖** អ៊ីចឹងសំណួរខ្ញុំចង់សួរថា តើរាល់ថ្ងៃនេះ ជាប្រចាំថ្ងៃនេះលោកស្រីបានជួបប្រធានពីរនាក់ទៀតដែលធំជាង វ៉ាត ហើយនិង រី ហ្នឹងដែរទេ? គឺថាតើលោកស្រីមានជួបអ្នកផ្សេងទៀត ក្រៅពីប្រធានលោកស្រីពីរនាក់ហ្នឹងទេ វ៉ាត ហើយនិង រី ហ្នឹងទេ?

[១១:២៣:៤១]

**ឆ៖** ខ្ញុំមិនច្បាស់សំណួរហ្នឹង ជួបនៅពេលណា? ពេលឥឡូវហ្នឹង ឬក៏ពេលណា ខ្ញុំមិនច្បាស់?

**ស៖** ខ្ញុំសួរម្ដងទៀត ប្រហែលជាមានបញ្ហាបកប្រែ។ ថានៅពេលដែលលោកស្រីធ្វើការនៅទំនប់១មករា លោកស្រីធ្វើការនៅក្រោមបញ្ជា វ៉ាត ហើយនិង លី។ លោកស្រីឆ្លើយបញ្ជាក់ហើយអំមិញថាអ៊ីចឹងមែន។ អ៊ីចឹងខ្ញុំសួរលោកស្រីថា លោកស្រីមានស្គាល់អ្នកណាដែលជាមេផ្ទាល់របស់ វ៉ាត ហើយនិង រី ហ្នឹងដែរឬទេ? មានមេណានៅលើគាត់ទៀត?

**ឆ៖** នៅកន្លែងការដ្ឋានន៎ុង ដូចជាខ្ញុំអត់ស្គាល់ ស្គាល់តែពីរនាក់ហ្នឹង ព្រោះនៅកងចល័តនេះបានមានមេធំទៀត។

**ស៖** អ៊ីចឹងជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា លោកស្រីផ្ទាល់នោះមិនដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងមេ ឬក៏ប្រធានរបស់ វ៉ាត ហើយនិង លី នេះទេ? តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ចាស ត្រឹមត្រូវហើយ។ ដូចថា មិនដែលមានពាក្យអីនិយាយទំនាក់ទំនងអីគ្នាទេ យើងខំតែធ្វើការ។ វាមិនដែលមានរឿងអីត្រូវពិភាក្សាគ្នា អត់មាន។

**ស៖** លោកស្រីបាននិយាយជាមួយសហព្រះរាជអាជ្ញាអម្បាញ់មិញហ្នឹង ហើយក៏ជាមួយនឹង

លោកមេធាវី កូប៉េ ផងដែរ។ លោកនិយាយអំពីករណីរបស់អ្នកធ្វើការជាមួយលោកស្រីម្នាក់ដែលត្រូវបានគេវ៉ៃ ដែលមានមេនារីម្នាក់អ្នកវ៉ៃ។ ខ្ញុំមិនដឹងថាច្បាស់ទេ អ្នកណាជាអ្នកវ៉ៃទេ លោកស្រីនិយាយថា យឿន ថាគាត់ហ្នឹងជា១ទំនងជាអ្នកដែលវ៉ៃមិត្តភក្តិ ឬក៏អ្នកធ្វើការជាមួយលោកស្រីទុំង។ លោកស្រីអាចបញ្ជាក់បានទេ ត្រង់ចំណុចហ្នឹង អ្នកណាជាអ្នកវ៉ៃមិត្តភក្តិលោកស្រីហ្នឹង?

[១១:២៦:០៦]

**ឆ៖** ចាស ពេលទៅការដ្ឋានមានតែប្រធានពីរនាក់ហ្នឹងទេ មានតែមិត្ត វ៉ាត និង លី ហ្នឹងទេ។ តែ មិត្តយឿន ណេះនៅប្រធានក្រុមនៅឯកងចល័តនេះ មិនបានទៅទេ។ តែ មិត្តវ៉ាត ហ្នឹងគេអ្នកវ៉ៃហ្នឹង មិត្តវ៉ាត។ មិត្តវ៉ាត ហ្នឹងដូចថា គេដូចថា ឆ្មើម១១ជាង មិត្តលី។ មិត្តវ៉ាត ហ្នឹងអ្នកវ៉ៃ អ្នកដូចថាគាត់បានសំឡេង បានសម្រេចរបស់គាត់ គឺមិត្តវ៉ាត។

**ស៖** ខ្ញុំសូមការបំភ្លឺពីលោកស្រីនោះ ដោយសារតាមរយៈការបកប្រែហ្នឹង ខ្ញុំមិនសូវយល់ច្បាស់។ លោកស្រីបានពន្យល់ថា វ៉ាត ហ្នឹងជាមេកងហ្នឹង ជាអ្នកវ៉ៃ អេង ហ្នឹង។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវហើយ។

**ស៖** អ៊ីចឹង តើជាការត្រឹមត្រូវដែរឬទេថា វ៉ាត ហ្នឹង គាត់មិនបានសុំការអនុញ្ញាតពីអ្នកណាទេ ដើម្បីវ៉ៃ អេង នេះ? អ៊ីចឹងក្នុងឋានៈគាត់ជាមេកងហ្នឹង គាត់ធ្វើ គាត់សម្រេចចិត្តខ្លួនឯង។ ឥឡូវខ្ញុំសួរប្រភេទផ្សេងទៀត តើជាការត្រឹមត្រូវដែរឬទេ ថានៅថ្ងៃដែល វ៉ាត នេះគាត់សម្រេចចិត្តវ៉ៃ អេង ហ្នឹង គាត់មិនមានអ្នកណានៅជាមួយគាត់ទេ គាត់សម្រេចចិត្តវ៉ៃដោយខ្លួនឯងតែម្តង?

**ឆ៖** ចាស ត្រូវហើយ ព្រោះគេបញ្ជូនពួកកងចល័ត ពួកនាងខ្ញុំមកទំនប់១មករាហ្នឹង គឺគាត់ហ្នឹងអ្នកគ្រប់គ្រង គឺតែពីរនាក់ហ្នឹងទេ សម្រេចការងារអីគឺលើគាត់ គ្មានអ្នកណាទៀតទេ។

[១១:២៨:២០]

**ស៖** ចំណុចចុងក្រោយ លោកស្រីបានឆ្លើយថា មានអង្រឹងសម្រាប់សែងអ្នកធ្វើការសន្លប់នៅលើការដ្ឋាន។ តើលោកអាចជម្រាបជូនបានទេថា អ្នកណាជាអ្នកសែងអ្នកជំងឺ អ្នកដែលដួលសន្លប់នៅលើការដ្ឋានហ្នឹង ចេញពីកន្លែងហ្នឹង? លោកស្រីអាចជម្រាបជូនបានទេ អ្នកណាជាអ្នកសែង ទទួលបន្ទុកខាងសែង?

**ឆ៖** ចាស ពេលសែងហ្នឹងគឺពួកយុវជនហ្នឹង ពួកប្រុស១ដែលធ្វើការហ្នឹង គេចាត់ឲ្យសែងទៅ

អ៊ីចឹង។

**ស៖** តើយុវជនទាំងអស់នុ៎ងសុទ្ធតែជាអ្នកធ្វើការនៅលើការដ្ឋានហ្នឹងដែរ គាត់ជាអ្នកកាប់ដីដែរ ឬក៏គាត់ហ្នឹងគេប្រើគាត់ឱ្យតែធ្វើការហ្នឹង គឺសម្រាប់តែសែងអ្នកដែលដួលសន្លប់នុ៎ងឯង?

**ឆ៖** ចាស គ្មានអ្នកសម្រាប់សែងទេ មានតែអ្នកកាប់ដីហ្នឹងសែង។ អត់មានអ្នកផ្សេងសម្រាប់មានសែងអីទេ គេមិនឱ្យមានមនុស្សឈរដោយឥតប្រយោជន៍ គេថាកុំឱ្យដកដង្ហើមចោល។ គេនិយាយពាក្យគេ គេមិនឱ្យមានមនុស្សដកដង្ហើមចោល គ្រប់ម៉ាត់ គ្រប់ជំហានគឺការងារ គឺមានតែអ្នកកាប់ដីហ្នឹងដែលសែងអ្នកដែលសន្លប់ហ្នឹង។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណដែលលោកស្រីបានឆ្លើយបំភ្លឺ។ លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

[១១:៣០:១៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះអរគុណលោកស្រី នួន ណារុំ។ សវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពព្យសនកម្ម ទុក្ខសោកវេទនាដែលលោកស្រីអះអាងថា លោកស្រីបានទទួលរងនោះ បានដល់ទីបញ្ចប់ហើយ ហើយលោកស្រីអាចសម្រាកបានហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកស្រី នួន ណារុំ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយអង្គជំនុំជម្រះអរគុណលោកស្រី ឆាយ ម៉ារីដែត ដែលជាបុគ្គលិកអង្គការ ធី.ភី.អូ លោកស្រីអាចសម្រាកបានហើយ។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនភាគី និងសាធារណជនដែរថា នៅរសៀលនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀតគឺ 2-TCCP-992 ហើយនិងអាចបន្តបន្ទាប់ទៀតតាមលំដាប់លំដោយ ដែលអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនកាលពីព្រឹកមិញ ហើយប្រសិនបើសវនាការធ្វើទៅបានឆាប់រហ័សជាងការគ្រោងទុក។

ហើយឥឡូវនេះដល់ពេលសម្រាកអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកត្រឹមនេះ ហើយសវនាការលើកបន្តធ្វើរសៀលនេះ ចាប់ផ្តើមពីម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣១ នាទី ដល់ម៉ោង ១៣:២៩ នាទី)*

[១៣:២៩:១៧]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការបន្តនៅរសៀលនេះអង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-992។ ប៉ុន្តែមុននឹងអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីរូបនេះចូលមកកាន់កន្លែងផ្តល់ថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនារបស់ខ្លួន អង្គជំនុំជម្រះធ្វើការផ្សព្វផ្សាយនូវដំណោះស្រាយបញ្ហាមួយចំនួន ពាក់ព័ន្ធនឹងសវនាការដាក់ឯកសារគន្លឹះ ដែលកើតមានបញ្ហាកាលពីសប្តាហ៍មុនដូចខាងក្រោមនេះ៖

កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ អង្គជំនុំជម្រះបានចាប់ផ្តើមធ្វើសវនាការលើការដាក់បង្ហាញឯកសារគន្លឹះ ពាក់ព័ន្ធនឹងអង្គហេតុស្តីពីការដ្ឋានការងារ។ អង្គជំនុំជម្រះបានគូសបញ្ជាក់នៅក្នុងអនុស្សរណៈ E315/1 ថាសវនាការនេះមានគោលបំណងផ្តល់ឱកាសឲ្យភាគីបង្ហាញឯកសារទាំងឡាយណា ដែលខ្លួនយល់ឃើញថា មានការពាក់ព័ន្ធជាក់លាក់ទៅនឹងអង្គហេតុនីមួយៗដែលត្រូវបានជំនុំជម្រះ (ហើយសូមមើលផងដែរឯកសារ E170 ឯកសារ E288/1/1)។

នៅក្នុងអំឡុងពេលដែលការិយាល័យសហព្រះរាជអាជ្ញាធ្វើការបង្ហាញឯកសារ សហមេធាវីអន្តរជាតិការពារក្តី នួន ជា បានជំទាស់ទៅនឹងការបង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយដែលទទួល

បានពីការិយាល័យសហចៅក្រមស៊ើបអង្កេត។ ក្រោយមកទៀត សហមេធាវីការពារក្ដី នួន ជា និង សហមេធាវីការពារក្ដី ខៀវ សំផន បានដើរចាកចេញពីបន្ទប់សវនាការ។

[១៣:៣១:៥៨]

នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ អង្គជំនុំជម្រះបានស្នើសុំឱ្យក្រុមមេធាវីការពារក្ដីនីមួយៗ ផ្ដល់នូវមូលដ្ឋានផ្លូវច្បាប់គាំទ្រលើការចាកចេញពីបន្ទប់សវនាការកាលពីថ្ងៃមុន (សូមមើលផងដែរឯកសារ E361)។ សហមេធាវីការពារក្ដីទាំងពីរក្រុមមិនអាចផ្ដល់មូលដ្ឋានផ្លូវច្បាប់ត្រឹមត្រូវណាមួយគាំទ្រលើការធ្វើដូច្នេះរបស់ខ្លួនឡើយ។ សហមេធាវីអន្តរជាតិការពារក្ដី នួន ជា បានទទួលស្គាល់ថា ការចាកចេញរបស់ខ្លួនពីបន្ទប់សវនាការ តាមពិតទៅគ្មានយុត្តកម្មផ្លូវច្បាប់ណាមួយឡើយ។ សហមេធាវីការពារក្ដី នួន ជា បានផ្ដល់យុត្តកម្មគាំទ្រលើការចាកចេញរបស់ខ្លួន ដោយផ្អែកលើការជំទាស់របស់ខ្លួនចំពោះលទ្ធភាពរបស់ការិយាល័យសហព្រះរាជអាជ្ញាក្នុងការបង្ហាញកំណត់ហេតុនៃការស្ដាប់ចម្លើយ នៅក្នុងអំឡុងពេលសវនាការលើការបង្ហាញឯកសារគន្លឹះ។ សហមេធាវីការពារក្ដី នួន ជា បានលើកឡើងថា ឯកសារទាំងនេះ មិនគួរត្រូវបានយកមកពិចារណាសម្រាប់គោលបំណងនៃការធ្វើសវនាការលើឯកសារគន្លឹះនោះទេ (សេចក្ដីព្រាងប្រតិចារឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ទំព័រ៥១ ទំព័រ៥២)។

អង្គជំនុំជម្រះសូមបញ្ជាក់សាជាថ្មីថា នៅក្នុងអំឡុងពេលនៃការដាក់បង្ហាញឯកសារគន្លឹះ ភាគីអាចយោងទៅលើឯកសារដែលត្រូវបានទទួលយករួចហើយ នៅក្នុងសំណុំរឿង០០២/០២បាន។ ទោះបីជាអង្គជំនុំជម្រះរំពឹងថា ភាគីទំនងជាសម្អាងភាគច្រើនលើឯកសារទាំងឡាយ ដែលនៅសេសសល់ពីសម័យនោះ ជាជាងកំណត់ហេតុនៃការស្ដាប់ចម្លើយនៅក្នុងអំឡុងពេលសវនាការនេះក៏ដោយ ក៏អង្គជំនុំជម្រះពុំធ្លាប់មិនឱ្យយោងទៅលើកំណត់ហេតុនៃការស្ដាប់ចម្លើយទាំងនោះដែរ។

[១៣:៣៤:០០]

អង្គជំនុំជម្រះសូមរំឭកដល់ភាគីថា ដោយសារហេតុថាឯកសារភស្តុតាងមិនចាំបាច់ត្រូវតែទទួលយកនៅក្នុងអំឡុងពេលនៃការសួរដេញដោលបុគ្គលមួយចំនួន ដែលបានចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះនោះទេ។ សវនាការទាំងនេះមានគោលបំណងជួយដល់អង្គជំនុំជម្រះ និងភាគីក្នុងការបង្ហាញឯកសារទាំងឡាយ ដែលជាប់ពាក់ព័ន្ធបំផុតទៅនឹងការជំនុំជម្រះ ហើយសវនាការនេះក៏ផ្ដល់លទ្ធភាពឱ្យសាធារណជន បានយល់ដឹងអំពីឯកសារនៅក្នុងការជំនុំជម្រះផងដែរ (សាលក្រមក្នុងសំណុំរឿង០០២/០១ ត្រង់កថាខណ្ឌ៦៧, ៦៨)។

ដើម្បីធានាឲ្យមានការពិភាក្សាដេញដោលចំពោះមុខ អង្គជំនុំជម្រះអនុញ្ញាតឲ្យភាគីទាំងអស់ផ្តល់មតិយោបល់លើឯកសារដែលភាគីម្ខាងទៀតបានដាក់បង្ហាញ។ អង្គជំនុំជម្រះបញ្ជាក់ថា សេចក្តីសន្និដ្ឋានដែលបានធ្វើឡើងដោយភាគីនៅក្នុងពេលនៃកិច្ចដំណើរការនីតិវិធី រួមទាំងក្នុងពេលសវនាការលើការបង្ហាញឯកសារគន្លឹះផងដែរនោះ នឹងត្រូវយកទៅពិចារណាចុងបញ្ចប់នៃសវនាការពិភាក្សាដេញដោលលើភស្តុតាងក្នុងសំណុំរឿង០០២ ដែលនៅពេលនោះ នឹងមានការវាយតម្លៃលើភស្តុតាងទាំងអស់ដែលបានទទួលយកនៅក្នុងពេលជំនុំជម្រះ និងអនុលោមតាមលក្ខណៈវិនិច្ឆ័យដែលត្រូវបានកំណត់នៅក្នុងយុត្តិសាស្ត្រពាក់ព័ន្ធ។

ពាក់ព័ន្ធនឹងកំណត់ហេតុនៃការស្តាប់ចម្លើយ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលអង្គជំនុំជម្រះបានបញ្ជាក់នាពេលមុនរួចហើយថា នត្ថិភាពនៃសក្ខីកម្មផ្ទាល់មាត់ និងឱកាសនៃការសួរដេញដោលចំពោះមុខ គឺជាកត្តាពាក់ព័ន្ធដែលត្រូវយកមកពិចារណាក្នុងការវាយតម្លៃទៅលើតម្លៃនិងទម្ងន់នៃភស្តុតាងដែលត្រូវផ្តល់ឲ្យទៅកំណត់ហេតុនៃការស្តាប់ចម្លើយ ឬពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលយកជំនួសឲ្យការផ្តល់សក្ខីកម្មផ្ទាល់មាត់ (ឧទាហរណ៍ សូមមើលឯកសារ E96/7 និង E299) បើសិនជាត្រូវមានការវាយតម្លៃទៅលើតម្លៃ និងទម្ងន់នៃភស្តុតាងបែបនេះ។

[១៣:៣៦:១៧]

អាស្រ័យហេតុនេះ អង្គជំនុំជម្រះលើកឡើងសាជាថ្មីអំពីការសម្រេចពីពេលមុនរបស់អង្គជំនុំជម្រះក្នុងអំឡុងពេលសវនាការលើការបង្ហាញឯកសារគន្លឹះថា ការជំទាស់របស់ នួន ជា ចំពោះការបង្ហាញកំណត់ហេតុនៃការស្តាប់ចម្លើយ នៅក្នុងអំឡុងពេលនៃការធ្វើសវនាការលើការបង្ហាញឯកសារគន្លឹះនេះ មិនមានមូលដ្ឋានឡើយ។

ដោយឡែក សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ដែលបានលើកឡើងពីការព្រួយបារម្ភផ្សេងៗទៀត ស្តីពីបង្ហាញនានា ពាក់ព័ន្ធនឹងការបន្តដាក់ឯកសារ ដាក់បង្ហាញឯកសារពីសំណុំរឿង០០៣ និង០០៤។ ជាពិសេស សហមេធាវីអន្តរជាតិការពារក្តី ខៀវ សំផន បានទាមទារឲ្យអង្គជំនុំជម្រះសម្រេចលើសំណើនានា ដែលបានធ្វើឡើងក្នុងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា (ឯកសារ E363 ដែលបានដាក់នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥)។

[១៣:៣៧:២០]

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា បញ្ហាមួយចំនួនដែលបានលើកឡើងនៅក្នុងឯកសារនេះ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងដោះស្រាយរួចហើយ នៅក្នុងគោលការណ៍ណែនាំស្ដីពីការដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៣ និង០០៤ មកក្នុងសំណុំរឿង០០២/០២។ ជាគោលការណ៍ណែនាំនេះ -- គោលការណ៍ណែនាំនេះ ត្រូវបានអង្គជំនុំជម្រះចម្លងជូនភាគីរួចហើយ នៅមុនពេលសវនាការកាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥។ អង្គជំនុំជម្រះនឹងដោះស្រាយបញ្ហាផ្សេងទៀតដែលបានលើកឡើងនៅក្នុងឯកសារនេះ បន្ទាប់ពីទទួលបានចម្លើយតបពីភាគីផ្សេងទៀតពាក់ព័ន្ធ។

មេធាវីការពារក្ដី ខៀវ សំផន ក៏បានជំទាស់ជាក់លាក់ទៅនឹងការបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា ចំពោះកំណត់ហេតុនៃការស្ដាប់ចម្លើយចំនួន១៨ ពីសំណុំរឿង០០៣ និង០០៤ ក្នុងអំឡុងពេលសវនាការបង្ហាញឯកសារគន្លឹះកាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ដែរ។ ដូចដែលបានលើកឡើងរួចមកហើយ នៅក្នុងសវនាការនោះកាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៥ អង្គជំនុំជម្រះបានយល់ព្រមតាមសំណើជាលាយលក្ខណ៍អក្សរដែលសហព្រះរាជអាជ្ញាបានដាក់កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ សុំឲ្យទទួលយកកំណត់ហេតុនៃការស្ដាប់ចម្លើយទាំងនេះ នៅក្នុងសំណុំរឿង០០២/០២ ជាឯកសារថ្មី អនុលោមតាមវិធាន៨៧(៣)និង៨៧(៤)នៃវិធានផ្ទៃក្នុង (សូមមើលឯកសារ E319/22/1)។

[១៣:៣៨:៥៧]

អង្គជំនុំជម្រះកត់សម្គាល់ថា មេធាវីការពារក្ដី ខៀវ សំផន នៅស្ងៀម មិនបានលើកការជំទាស់ណាមួយចំពោះសំណើសហព្រះរាជអាជ្ញាឡើយ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញានឹងទទួលបានការអនុញ្ញាតឲ្យបង្ហាញកំណត់ហេតុនៃការស្ដាប់ចម្លើយទាំងនេះនៅក្នុងសវនាការ នៃការបង្ហាញឯកសារគន្លឹះដែលនឹងធ្វើបន្តនៅចុងសប្ដាហ៍នេះ។ មេធាវីការពារក្ដី ខៀវ សំផន ក៏បានជំទាស់នឹងការបង្ហាញឯកសារ D195.7 និង E342.1 ដែរ។ សហព្រះរាជអាជ្ញាបានលើកឡើងនាពេលក្រោយមកទៀតថា ពួកគាត់នឹងមិនបង្ហាញឯកសារ E342.1។ អង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារ D195.7 មិនត្រូវបានទទួលយកក្នុងសំណុំរឿង០០២/០២ទេ។ ហេតុនេះសហព្រះរាជអាជ្ញានឹងមិនអនុញ្ញាត -- នឹងមិនត្រូវបានអនុញ្ញាតឲ្យបង្ហាញឯកសារនេះ នៅក្នុងអំឡុងពេលសវនាការនៃការដាក់បង្ហាញឯកសារគន្លឹះនេះឡើយ។

ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់អំពីការលំបាក និងអារម្មណ៍តានតឹងដែលភាគីមានចំពោះដំណើរការនីតិវិធីដែលមានរយៈយូរ និងស្មុគស្មាញនេះ។ អង្គជំនុំជម្រះនឹងបន្តដោះស្រាយ

បញ្ហាដែលកើតមានឡើងឲ្យអស់ពីលទ្ធភាព ប្រកបដោយយុត្តិធម៌ និងភាពស៊ីសង្វាក់គ្នា។ អង្គជំនុំជម្រះនឹងបន្តផ្តល់ឱកាសឲ្យគ្រប់ភាគីបញ្ចេញមតិយោបល់ឲ្យពេញលេញ ក្នុងលក្ខណៈសមស្របទៅលើបញ្ហានានាដែលសមស្រប និងពាក់ព័ន្ធ។

[១៣:៤០:៣៧]

នៅក្នុងសវនាការថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ លោកមេធាវី វ៉ិចទ័រ កូប៉េ បានលើកឡើងជាលក្ខណៈរិះគន់ ដោយមិនមានការគោរពមួយចំនួនចំពោះសមាជិកក្រុមប្រឹក្សាជំនុំជម្រះ។ ទោះបីជាអង្គជំនុំជម្រះគោរពសិទ្ធិរបស់លោកមេធាវី វ៉ិចទ័រ កូប៉េ ក្នុងការបញ្ចេញមតិយោបល់ និងសិទ្ធិសេរីភាពក្នុងការនិយាយស្តីក៏ដោយ។ ក៏មតិយោបល់មួយចំនួនដែលលើកឡើងក្នុងសវនាការបានបំពានទៅលើព្រំដែននៃឥរិយាបថត្រឹមត្រូវនៅក្នុងសវនាការ។ អង្គជំនុំជម្រះកំពុងពិចារណាលើវិធានការសមស្របដែលត្រូវអនុវត្តចំពោះបញ្ហានេះ។ លោកមេធាវី វ៉ិចទ័រ កូប៉េ ខ្លួនឯងក៏បានទទួលស្គាល់ថានៅតុលាការខ្លះឥរិយាបថរបស់គាត់ត្រូវបានចាត់ទុកថា ជាកំហុសឆ្គងនៃការមើលងាយតុលាការ។ អង្គជំនុំជម្រះសូមផ្តល់ឱកាសឲ្យលោកមេធាវី វ៉ិចទ័រ កូប៉េ កែប្រែឥរិយាបថនេះ ហើយអង្គជំនុំជម្រះកត់សម្គាល់ថា ប្រសិនបើលោកមិនកែប្រែឥរិយាបថនេះទេ អង្គជំនុំជម្រះនឹងគ្មានជម្រើសអ្វី ក្រៅពីចាត់វិធានការខ្លះៗនោះឡើយ។ អង្គជំនុំជម្រះនឹងជូនដំណឹងភាគីបន្ថែមទៀត អំពីស្ថានភាពនេះនៅក្នុងពេលសមស្របខាងមុខ។

ហើយជាចុងក្រោយនេះ ដោយផ្អែកលើការបញ្ជាក់របស់ក្រុមមេធាវីការពារក្តីទាំងពីរ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ថាខ្លួននឹងមានវត្តមាននៅក្នុងតុលាការ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា អង្គជំនុំជម្រះមិនចាំបាច់ចាត់វិធានការនៅពេលនេះ ពាក់ព័ន្ធនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្តីពីចំណាត់ការនាពេលខាងមុខ ចំពោះសវនាការលើការដាក់បង្ហាញឯកសារគន្លឹះ ទាក់ទងនឹងការដ្ឋានការងារនេះទេ (ឯកសារ E360)។

[១៣:៤២:៣៦]

ជាបន្តនេះ យើងធ្វើសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-992 ចូលមកកាន់កន្លែងដែលរៀបចំឲ្យគាត់អង្គុយថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មចំពោះមុខអង្គជំនុំជម្រះនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអី?

**លោកស្រី ចៅ ឡាង៖**

**ឆ៖** ចាស សូមគោរពលោកប្រធាន។ នាងខ្ញុំឈ្មោះ ចៅ ឡាង។ កើតនៅថ្ងៃទី០១ ខែ០១ ឆ្នាំ១៩៥១។ នាងខ្ញុំ ស្រុកកំណើតរបស់នាងខ្ញុំនៅច្រាំងចំរេះ ខណ្ឌឫស្សី ក្រុងភ្នំពេញ។ បច្ចុប្បន្ននាងខ្ញុំរស់នៅភូមិកោះខ្សុង ឃុំអូរជ្រៅ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

[១៣:៤៥:០៨]

**ស៖** បាទ អរគុណ។ តើលោកស្រីអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរឬទេ ថាតើឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ម្តាយបង្កើតរបស់លោកស្រីឈ្មោះអី?

**ឆ៖** ចាស សូមជម្រាបលោកប្រធាន។ ឪពុកនាងខ្ញុំឈ្មោះ ចៅ សាង។ ម្តាយនាងខ្ញុំឈ្មោះ ស៊ឹម សុខុម។ គាត់អតីតជាទាហានប្រចាំការនៅបន្ទាយប្រសូត្រ ខេត្តស្វាយរៀង។

**ស៖** បាទ អរគុណ។ ចុះប្តីរបស់លោកស្រីគាត់ឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ចាស សូមជម្រាបដល់លោកប្រធាន។ ប្តីនាងខ្ញុំឈ្មោះ ឃឹម ខុន។ នាងខ្ញុំមានកូនបីនាក់ ប្រុសពីរ ស្រីមួយ។ បច្ចុប្បន្ននាងខ្ញុំបានបែកគ្នាហើយ អស់រយៈពេលជាប់៣០ឆ្នាំ។

**ស៖** អ៊ីចឹងបានសេចក្តីថា បច្ចុប្បន្ននេះ លោកស្រីមេម៉ាយទេ ជាស្ត្រីមេម៉ាយអ៊ីចឹងទេ?

**ឆ៖** ចាស លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនភាគី និងសាធារណជនជ្រាបផងដែរថា នៅក្នុងដំណើរការសវនាការស្តាប់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង អង្គជំនុំជម្រះបានសម្របសម្រួលជាមួយនឹងអង្គការ ធី.ភី.អូ ដោយទទួលយកលោកស្រី ឆាយ ម៉ារីដែត ដើម្បីអង្គុយនៅក្បែរដើមបណ្តឹងរដ្ឋប្បវេណីនេះ នៅក្នុងអំឡុងពេលដែលគាត់ផ្តល់សេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ក្នុងបំណងគឺដើម្បីពង្រឹងស្មារតីរបស់គាត់ដើម្បីឲ្យគាត់មានអារម្មណ៍ល្អ ហើយចៀសវាងការព្រួយបារម្ភភ័យខ្លាចដើម្បីឲ្យគាត់អាចធ្វើការបង្ហាញអំពីមូលហេតុ និងហេតុផលទាំងឡាយដែលគាត់បានទទួលរងទុក្ខសោកវេទនា និង

ព្យសនកម្មក្នុងអំឡុងពេលៗកម្ពុជាប្រជាធិបតេយ្យដែលចោទប្រកាន់ចំពោះជនជាប់ចោទ។

[១៣:៤៧:៤៤]

លោកស្រី ចៅ ឡាង ក្នុងនាមលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនលោកស្រី ដើម្បីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកស្រី ជាអាទិ៍ ការខូចខាតខាងផ្លូវកាយ ផ្លូវចិត្ត សម្ភារៈ ដែលជាព្យសនកម្មផ្ទាល់ខ្លួន ដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ និងបានកើតមានពិតប្រាកដរហូតដល់បច្ចុប្បន្ននេះ ដែលនាំឱ្យលោកស្រីប្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះ ដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីររូបគឺ នួន ជា និង ខៀវ សំផន ហើយដែលលោកស្រីអះអាងថា បានប៉ះពាល់ដោយផ្ទាល់ចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩។

ហើយគួរតែសង្កត់ធ្ងន់ទៅលើអង្គហេតុដែលពាក់ព័ន្ធទៅនឹងការចោទប្រកាន់ ដែលអង្គជំនុំជម្រះកំណត់បានធ្វើសវនាការរួចហើយ គឺការដ្ឋានការងារ។ នៅក្នុងនោះ គឺការដ្ឋានការងារចំពោះទំនប់ត្រពាំងថ្ម នេះតាមពាក្យប្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រី។ ហើយតាមសំណើសុំរបស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខ ដើម្បីមានលទ្ធភាពក្នុងការសាកសួរអំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មដែលកើតមានចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឡាង។

[១៣:៤៩:១៩]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សូមអនុញ្ញាតបញ្ជាក់បន្តិច គឺគាត់មិនមែននិយាយអំពីអង្គហេតុនៅត្រពាំងថ្មទេលោកប្រធាន គឺនៅទំនប់១មករា។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ នៅទំនប់១មករា ការដ្ឋានពីរអាចច្រឡំគ្នា។ បាទ ទំនប់១មករា។

លោកស្រី ចៅ ឡាង តើលោកស្រីជម្រើសនៅក្នុងការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ឬក៏ស្ថានភាពព្យសនកម្មដែលប៉ះពាល់ចំពោះលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលលោកស្រីអះអាងទទួលរងដោយខ្លួនឯង ឬក៏លោកស្រីមិនធ្វើដោយខ្លួនឯងទេ? លោកស្រីទទួលយកនូវសំណើសុំ

របស់មេធាវីការពារក្តី ដែលយើងបានផ្តល់លទ្ធភាពទៅជូនមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នូវលទ្ធភាពនៅក្នុងការសាកសួរអំពីស្ថានភាពពាក់ព័ន្ធជាមួយនឹងប្រធានបទ ដែលយើងកំណត់ធ្វើសវនាការនៅពេលនេះ។ ពីព្រោះបញ្ហាមានពីរ ទី១គឺគំនិតដើម គឺចង់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីដែលមានលទ្ធភាព គឺថ្លែងទុក្ខសោកវេទនាដោយខ្លួនឯង ចេញពីដួងចិត្តខ្លួនឯង។ ហើយប្រសិនបើលោកស្រីមានបំណងធ្វើយ៉ាងណេះក៏ធ្វើបាន ហើយបើសិនលោកស្រីធ្វើមិនបានទេ លោកស្រីអាចប្រាប់ទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីគាត់ធ្វើនីតិវិធីនៃការទទួល ការអនុញ្ញាតពីអង្គជំនុំជម្រះរួចហើយថា ឲ្យគាត់សាកសួរពាក់ព័ន្ធជាមួយនឹងបញ្ហានេះចំពោះលោកស្រី ដើម្បីជាការណែនាំ ឬក៏ជាការដោះស្រាយបញ្ហាមួយដែលអាចប្រព្រឹត្តទៅបានផងដែរ។ នេះជាមធ្យោបាយ លទ្ធភាពមួយទៀតដែលនៅក្នុងនីតិវិធីនេះ យើងបានអនុវត្តកន្លងមកហើយដែរ។

[១៣:៥១:៣៧]

**លោកស្រី ថៅ ឡាង៖**

ចាស នាងខ្ញុំសូមឲ្យមេធាវី គាត់សាកសួរចាស។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតផ្ទេរសិទ្ធិនៅក្នុងការសាកសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ជូនលោកមេធាវី ឡោ ជុនធី។ បាទ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

សូមអញ្ជើញលោកមេធាវី ឡោ ជុនធី!

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** សូមជម្រាបសួរលោកស្រី ថៅ ឡាង។ ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីតំណាងដើម

បណ្តឹងរដ្ឋប្បវេណី។ ហើយនៅពេលនេះ ខ្ញុំបាទនឹងជម្រាបសួរលោកស្រីដែលពាក់ព័ន្ធទៅនឹងបរិបទទំនប់១មករា។ ប៉ុន្តែជាដំបូង គឺខ្ញុំជម្រាបសួរថា តើអ្នកស្រីបានមុនឆ្នាំ១៩៧៥ បានន័យថា មុនថ្ងៃបែក ១៧ មេសា បន្តិច តើលោកស្រីនៅឯណាដែរ?

**លោកស្រី ចៅ ឡាង៖**

**ឆ៖** ចាស សូមគោរពលោកមេធាវី។ សូមអរគុណចាស។ នាងខ្ញុំមុនឆ្នាំ៧៥នេះ រយៈពេលមុនប្រហែលជាមួយខែ មុនចូលឆ្នាំ នាងខ្ញុំបានធ្វើការនៅមន្ទីរពេទ្យ៤០៤ នៅខេត្តសៀមរាប។ នៅពេលដែលមុនបែកនេះ ខ្ញុំបានជួបនឹងលោកស័ក្តិ៥ ខាងហ្វីលីពីនម្នាក់ដែលគាត់ទទួលខាងគ្រប់រំសេវដាក់ចូលឃ្លាំងនេះ។ គាត់បានប្រាប់នាងខ្ញុំថា "កញ្ញា ឡាង សុំច្បាប់គេទៅលេងឪពុកម្តាយទៅ ព្រោះអីបើតាមមើលស្ថានភាពខ្មែរក្រហម ប្រហែលជាវ៉ៃបែកទីក្រុងភ្នំពេញហើយ។ កាលណាយកបានទីក្រុងភ្នំពេញ គឺយកបានទាំងអស់នុ៎ង ទាំងអស់ហ្នឹង ទាំងគ្រប់ខេត្តទាំងអស់ហ្នឹង។ អ៊ីចឹងនារីឯង ធ្វើយ៉ាងណាត្រូវទៅដល់ឪពុកម្តាយឲ្យហើយទៅ។ សុំច្បាប់គេទៅទៅ ហើយលាក់ប្រវត្តិរូបខ្លួនឯងឲ្យជិត។ លាក់ប្រវត្តិរូបខ្លួនឯងឲ្យជិត ព្រោះអីខ្មែរក្រហម កាលណាវ៉ៃបែក គាត់នឹងស្រាវជ្រាវរកស្ថាប័ន គ្រប់ស្ថាប័នទាំងអស់ ទាំងពេទ្យ ទាំងទាហាន ទាំងអ្វីៗដែលអ្នកដែលមានការងារធ្វើនោះ គឺគាត់នឹងស្រាវជ្រាវហើយ។ ស្រាវជ្រាវហើយ កាលណាគាត់ស្រាវជ្រាវបាន គឺគាត់សម្លាប់ចោលហើយ។"

[១៣:៥៤:៥៤]

ពេលនោះ ខ្ញុំក៏ដាក់ច្បាប់តាមគាត់ ហើយខ្ញុំ អារម្មណ៍ខ្ញុំគិតថា មិនអាចសម្លាប់បានទេ បើសិនជារំដោះបាននោះ មិនគួរឲ្យជឿថា សម្លាប់ទេ។ ខ្ញុំក៏ដាក់បានមកដល់ទីក្រុងភ្នំពេញជួបឪពុកម្តាយខ្ញុំ នៅសង្កាត់លេខ៤។ គាត់ក៏បាន មានប្រហែលជាកន្លះខែ មានមិត្តភក្តិនៅកៀនស្វាយ នៅខាងដីឥដ្ឋ គាត់មកហៅខ្ញុំទៅថា "តោះ! យើងទៅលេងនៅដីឥដ្ឋទៅ សប្បាយជាងនៅភ្នំពេញ ព្រោះអីមានឈូង មានអង្គុញអីអ៊ីចឹង។" ចាស នៅពេលដែលខ្ញុំទៅហ្នឹងក្នុងថ្ងៃទី១៣ ខ្ញុំបានទៅបោះអង្គុញលេងនឹងគេហ្នឹងសប្បាយមែន ចេញទៅម្នាក់ឯងហ្នឹង។ បោះហើយបោះដល់ថ្ងៃទី១៧នេះ ខ្ញុំនៅតែនឹកមិនជឿថា អាចវ៉ៃបែកទីក្រុងភ្នំពេញទេ។ នៅពេលដែលកំពុងតែបោះឈូងនោះ បោះអង្គុញនោះ ផ្អើលមនុស្សម្នាមកថា "យី! ហើយចុះមិត្តឯងនៅសប្បាយដល់ណាទៀត? មិត្តឯងម៉េចក៏មិនរត់?" ខ្ញុំថា "អ្ហា! រត់រឿងអីៗ?" "យី! មិត្តឯងអត់ដឹងទេ ខ្មែរក្រហមគេវ៉ៃបែកភ្នំពេញហើយណា។" ពេលនោះ នៅពេលដែលឈូឆរហ្នឹង ខ្ញុំក៏បានស្តាប់ឮសូរគ្រាប់កាំភ្លើង មានធំ មានតូច បាញ់ប្រែវប្រាវ ខ្ញុំក៏រត់តាមគេទៅកោះប្រាក់។ រត់តាមគេ

សិនហើយ ព្រោះអីខ្លាចវាមកបាញ់ដល់ហ្នឹងអីទៅ។ រត់ដល់កោះប្រាក់បានមួយយប់ ខ្ញុំក៏បកមកដីឥដ្ឋហ្នឹងវិញ។ កំពុងតែមនុស្សឈូឆរហ្នឹង ខ្ញុំនឹកឃើញឪពុកម្ដាយខ្ញុំដែលគាត់ ប៉ាខ្ញុំគាត់ត្រូវគ្រាប់។ ខ្មែរក្រហមបាញ់ៗកាលរដ្ឋប្រហារ កាលដែលទម្លាក់ព្រះកុរុណា លន់ នល់ ឡើងកាន់កាប់។

[១៣:៥៧:១៧]

អ៊ីចឹងខ្ញុំក៏មកជួប នឹកឃើញថាទៅជួបម្ដាយខ្ញុំ បងប្អូនខ្ញុំហើយ។ ខ្ញុំរុលជ្រែកគេជ្រែងឯងទៅដល់វត្តចំប៉ា។ ឃើញហេតុការណ៍នោះភ្លាមៗ ដែលមិនគួរឲ្យជឿ ត្រូវតែជឿពេលនេះ។ ដេញបាញ់ៗ ដោយខ្ញុំឃើញផ្ទាល់នឹងភ្នែក។ ខ្ញុំរត់វក់វីជួយមួយគេ ឲ្យរួចផុតពីគ្រាប់ដែលគេបាញ់ ហើយឃើញពីរនាក់ដួលព្រួសហើយ នៅចិញ្ចើមថ្នល់។ ដេញបាញ់ម្នាក់ទៀតរហូតដល់ក្រោយវត្តចំប៉ា។ ដល់មាត់ទន្លេ ខ្ញុំរត់គេចតាមគេដែរ ឃើញហេតុការណ៍ហ្នឹង។ បាញ់ស្លាប់ ដល់គាត់ស្រាតខោទាហានពុំទាន់ ដោះបានតែអាវទេ។ បាញ់ស្លាប់នៅនឹងមាត់ទឹកហ្នឹងទៀត។ ត្រង់ចំណុចនេះហើយដែលធ្វើឲ្យខ្ញុំនឹករឿងដែលលោកកូវ៉ាដូ ដាមីត គាត់ជនជាតិហ្វីលីពីនគាត់បានផ្ដាំខ្ញុំទុក ចាស។

**ស៖** បាទ អរគុណ។ ថាតើនៅពេលណា ដែលអ្នកស្រីបានឆ្លងកាត់ពីកន្លែងដែលឃើញព្រឹត្តិការណ៍ហ្នឹង ហើយទៅដល់ខាងទំនប់១មករា នៅពេលណាខ្លះ? សុំជម្រាបរៀបរាប់ពីកន្លែងដែលលោកស្រីបានលើកឡើងអម្បាញ់មិញ ទៅដល់ទំនប់១មករា។

**ឆ៖** ចាស នាងខ្ញុំសូមជម្រាបអង្គសាលាក្ដីទាំងមូល។ នាងខ្ញុំបាននៅដីឥដ្ឋហ្នឹង ត្រឡប់មកវិញហើយ វត្តចំប៉ាហ្នឹងខ្ញុំមិនអាច នាងខ្ញុំមិនអាចចូលទៅភ្នំពេញបានវិញទេ ដោយសារថាមើលទៅការបាញ់ដេញបាញ់អី ធ្វើឲ្យនាងខ្ញុំភ័យខ្លាច នាងខ្ញុំបកក្រោយវិញ មកដល់ដីឥដ្ឋហ្នឹង។ នាងខ្ញុំនៅ រស់នៅបានប្រហែលជា១២ខែ អ៊ីចឹងមិនដឹងទេ ពុំបានចាំទេ។ ដោយរួមរស់ជាមួយអ្នកភូមិហ្នឹង បានញ៉ាំដើមគល់ចេក កន្ទក់។ ដោយការអត់ទ្រាំពុំបាន នាងខ្ញុំក៏ធ្វើលួចៗធ្វើដំណើរម្នាក់ឯង។ ទៅតម្រង់ទិសដៅទៅស្វាយរៀង។ តែនាងខ្ញុំដើរម្នាក់ឯងនោះ គេចពីឈ្លបយាមកាមតាមផ្លូវអី គឺគេចទៅជួបឈ្លបមួយនោះថា “មិត្តឯងទៅណា?” ខ្ញុំថា“ខ្ញុំសុំមិត្តទៅរកឪពុកម្ដាយខ្ញុំ ដោយខ្ញុំឮឪពុកម្ដាយខ្ញុំនៅស្វាយរៀង”។ “មិត្តឯងមិនត្រឡប់ក្រោយ ប្រយ័ត្នគេឲ្យមិត្តឯងរែកដីអា្ហ! ជីកដី ឲ្យមិត្តឯងជីកដី រែកដី!” ខ្ញុំថា “មិត្តអើយអាណិតមេត្តាខ្ញុំទៅ ខ្ញុំទៅជួបឪពុកម្ដាយខ្ញុំទៅ”។ ពេលហ្នឹងក៏គេមិនមាត់មិនក ខ្ញុំក៏គេចវេះតាមភូមិគេពួនអីអ៊ីចឹង។ ទៅដល់អ្នកលឿងៗ ហ្នឹងទៀត ឃើញគេស្រឡាងគេហ្នឹងដាក់សុទ្ធតែឡានចាស់ៗ គរត្រួតលើគ្នា ខ្ញុំមិនដឹងធ្វើម៉េចទេ ខ្ញុំមើលនាយអាយមិនឃើញមានឈ្លបទេ ខ្ញុំក៏រត់រឹងចូលទៅស្រឡាង ចូលទៅ

ក្រោមឡានចាស់ៗហ្នឹងចាស។ ចូលទៅហើយ ខ្ញុំលួចមើលតាមក្រោមឡានហ្នឹង ជើងគេដើរពីណាទៅណា វិលជុំវិញក្នុងក្រោមឡានហ្នឹងរហូតដើម្បីកុំឲ្យគេឃើញ គឺគេចវេះ ខ្ទិចខ្ទៀនជាមួយឡានចាស់ៗហ្នឹង រហូតដល់ខ្ញុំបានឆ្លងផុតអ្នកលឿងទៅត្រើយម្ខាង។ ពេលនោះ អត់មានប្រជាជន១៧ទេ សុទ្ធតែកងទ័ពយោធារបស់ខ្មែរក្រហម។ ខ្ញុំទៅជួបពួកគេទៀត គេថា "ចុះមិត្តនារីឯងទៅណា?" ខ្ញុំថា "មិត្តអើយ ខ្ញុំឮសូរដំណឹងឪពុកម្ដាយខ្ញុំនៅស្វាយរៀង ខ្ញុំធ្វើដំណើរទៅជួបគាត់"។ "មិត្តឯងនៅសម្រាកហ្នឹងមួយយប់ហើយ!" ខ្ញុំថា "អត់ទេ ខ្ញុំប្រញាប់ទៅមុខទៀត ដើម្បីឲ្យបានដល់ជួបពួកគាត់"។

[១៤:០២:២៧]

**ស៖** ខ្ញុំសុំកាត់បន្តិច ដោយសារពេលវេលាយើង ហើយថាតើនៅពេលដែលយើង អុំទៅដល់ស្វាយរៀងហ្នឹងបានជួបឪពុកម្ដាយដែរឬអត់?

**ឆ៖** ចាស លោកមេធាវី ខ្ញុំសូមបញ្ជាក់ថា នៅពេលដែលខ្ញុំធ្វើដំណើរទៅនោះ ពុំបានជួបឪពុកម្ដាយទេ។ នេះជាការភូតកុហករបស់នាងខ្ញុំ ដើម្បីឲ្យខ្ញុំបានស្វែងរកឪពុកម្ដាយនាងខ្ញុំ។ តែផ្ទុយទៅវិញ ខ្ញុំពុំបានជួបទេ ខ្ញុំបានជួបបងជីដូនមួយខ្ញុំនៅភូមិបោះព្រីង ខេត្តស្វាយរៀង។ បន្ទាប់មកទៀត ខាងភូមិបោះព្រីងហ្នឹង ចុះខេត្តស្វាយរៀង ប៉ាខ្ញុំគាត់ធ្លាប់ក្ដោបក្ដាប់នៅតំបន់គ្រប់តំបន់ខេត្តស្វាយរៀងហ្នឹង គាត់ប្រជាពលរដ្ឋហ្នឹងគាត់ ប្រជាជនចាស់ហ្នឹងគាត់ស្គាល់ច្រើន។ តែដោយសារការស្គាល់ប៉ាខ្ញុំ ក៏គេធ្មេចភ្នែកធ្មេចច្រមុះអ៊ីចឹងទៅ។ ដល់ពេលគេថា ឥឡូវត្រូវការយកប្រជាជន១៧មេសាហ្នឹង ត្រូវទៅភូមិថ្មី ទឹកដីថ្មីដើម្បីឲ្យបង្កបង្កើនផល។ មិត្តណាបែកបងប្អូន មិត្តណាបែកឪពុកម្ដាយ ចង់ទៅ ទៅទៅ។ ខ្ញុំនឹកឃើញថា អ្ហែ! បើអ៊ីចឹងទេ ខ្ញុំត្រូវតែទៅហើយ ខ្ញុំមិនអាចនៅភូមិបោះព្រីងទេ ដោយសារថា ក្រែងលោភូមថ្មីហ្នឹង បានជួបឪពុកម្ដាយខ្ញុំ។ គេដាក់រទេះគោទាំងបងស្រីខ្ញុំពីរនាក់ប្ដីប្រពន្ធ ព្រមទាំងក្មួយស្រីអាយុ៣ឆ្នាំមួយ និងនាងខ្ញុំម្នាក់ទៀត ដាក់រទេះគោទៅ។ គិតទៅរទេះគោវាចូលទៅជាង១០រទេះគោ។ បញ្ជូនទៅៗដល់ៗៗភូមិអូរកន្សែងហ្នឹងមួយថ្ងៃ ប៉ុន្មានយប់ប៉ុន្មានថ្ងៃ ខ្ញុំពុំបានចាំទេ។ ទៅដល់ភូមិអូរកន្សែងហ្នឹងក៏គេយកទៅផ្ញើដាក់នៅតាមផ្ទះប្រជាជនចាស់របស់គេ។ ពេលនោះ អត់មានអីញុំាទេអត់មានអីហូបទេ។ នាងខ្ញុំប្រវេប្រវា ទៅចាប់បានក្ដាមមួយ យកមកបុកៗយកទឹកហើយ រំងាស់យកៗទៅហូបជាមួយបាយដែលគេឲ្យអង្ករមួយកំប៉ុងចែកគ្នាដាំបាយ ដាំបបរអីហូបអ៊ីចឹងទៅ។ បន្ទាប់មកទៀត នាងខ្ញុំហ្នឹងក៏បានធ្វើការជាមួយគេហ្នឹង បានតិចណាស់ គេចាត់តាំងឲ្យឡើងជាកងចល័ត ជាកម្លាំងស្រួច។ មានគ្នានោះឈ្មោះ ឃឹម សំអុល មួយ, ឃឹម ផូ មួយ, ឃឹម ភួន មួយ, ឃឹម ខុន និងនាងខ្ញុំ ថៅ ឡាង ចាស។

ប៉ុន្មានរូបនេះហើយ ដែលគេយកទៅជាកម្លាំងស្រួច ទៅកងចល័ត – កងចល័តតំបន់។

[១៤:០៥:៥៨]

**ស៖** បាទ សូមៗកាត់បន្តិច ដោយសារ -- ថាតើនៅពេលដែលថា ដឹកចល័ត ដឹកចេញទៅជាមួយមីងជាមួយអីហ្នឹង ទៅដល់កន្លែងណា? ហើយនៅពេលណាដែលគេបញ្ជូនទៅកងចល័តដែលចល័តនៅទំនប់១មករាហ្នឹង?

ឆ៖ ចាស នាងខ្ញុំទៅដល់ភូមិអូរកន្សែងហ្នឹង ប្រហែលជារយៈពេលដ៏ខ្លីទេ ដែលនាងខ្ញុំត្រូវគេឲ្យឡើងជាកងចល័តតំបន់៤២ គឺគេយកទៅទំនប់១មករានោះហើយ។ នៅពេលដែលខ្ញុំទៅដល់ទំនប់នោះ ខ្ញុំពុំបានចាំថា ភូមិនោះជាភូមិអីទេ ដែលគេបោះទីតាំងឲ្យនាងខ្ញុំជាកងចល័តរស់នៅនោះ គ្រាន់ថានៅអែបនឹងថ្នល់ជាតិ តែនាងខ្ញុំអត់បានចាំថា ជាភូមិអ្វីទេ។ ពេលនោះហើយ ដែលនាងខ្ញុំចុះទៅទំនប់នោះ ទៅរែកដីទាំងយប់ ទាំងថ្ងៃ។

**លោក ឡៅ ជុនធី៖**

បាទ សុំៗបន្តិច។ សូមគោរពលោកប្រធាន នៅពេលនេះ ខ្ញុំបាទខាងមេធាវីសូមបង្ហាញនូវខ្សែវីដេអូ ដែលមានលេខ E3/33014R ដោយមាន*ម៉ឺនុត*គឺ សូន្យៗទៅដល់ដប់ប្រាំ*ស៊ីហ្គុង*។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

បុគ្គលិកសំឡេង-រូបភាព ផ្សាយនូវវីដេអូឃ្លីប តាមសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

*(ការបង្ហាញឯកសារជារូបភាព)*

[១៤:០៨:៤០]

**សួរដោយលោក ឡៅ ជុនធី៖**

**ស៖** បាទ តាមអ្វីដែលខ្សែវីដេអូអម្បាញ់មិញ តើលោកស្រីអាចចំណាំបានថាជាកន្លែងលោកស្រីបានធ្វើការនៅក្នុងសម័យនោះដែរទេ?

**លោកស្រី ចៅ ឡាង៖**

**ឆ៖** ចាស សូមអរគុណលោកមេធាវី។ ទីតាំងនេះហើយដែលនាងខ្ញុំបានទៅធ្វើនោះ ចាស បាន

ទៅរែកដីនៅទីនោះហើយ។ នៅពេលដែលនាងខ្ញុំបានទៅរែកដីនៅទីនោះ នាងខ្ញុំរែកដីពិបាកមែនទែន ដោយសារថា ជួនកាលអាចបាក់ដងរែកហើយ យកឈើមកអបដងរែកហ្នឹងទៀត ចាសអបដងរែកហ្នឹងទៀត។ សំខាន់បំផុតដែលនាងខ្ញុំខំប្រឹង ប្រឹងដោយហួសពីកម្លាំងខ្លួនឯង គឺនាងខ្ញុំគិតថា ធ្វើម៉េចឲ្យរួចពីការស្លាប់ ព្រោះកន្លងមកនាងខ្ញុំបានទៅធ្វើនេះ នៅពេលបកមកវិញនោះ គេឲ្យធ្វើការប្រជុំតូចៗជាក្រុមៗហ្នឹង ឲ្យមានការស្វ័យទិតៀនគ្នាទៅវិញទៅមក គេហៅថា កញ្ចក់ឆ្លុះបញ្ចាំងគ្នាទៅវិញទៅមក។ ហើយពេលនោះហើយដែលនាងខ្ញុំនឹកឃើញថា ការឆ្លុះបញ្ចាំងនេះ វាជាការត្រឹមត្រូវហើយ ព្រោះអីមើលឃើញថា អ្នកណាមួយដែលសកម្ម អ្នកណាមួយមិនសកម្ម មិននឹកស្មានថា អ្នកមិនសកម្មគេអាចនឹងបាត់ខ្លួនទេ។

[១៤:១០:៣១]

អ៊ីចឹងការធ្វើស្វ័យទិតៀន និងទិតៀននេះ គឺនាងខ្ញុំបានៗ ថ្ងៃមួយនាងខ្ញុំប៊ានៗទិតៀនដល់មេៗក្រុម។ ហេតុអីបានជានាងខ្ញុំប៊ានទិតៀន នាងខ្ញុំថា “មិត្តនារី មិត្តឯងជាប្រធាន មិត្តឯងស្រែកផ្ដុកញ្ចែច្រេចៗ – ម៉ោងប្រហែលជា១បួន១ ឬក៏បួនជាងប៉ុណ្ណោះទេលោកប្រធាន – ច្រេចៗ ហើយទៅដល់ពេលខ្ញុំអើតចេញមក មិត្តឯងស្រែកក្នុងមុងហ្នឹង។ បើមិត្តឯងផ្លុំកញ្ចែច្រេចៗ មិត្តឯងចេញមកៗ។ ពួកខ្ញុំនឹងចេញតាមមិត្តឯងហើយ ដល់មិត្តឯងស្រែកច្រេចៗ មិត្តឯងនៅតែក្នុងមុង។” ចាស ត្រង់នេះហើយខ្ញុំក្រោយមកខ្ញុំភ័យដែរ ភ័យ មុខតែស្លាប់ហើយ។ ប៊ាន គេឆ្លើយមួយម៉ាត់ គេថា “មិនដែលអ្នក១៧មេសាណាប៊ានទិតៀនដល់មេកង មេក្រុមអីអ៊ីចឹងទេ។” ខ្លួនខ្ញុំក៏មិនដឹងដែរ ព្រោះដោយសារនឹកឃើញថាការទិតៀននេះដើម្បីស្វែងរកឲ្យយើងធ្វើអ្វី ដូចថាយើងខ្ជិលច្រអូស យើងខំប្រឹងឡើងមិន១១១នឹកស្មានថា ការស្វ័យទិតៀនគ្នាទៅវិញទៅមកនេះ នឹងបាត់ខ្លួនទេ។ ប៉ុន្តែចំពោះនាងខ្ញុំវិញ ទិតៀនដល់អ្នកៗជាប្រធានក្រុមហើយ មិនទាន់បាត់ខ្លួនចាស មិនដឹងជាមូលហេតុអីដែរចាស។

ខ្ញុំសូមបញ្ជាក់ដែរ នៅពេលទំនប់នេះ ខ្ញុំប្រឹងៗរហូតដល់ខ្ញុំធ្វើដល់១១ស្គម សឹងថាស្គមមែនទែនហើយគ្មានកម្លាំងកំហែងទេ ប្រឹងហ្នឹងប្រឹងដោយសារថា កម្លាំងចិត្តដើម្បីឲ្យជៀសផុតនូវការដែលគេយកទៅសម្លាប់។ ក្រោយបន្ទាប់មកទៀតមក គេឲ្យច្បាប់ខ្ញុំមួយថ្ងៃ ទៅលេងភូមិអូរកន្សែង។ ហើយខ្ញុំសូមលោកប្រធាន ខ្ញុំអត់បានចាំពេលវេលាថ្ងៃខែទេ គ្រាន់តែចាំបានថា ថ្ងៃមួយនោះគេឲ្យខ្ញុំសម្រាកមួយថ្ងៃទៅលេងសហករណ៍។

[១៤:១៣:២២]

ពេលខ្ញុំទៅដល់អូរកន្សែង ប្រជាជនចាស់របស់គេនោះ គេថា "អួ! មិត្តឯងមកធ្វើអី? បងមិត្តឯងគេយកទៅសម្លាប់ហើយៗ"។ ខ្ញុំសួរថា "គាត់មានទោសកំហុសអី ដែលគេយកទៅសម្លាប់?" គេឆ្លើយប្រាប់ខ្ញុំវិញថា "គាត់ជាខ្មែរស"។ ខ្ញុំថា "ហេតុអីបានចោទគាត់ថាជាខ្មែរស?" "ព្រោះគាត់មានអំបិលហូប។" អំបិលនេះបើតាមនាងខ្ញុំដឹង គឺអំបិលដោយមានការដោះដូរជានាឡិកា ដោយគេស្រឡាញ់អ្នកមូលដ្ឋានគេស្រឡាញ់។ ខ្ញុំសួរគេទៅវិញថា "បើគេចោទគាត់ថាជាខ្មែរស គេយកគាត់ទៅសម្លាប់យ៉ាងដូចម្ដេច?" គេឆ្លើយប្រាប់ខ្ញុំថា "ប្ដីនិងប្រពន្ធគេដាក់ច្រវាក់ ដាក់នឹង ទាក់នឹងរទេះគោ។ កូនអាយុ៣ឆ្នាំ ក៏គេដាក់អ៊ីចឹងដែរ។ គេអូសបញ្ច្រាសកាត់ព្រៃទៅហើយមិត្តអើយ"។ តើកូនក្មេងអាយុ៣ឆ្នាំ បើថាយកទៅសម្លាប់ ចាំបាច់ដាក់ច្រវាក់អូសបញ្ច្រាសដូចឪម្ដាយធ្វើអី កាត់ព្រៃភ្នំ? តើបងស្រីខ្ញុំ និងក្មួយខ្ញុំវេទនាយ៉ាងណានៅពេលមុននឹងស្លាប់? នៅពេលនោះ ខ្ញុំស្ទើរតែសន្លប់បាត់លែងដឹងអ្វីទាំងអស់ បាត់ស្មារតីអស់ហើយ ការតាំងខ្លួនរបស់ខ្ញុំទាំងប៉ុន្មាន គឺអស់រលីងៗទាំងអស់ ទន់ជង្គង់គ្រឹប។

បន្ទាប់មកទៀត មិត្តដែលប្រាប់ខ្ញុំហ្នឹង គាត់ថា "មិត្តឯងឆាប់ទៅវិញទៅ កុំនៅ ប្រយ័ត្នពាក់ព័ន្ធគេយកទៅទៀត"។ ដល់ចំណុចដែលគេប្រាប់ខ្ញុំ ខ្ញុំវិលវិញភ្លាមអត់បាននៅពេញមួយថ្ងៃ ដូចគេឲ្យកំណត់ឲ្យខ្ញុំទៅលេងទេ។ ខ្ញុំខ្លាចពាក់ព័ន្ធដល់រូបនាងខ្ញុំទៀត។ ឃើញនាងខ្ញុំយំអ៊ីចឹង ខ្លាចគេមកចោទប្រកាន់ថា យ៉ាងម៉េចយ៉ាងម៉ានោះទៀត កុំឲ្យគេដឹង ខ្ញុំរឹងមកវិញចាស រឹងមកវិញ។ ខំប្រឹងធ្វើការតទៅទៀតហើយ មិនប៉ានធ្វើអ្វី សកម្មភាពអ្វីឲ្យគេដឹងនៅក្នុងកងចល័តតំបន់៤២ទេ គឺខំលាក់ លាក់មិនឲ្យដឹងទេ។

[១៤:១៧:២៧]

ដល់តែពេលថ្ងៃមួយនោះ នាងខ្ញុំមិនដឹងថា ក្ដៅហ្នឹង វាដល់ថ្នាក់សន្លប់យ៉ាងម៉េច ខ្ញុំអត់បានដឹងខ្លួនទេ។ ខ្ញុំដឹងខ្លួនបន្តិចឡើង ឃើញនៅក្នុងមន្ទីរពេទ្យរបស់គេ ជាបន្ទប់មួយងងឹត គេដាក់ខ្ញុំនៅក្នុងនោះ គ្មានឃើញបបរគ្មានឃើញបាយអីទេ គឺដឹងខ្លួនឡើង ដឹងថាខ្លួនក្ដៅខ្លាំងតែប៉ុណ្ណោះទេ។ ចប់ការងារម៉ោងប្រាំមានមិត្ត ឃឹម ផូ គាត់បានសុំថា "មិត្ត! សមមិត្តអើយ ខ្ញុំសុំមើល មិត្តឡាង បន្តិចទៅ យប់ហ្នឹងខ្ញុំអត់បានទៅធ្វើការទេ ដោយសារថា មិត្តហ្នឹងប្រហែលជាមិនរស់ទេ ព្រោះគាត់ក្ដៅខ្លាំងណាស់ ឲ្យខ្ញុំសុំបានមួយយប់មក នៅក្បែរគាត់"។ មិត្តផូ សុំគេបាន បងផូ ដែលគាត់ឈ្មោះ ឃឹម ផូ នោះគាត់នៅប្រទេសកាណាដាហើយពេលនេះ។ គាត់បានសុំគេបានមួយយប់មែន ដោយសារឃើញខ្ញុំក្ដៅខ្លាំងពេក។ គាត់បោចស្លឹក គាត់ទៅបេះស្លឹកគ ស្លឹកគហ្នឹងគេដាំជារបង។ បេះស្លឹកគយកមកឲ្យខ្ញុំច្របាច់ៗ មួយកាមែល

ទាហាន មួយកាមែលបាយរបស់ទាហានហ្នឹង ច្របាច់ពេញមួយកាមែលហ្នឹង ឡើងក្លាយទៅជា ដូចចាហួយអ៊ីចឹង។ ឲ្យខ្ញុំញ៉ាំហើយ ស្លឹកហ្នឹងយកមកពពោកក្បាល ពពោកទ្រូង ពពោកពោះ ខ្លួនអីទាំងអស់ពពោក មួយយប់ទាល់ភ្លឺង គឺខ្ញុំញ៉ាំតែទឹកគរហូត។ ពេលនោះខ្ញុំមិនអាចស្រាកស្រាន្តបាននូវកំដៅទេ។ ឈ្មោះ បងធូ ហ្នឹងជិតភ្លឺ គាត់នឹកឃើញ ថាគាត់ទៅចោលខ្ញុំទៀតហើយ។ គាត់ក៏លើកដៃសំពះថា "មិត្តអើយ! ឲ្យខ្ញុំសុំថ្នាំអ្វីប្លែកពីអាចម៍ទន្សាយហ្នឹងមក ក្រៅថ្នាំសូនគ្រាប់ខ្មៅៗហ្នឹងមក ក្រែងជួយមិត្តឡាងផង"។ គេក៏ហុចថ្នាំមួយគ្រាប់ ខ្ញុំចេះវិធីពេទ្យ កាលដែលខ្ញុំធ្វើពេទ្យ ខ្ញុំបានស្គាល់ថ្នាំនោះគឺ អាស្ពារីន។ បានថ្នាំហ្នឹងមួយគ្រាប់ញ៉ាំលាយនឹងទឹកគហ្នឹងទៅ ទើបបានខ្លួនខ្ញុំត្រជាក់។ ត្រជាក់ហើយហ្នឹងមិនប៉ាន ថាធ្វើទម្រន់អីដែលខ្លួនត្រជាក់ហើយ ទម្រន់ឲ្យបាននៅតទៀត គឺអត់ប៉ានទេ។ ប្រញាប់ប្រញាល់រត់ទៅកន្លែងរែកដីទៀតហើយ។

[១៤:២០:៥៧]

ក្រោយមកទៀត ខ្ញុំបានរែកដីហើយហ្នឹង ក៏ដល់រដូវខែស្រូវទុំ ខាងវាលស្រែ១០០នោះ។ ទុំឡើងបាក់កហើយ ដល់អ៊ីចឹងទេ គេដកកងចល័តមួយចំនួន គឺដកដោយនាងខ្ញុំទៅទៀត។ ដល់វាលស្រែ១០០មានច្រូតកាត់ហើយអស់។ ពេលច្រូតកាត់នោះ ក្តៅខ្លាំងណាស់ គ្មានទឹកហូបទេ គ្មានអ្វីញ៉ាំឲ្យបានពេញពោះទេ។ ច្រូតហើយ ដើររកទឹក។ លេបទឹកមាត់រហូត ទម្រាំនឹងបានទឹកហូប ផ្អុកអាចម៍ក្របី។ មកដល់កន្លែងអត់អីហូបទៀត បោចត្រកួនឲ្យហើយ តាមវាលស្រែ។ ប្រហែលជាខ្លះ២ម៉ែត្រ ខ្លះ១ម៉ែត្រជាង ទាំងឫស ទាំងគល់អីមកទាំងអស់។ យកមកស្ងោរ ស្ងោរឲ្យហើយ គេចែកបបរមក គឺយកមកលាយ លាយទៅដើម្បីហូបទៅឲ្យបានឆ្អែត។

ច្រូតកាត់ហើយអស់ គេអនុញ្ញាតឲ្យមកលេងសហករណ៍។ នៅពេលដែលខ្ញុំមកដល់សហករណ៍ខាងសហករណ៍គេបើកសណ្តែកខៀវនោះឲ្យមួយកំប៉ុង ស្ករនោះបន្តិចមក គេឲ្យមិត្តឯងបបរញ៉ាំទៅហូបទៅ។ ដល់តែបានរាង ១គេឲ្យហូបអ៊ីចឹង យី! សហករណ៍ចិត្តបានណាស់ ឲ្យសណ្តែកខៀវខ្ញុំ ស្ករខ្ញុំអ៊ីចឹង ខ្ញុំអត់ទៅវិញ។ ខ្ញុំអត់ទៅវិញ គេមកតាម គ្នាប្រាំបួននាក់ដែលបើកឲ្យមកលេង។ អត់ព្រមទៅវិញទេ គេមកតាម គេថា "ឥឡូវមិត្តឯង តោះទៅវិញ!" ខ្ញុំថា "ខ្ញុំមិនទៅទេ ខ្ញុំសុខចិត្តស្លាប់ជាមួយបងប្អូននៅភូមិនេះហើយ សហករណ៍នេះហើយ"។ គេថា "មិត្តឯង អង្គការមកតាមអង្វរមិត្តឯង! ទៅមិនទៅ?" ខ្ញុំថា "ខ្ញុំមិនទៅទេ សុខចិត្តស្លាប់ជាមួយបងប្អូននៅសហករណ៍នេះហើយ"។ ប្រកែកគេហើយប្រកែកគេទៀត។ គេថា "មិត្តឯងមិនអីទេ ពេលនេះអង្គការមកអង្វរមិត្តឯង។ ប្រយ័ត្នមិត្តឯងអង្វរ

អង្គការវិញ ប្រយ័ត្នណា!"។ ខ្ញុំនឹកឃើញថា អ្ហ៎! មិនដឹងប្រយ័ត្នអីទេ បើស្លាប់ក៏ស្លាប់ជាមួយគ្នីគ្នានៅនឹងភូមិហ្នឹងចុះ មិនទៅវិញទេ ដាច់ខាតគឺមិនទៅ។ ស្រាប់តែគេលេងមែនទែន គេហៅប្រធានសហករណ៍ឱ្យហៅមក ឱ្យប្រធានសហករណ៍ហៅមកប្រជុំសិន។ មិនដឹងថា គេមកហៅទៅហ្នឹង ដើម្បីដាក់ច្រវាក់ទៅទេ។ ពេលនោះគេថា "មិត្តឯង តោះទៅប្រជុំមួយភ្លែត"។ មិនដឹងថា គេហៅហ្នឹងហោយកទៅដាក់ច្រវាក់អូសទៅទេ។ ពេលនោះហើយនាងខ្ញុំក៏ទៅតាមគេហ្នឹង ស្រាប់តែចូលបន្ទប់ភ្លឹប វាដាក់ច្រវាក់ភ្លែតទាញច្រវាក់មកដាក់គ្រឹបៗបន្តគ្នា ប្រាំបួននាក់។

[១៤:២៥:១៣]

បណ្ដើរទាំងយប់ទៅវាលស្រែ១០០វិញ។ ពួកប្រុសៗគេថា បើសិនជាយើងរត់រួចតែប្រុសៗទេ រត់ចូលព្រៃ ឯចំណែកស្រីៗប៉ុន្មានហ្នឹងមុខជាស្លាប់ហើយ។ អ៊ីចឹងទេ យើងតស៊ូទាំងអស់គ្នា បើស្លាប់ៗទាំងអស់គ្នាទៅ នៅទាំងអស់គ្នាទៅ។ គេបណ្ដើរទៅហ្នឹងរហូតដល់កណ្ដាលអធ្រាត្រយប់ជ្រៅមែនទែនដល់ៗវាលស្រែ១០០។ នាំគ្នាអស់សង្ឃឹមហើយ ពេលគេដាក់ច្រវាក់បណ្ដើរទៅនេះ មិនទឹកស្មានថារស់បានសព្វថ្ងៃនេះទេ មុខតែស្លាប់ហើយ។ កេះគ្នាហើយ ថាយើងស្លាប់ហើយ។ គេដាក់បាយ ចុងភៅយកបាយមួយឆ្នាំងមក ត្រីងៀតមួយកន្ទុយមក។ កេះគ្នាថា អ្ហ៎!គេឱ្យហូបហ្នឹងប្រហែលជាថ្ងៃបញ្ចប់ហើយថ្ងៃគេសម្លាប់ចោលហើយ។ នាំគ្នាហូបទៅយើង តោះហូបទៅហូបឱ្យឆ្អែតទៅ មើលទៅគេសម្លាប់យើងចោលហើយ។ ហូបហើយអីហើយចប់សព្វគ្រប់ គេណែនាំ គេថា "សំណាងល្អហើយមិត្តឯងនេះ ទាំងអស់គ្នានេះ ដែលអង្គការមិនយកមិត្តឯងទៅណានោះ ដោយសារអី? ដោយសារការប្រឹងប្រែងរបស់មិត្តឯង។ អង្គការមើលឃើញ ឱ្យបាយមួយពេលហ្នឹង"។ ចាសឱ្យបាយមួយពេលហ្នឹង ជាគុណបំណាច់របស់អង្គការហើយដែលយើងខំប្រឹងធ្វើប៊ិះស្លាប់ប៊ិះរស់។

បន្ទាប់មកទៀតនោះ ចប់ហើយ គេថាដកទៅទៀតហើយ ដកពីវាលស្រែ១០០ហើយទៅប្រឡាយនៅវាលស្ពឺ -- ទៅដាំកប្បាសនៅបុសខ្នុរ។ ចាប់ផ្ដើមដើរទៀតហើយ ទាំងយប់ទាំងថ្ងៃ។ ដើរហ្នឹង ខ្ញុំដើរទាំងធ្មេចភ្នែកលក់រឹងចូលព្រៃប្រោក។ ដឹងខ្លួនឡើង ងាកមកដើរវិញ ដើរតាមផ្លូវ តាមជួរគ្នាមិត្តៗទាំងអស់នោះវិញ។ ដើរៗលក់រឹងទៅចូលព្រៃទៀតហើយ ទម្រាំនឹងភ្លឺហ្នឹង មិនដឹងជាលក់ចូលព្រៃប៉ុន្មានដង ដើរ។ រហូតដល់នាងខ្ញុំហ្នឹងដល់បុសខ្នុរ ដាំកប្បាស។ ដាំកប្បាសនេះ គឺនៅពេលបាញ់ថ្នាំ គឺបាញ់ទាំងយប់ បាញ់ទាំងថ្ងៃ មានវេន។ បើវេនថ្ងៃ វាដូរវេនវិលទៅវិលមក។ ថ្ងៃមួយនោះ វេននាងខ្ញុំយប់ គេឱ្យកាន់ម៉ាំងសុង ចង្កៀងម៉ាំងសុងរបស់គេ គេឱ្យបំភ្លឺអ្នកបាញ់ថ្នាំ។ យូរៗៗ អាល័យតែមើលទៅ

មុខអ៊ីចឹង អាក្រោមហ្នឹងរណ្ដៅ ធ្លាក់ក្នុងទាំងៗៗចង្កៀងម៉ាំងសុង ទៅទាំងមនុស្ស ទៅទាំងនាងខ្ញុំ។ អ៊ីចឹងគេនាំគ្នាឈូឆរមកចាប់ទាញឡើងវិញចាស មួយយប់ទល់ភ្លឺគឺបាញ់ថ្នាំកប្បាស។

[១៤:២៩:០០]

**សៈ** បាទ សូម -- តើសូមបង្ហិលបន្តិចថា តើនៅក្នុងការដ្ឋានទំនប់១មករា ហ្នឹងមានស្ថិតដែលជាការចាប់អារម្មណ៍ធ្វើឲ្យមានការឈឺចាប់ដែលធ្វើនៅទំនប់១មករាហ្នឹង?

**ផះ** ចាស សូមអរគុណលោកមេធាវី ខ្ញុំសូមឆ្លើយជូនលោកមេធាវី។ ទំនប់១មករានេះ មានការឈឺចាប់នោះ គឺនៅពេលដែលនាងខ្ញុំឈឺ គ្មានបងប្អូន គ្មានញាតិសន្តាន ឈឺដោយម្នាក់ឯង ឯកោម្នាក់ឯង មិនសង្ឃឹមថារស់ ចាសមិនសង្ឃឹមថារស់ទេនៅពេលដឹងខ្លួនម្ដងៗ។ មួយទៀត ការហូបមិនគ្រប់គ្រាន់ ធ្វើឲ្យនាងខ្ញុំស្គមស្គាំង ស្លេកស្លាំង។ ធ្វើការរហូតដល់ម៉ោងប្រហែលជាដប់ ឬក៏ដប់មួយអ៊ីចេះមិនដឹងទេ ចាសខ្ញុំមិនអាចចាំច្បាស់ទេ យប់។ គេដើរមកអស់ហើយ នៅតែនាងខ្ញុំមួយទេ បានដឹកដៃបង ឃឹម ផូ នេះគាត់ជាមនុស្សខ្វាក់មាន់។ ដឹករៀងរាល់ថ្ងៃពេក នាងខ្ញុំពិបាកទ្រាំពេក ពេលណាក៏ទៅគេងក្រោយគេ ពេលណាក៏ទៅក្រោយគេ រាល់ពេលរាល់វេលាពេក។ នាងខ្ញុំក៏បានជួបប្រទះថ្នាក់ដឹកនាំ គាត់អង្គុយបីរូប នៅកណ្ដាលផ្លូវនាងខ្ញុំដើរហ្នឹង អែបនឹងផ្លូវនាងខ្ញុំដើរមកហ្នឹង។ មានអារម្មណ៍មួយគិតថា បើសិនជានាងខ្ញុំនៅតែដឹកដៃ គេនៅតែមិនដឹង។ បើអ៊ីចឹងទេ នាងខ្ញុំលែងអ្នកខ្វាក់មាន់ហ្នឹងទៅឲ្យទៅជាន់មិត្តទាំងបីហ្នឹងមើល៍ វាយ៉ាងម៉េច។ ដើរទៅកៀកនាងខ្ញុំលែងដៃរឹប គ្នាដើរទៅជាន់មែន ជាន់រឹប ងាកមកផាំង។ "ទាច អ្ហឺមិត្តឯងម៉េចមកជាន់ខ្ញុំអ៊ីចឹង?" "ហ៊ឺ! មិត្តបងហើយ ខ្ញុំមើលអីអត់ឃើញទេ"។ "ចុះអ្នកណាប្រើមិត្តឯងឲ្យមក?" ខ្ញុំថា អ្ហឺ! ខ្ញុំឆ្លើយតបជំនួសថា "ហ៊ឺ! សមមិត្តហើយ មិត្តបងហើយខ្ញុំវេទនាណាស់ ខ្ញុំដឹកដៃរាល់តែយប់ មិនដែលខានយប់ណាទេ" "អ្ហេ! ទៅវិញទៅ ទៅប្រាប់ទៅ ប្រាប់មេកងមេក្រុមទៅ ឈប់ឲ្យមិត្តហ្នឹងមក យប់"។ រួចខ្លួនមួយ ចាសរួចខ្លួនមិត្ត ឃឹម ផូ ហ្នឹងហើយ។ ត្រង់ហ្នឹងហើយដែលគាត់ដឹងថា ខ្ញុំជាមនុស្សដែលដឹងទុក្ខធុរៈរបស់គាត់ គាត់ក៏ដាច់ចិត្តសុំៗនៅមើលផ្ទៃខ្ញុំមួយយប់។ ចាសត្រង់ហ្នឹង ចំណុចហ្នឹង។

[១៤:៣២:៤៩]

មួយទៀត នៅពេលដែលខំធ្វើហ្នឹងមួយរយៈពេល៣ថ្ងៃ មួយអាទិត្យ គេប្រជុំម្ដងអ៊ីចឹងទៅចាស គេប្រជុំម្ដង គេឲ្យប្ដេជ្ញាចិត្ត។ "យើងខ្ញុំទាំងអស់គ្នាប្ដេជ្ញាចិត្ត សម្រេចតាមផែនការរបស់អង្គការដាក់ចុះឲ្យបាន១០០ភាគរយ ជយោ! មហាលោតផ្លោះ មហាអស្ចារ្យ!"។ ចាស ប៉ុន្តែការប្រជុំនេះ គេបាន

ព្រមានគេថា "មិត្តទាំងអស់ កង់ប្រវត្តិសាស្ត្រវិលទៅមុខហើយណាមិត្ត អត់ថយក្រោយបានទេ មិត្តណាប៉ានប្រឆាំង មិត្តណាប៉ានយកដៃទៅរាំងវា មិត្តហ្នឹងដាច់ដៃ មិត្តណាប៉ានយកជើងទៅរាំងវា មិត្តហ្នឹងគឺដាច់ជើងហើយ"។ អ៊ីចឹងក្នុងម្នាក់ៗហ្នឹង គឺប្ដេជ្ញាៗដាច់ខាតត្រូវតែធ្វើឱ្យបានតាមផែនការរបស់អង្គការដាក់ចុះ។

**ស៖** បាទ សូមបន្តចំណុចមួយទៀត ថាតើនៅពេលដែលលោកស្រីបានធ្វើការនៅទំនប់១មករានុ៎ង តើមានជួបព្រឹត្តិការណ៍អ្វីមួយទៀតទេ ដែលគេចាប់មិត្តភក្ដិដែលស្គាល់ហ្នឹង? តើមានបានដឹងពីបញ្ហាហ្នឹងទេ?

**ឆ៖** ខ្ញុំអត់បានដឹងមិត្តភក្ដិដែលចាប់ទេ។ ខ្ញុំអត់បានដឹងទេ ប៉ុន្តែគ្រាន់តែថា អ្នកដែលធ្វើការទីនោះ គឺដឹងប្រហាក់ប្រហែលតែគ្នាទេ។ គឺដឹងតែពេលណាដែលយើងរែកទៅៗ អារម្មណ៍គិតថា ធ្វើម៉េចខំប្រឹងធ្វើម៉េច ដើម្បីឱ្យចៀសផុតនូវការសម្លាប់នោះ។ អ៊ីចឹងទេ ពុំបានចាប់អារម្មណ៍អ្វីទេ។ លុះធ្វើរែកទៅៗ សម្លឹងទៅសម្លឹងមក ស្រាប់តែបាត់មួយអ៊ីចឹងទៅ អូ៎! មិត្តនោះបាត់ហើយ មិនដឹងបាត់មូលហេតុអីទេ ចាសបាត់ហើយ។

**ស៖** បាទ ចុះករណីមានឈ្មោះ សុង និងបងប្អូន តើករណីហ្នឹង?

**ឆ៖** ខ្ញុំសូមជម្រាបលោកមេធាវីដែរ ឈ្មោះ សុង នេះមិននៅទំនប់ទេ។ ឈ្មោះ សុង នេះនៅចម្ការកប្បាស។ ចាស ខ្ញុំសូមបង្វែរទៅខាងចម្ការកប្បាសវិញ ដាំកប្បាសវិញ។ កប្បាសនេះ ដាំៗហ្នឹង ស្រាប់តែថ្ងៃមួយ មានមិត្តនារី ចាន់ នោះគេហៅថា មិត្តនារីចាន់ តែបើតាមពួតៗគ្នា អ្នកដែលស្គាល់នារី ចាន់នោះជាអ្នកតែក្វាន់ដូៗ នារីចាន់។ ហើយ--

**ស៖** បាទ អ៊ីចេះ យើងផ្ដោតតែលើបញ្ហាដែលចេញពីទំនប់១មករា។ អ៊ីចឹង ថាតើនៅពេលសម័យនោះ អ្នកស្រីមានបានរៀបអាពាហ៍ពិពាហ៍ឬនៅ?

[១៤:៣៦:៥០]

**ឆ៖** ចាស នៅចំណុចនេះ ខ្ញុំមានការភ្លាំងភ្លាត់ មានការភ្លេចភ្លាំងនេះ គឺនៅពេលដែលស្នាដៃចប់នេះហើយ ដែលគេហៅទៅរៀបការនោះដោយបង្ខំ ដោយនាងខ្ញុំពុំបានពេញចិត្ត ឬក៏បានថា មានការទំនាក់ទំនងនោះទេ។ គេថា កំពុងតែនេះហ្នឹង គេថា "ន៎ែ! មិត្តនារី! មិត្តឯងរៀបចំខ្លួនប្រាណទៅ!" ហ្នឹងមកពីរែកដីវិញ គេកេះមកថា "មិត្តនារីទៅៗកន្លែងមួយភ្លែតទៅ" ខ្ញុំថា "ទៅមានការអីមិត្ត?" "ថ្ងៃហ្នឹងគេរៀបចំគ្រួសារឱ្យមិត្តឯងហើយ"។ ខ្ញុំថា៖ "អ្ហឺ! រៀបចំគ្រួសារម៉េចទៅ បើខោអាវអត់មានផង

ហ្នឹង?" "មិនអីទេ ចាំអង្គការយើងឱ្យមួយកំប្លេ ស្លៀកពេលរៀបចំហ្នឹង ប៉ុន្តែមិត្តឯងកុំប្រកែក! មិត្តឯងប្រកែក ចប់ហើយមិត្តអើយ អត់បានទេ"។ ពេលមកដល់កន្លែង គេបោះខោអាវមួយកំប្លេហើយ គេបោះក្រមាមួយព្រួស "ទៅ រៀបចំខ្លួនទៅ!"។ រៀបចំខ្លួនទៅ គេយកទៅរៀប។ រៀបចំឱ្យយើងចាប់ដៃគ្នា។ សុំបញ្ជាក់ត្រង់ហ្នឹងបន្តិចដែរ ការចាប់ដៃនេះ មិនមែនជាការស្រួលទេ ដោយសារភាគីខាងខ្ញុំ និងខាងបុរសនោះ ពុំមានការទំនាក់ទំនងគ្នា។ ទម្រាំនឹងលូកដៃទៅចាប់គ្នានោះ ញ័រដូចស្អីមកកន្ត្រាក់អ៊ីចឹង រង្គើទាំងតុទៀតនោះ។ ចាប់ដៃគ្នាបានហើយ អីហើយ គេឱ្យនៅជាមួយគ្នារយៈពេល៣ថ្ងៃ។ ថ្ងៃធ្វើការធម្មតា យប់គេឱ្យជួបគ្នា។ តែយប់ទី១ ពេលជួបគ្នានោះ ពុំបាននិយាយអ្វីទាំងអស់ ដោយសារអី? ល្ហបៗហែកជញ្ជាំងខ្ទេចខ្ទីអស់ហើយ ដូចកណ្ដៀរកាត់ជញ្ជាំងអ៊ីចឹង លាន់រសឹបអស់ហើយ។ ណាមួយភ័យខ្លាចគេសម្លាប់ និយាយអីមិនស្រួលខ្លាចគេយកទៅទាំងយប់ អ៊ីចឹងអត់ហ៊ាននិយាយអីទាំងអស់។ គ្រាន់តែគេង ស្ងៀមទៅទាំងអស់គ្នាតែម្ដង មិនហ៊ានកម្រើកខ្លួនតែម្ដង។ បានតែបីយប់ហ្នឹងទេ ដែលគេឱ្យជួបគ្នា គេឱ្យយើងនៅដោយឡែកពីគ្នារហូត។ បុរសនៅមួយចំហៀង នារីនៅមួយចំហៀង ដាំកប្បាស គេយកទៅដាំកប្បាសទៀតហើយ។ រៀបចំហើយហ្នឹង គេនាំទៅដាំកប្បាសនុ៎ងហើយ។ គ្រួសារធ្វើកន្លែងមួយចំហៀង ប្ដីធ្វើកន្លែងមួយចំហៀង ប្រពន្ធធ្វើកន្លែងមួយចំហៀង ដាំកប្បាស អត់ឱ្យជួបគ្នាទេ។

**ស៖** បាទ ចុះពាក់ព័ន្ធនឹងក្រុមគ្រួសារ--

[១៤:៤០:៣៥]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ អរគុណដើមបណ្ដឹងរដ្ឋប្បវេណី។

ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់ រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងដែលគាត់អង្គុយថ្លែងរៀបរាប់អំពីទុក្ខសោកវេទនាចំពោះមុខអង្គជំនុំជម្រះក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១៤:៤១ នាទី ដល់ម៉ោង១៥:០០ នាទី)*

[១៥:០០:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នូវឱកាសដើម្បីបន្តការសួរ ឲ្យដើមបណ្តឹងរៀបរាប់អំពីសេចក្តីថ្លែងទុក្ខសោកវេទនា និងព្យសនកម្មដែលកើតមានចំពោះគាត់។ ហើយសូមសង្ខេបខ្លីទៅបានហើយ ព្រោះប្រើពេលវេលាច្រើនហើយដែរ ហើយទុកលទ្ធភាពជូនភាគីដទៃទៀត ក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះផង។

**លោក ឡោ ជុនធី៖**

បាទ អរគុណលោកប្រធាន។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ខ្ញុំបាទសូមបន្តសំណួរពីរបីសំណួរចុងក្រោយគឺ តើនៅ -- មុននឹងសម្រាកខ្ញុំបានសួរពាក់ព័ន្ធទៅនឹងរឿងក្រុមគ្រួសារ ថាតើក្រុមគ្រួសារអ្នកស្រីហ្នឹងមានការបាត់បង់នៅក្នុងសម័យនោះដូចជាលោកឪពុក ឬអ្នកម្តាយទៅណាដែរ?

[១៥:០២:០០]

**លោកស្រី ចៅ ឡាង៖**

**ឆ៖** ចាស អរគុណលោកមេធាវី។ មុននឹងខ្ញុំនិយាយដល់ឪពុកម្តាយនាងខ្ញុំៗ សូមបញ្ជាក់នៅទំនប់១មករាបន្តិច ចាស សូមៗបញ្ជាក់បន្តិច។ នៅទំនប់១មករានេះ មានថ្ងៃមួយគឺគេដឹកស៊ីម៉ង់ត៍មួយឡាន។ ស៊ីម៉ង់ត៍មួយឡានហ្នឹង គេចាត់កម្លាំងកងចល័ត មាននារីៗ មានយុវជន នាងខ្ញុំក៏ដាក់ឈ្មោះនឹងគេដែរ ថាខ្ញុំសុំទៅដែរ ទៅលីស៊ីម៉ង់ត៍មួយឡានហ្នឹង ដាក់ចុះពីលើឡានហ្នឹង។ អ៊ីចឹងគ្នាប្រហែលជានារីពីរ បុរសបីប៉ុណ្ណឹងទេ។ លីនោះ នាងខ្ញុំលីមិនរួចទេ ប៉ុន្តែបានមិត្តមួយគាត់ជួយយោងដោយសារថា ខ្ញុំហ្នឹងគ្រាន់តែជួយលើក លើកដាក់លើស្មា។ សូមបញ្ជាក់ថា អស់មួយឡានហ្នឹងគឺសល់ពេលបានមួយ

ម៉ោងដែរ ចប់ត្រឹមម៉ោងបួន អ៊ីចឹងម៉ោងប្រាំបានមួយម៉ោងដែរ ពីម៉ោងបួនម៉ោងប្រាំនាងខ្ញុំបានសម្រាក។ ចាសហ្នឹងសូមបញ្ជាក់ នៅទំនប់១មករានេះ គឺលីស៊ីម៉ង់ត៍នេះ គឺកោងអស់ហើយខ្នង កោងសឹងដល់ដីដើម្បីឲ្យរួច ប្រឹងឲ្យរួចស៊ីម៉ង់ត៍មួយបាវៗចាស អស់មួយឡានចាស។

[១៥:០៣:២១]

ឥឡូវចូលដល់លោកមេធាវីបានសួរខ្ញុំពីរឿងឪពុកម្ដាយ។ ឪពុកខ្ញុំគាត់ដើរ ដូចគាត់ដើរបាត់បង់ឪពុកម្ដាយ -- បាត់បង់កូនចៅអ៊ីចឹង មិនឃើញកូនចៅអ៊ីចឹង គាត់ក៏ដើរដល់កំពង់ចាមហ្នឹង គេក៏ចាប់ខ្លួនគាត់យកទៅសម្លាប់ទៅ។ ឯម្ដាយនាងខ្ញុំគាត់រស់នៅពោធិ៍សាត់ជាមួយប្អូនៗ។ គាត់ឈឺ នៅខេត្តពោធិ៍សាត់ហ្នឹងគាត់ឈឺ ឈឺហើយគាត់បានសុំៗៗពេលដែលមុននឹងគាត់ស្លាប់ហ្នឹង គាត់សុំអង្ករដែលគេលាងចោលនោះ។ គាត់ថា "ឲ្យសុំទឹកហ្នឹងមកមិត្តនារី ខ្ញុំយកទៅរម្ងាស់ដើម្បីហូបៗឲ្យមានកម្លាំង"។ ទឹកអង្ករដែលគេលាងចោលនោះ គឺគេមិនឲ្យទេ។ តើជីវិតម្ដាយខ្ញុំស្មើនឹងសត្វអ្វី? ស្មើនឹងអ្វីជីវិតម្ដាយខ្ញុំ? គេមិនឲ្យទឹកអង្ករលាងចោលហ្នឹងទេ រហូតដល់គាត់ដាច់ខ្យល់ស្លាប់។ ខ្ញុំសួរទៅលោក ថ្នាក់ដឹកនាំសម័យខ្មែរក្រហម តើជីវិតម្ដាយខ្ញុំ និងអ្នកទាំងអស់ហ្នឹង តើជីវិតនោះស្មើនឹងស្អី? ស្មើនឹងគោ ក្របី ជ្រូក មាន់ទា គេឲ្យចំណីហូប។ ចុះហេតុអ្វីជីវិតម្ដាយខ្ញុំ ទឹកអង្ករជាត់ចោល គេមិនឲ្យហូប។ រហូតទាមទារស្រែករហូតដល់ស្លាប់។ ហ្នឹងប្រវត្តិឪពុកម្ដាយនាងខ្ញុំ។

បន្ទាប់មកទៀត ដល់ដំណាក់ចុងក្រោយ គេហៅ នៅតាអុង -- នៅបុសខ្នុរ គេហៅឡើងឡានមួយថ្ងៃ នារី២០ យុវជន២០ ទៅកាប់ពោត។ លើកទី១នោះ គឺយកទៅបានឈ្មោះ វ៉ន ឈ្មោះ វ៉ន ហ្នឹងគាត់បានលោតចុះពីលើឡានចូលព្រៃ។ ឥឡូវគាត់នៅប្រទេសបារាំង។ ហេតុការណ៍ដែលយកទៅសម្លាប់រស់បានដល់សព្វថ្ងៃនេះ។ បន្ទាប់មកទៀត យប់ដែលគាត់លោតបានហ្នឹង គាត់រត់មកសួរខ្ញុំថា "អើ!មិត្តអើយ ឃើញប្រពន្ធខ្ញុំទេ?" ខ្ញុំថា "ប្រពន្ធមិត្តឯង ស្អែកឡើងគេយកទៅទៀតហើយ យកទៅកាប់ពោតទៀតហើយ"។ ពេលនោះ មិត្តវ៉ន ហ្នឹងក៏រត់ចូលព្រៃវិញបាត់ទៅ។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ដែរ បានតែបួនឡានទេ ថ្ងៃទី១ និងថ្ងៃទី២ ថ្ងៃទី៣ គឺដល់ឈ្មោះនាងខ្ញុំហើយ។ ប៉ុន្តែថ្ងៃទី៣នេះ គេក៏បញ្ឈប់ គេថាអង្គការដាក់ទិសមកថា ផ្អាកសិនៗ។ អ៊ីចឹងក៏បានរស់មានជីវិតដល់សព្វថ្ងៃនេះ។

[១៥:០៧:១២]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ដោយសារពេលវេលាចំណាយទៅលើ

ពេលវេលារបស់ភាគីផ្សេងទៀតហើយ។ អ៊ីចឹងខាងដើមបណ្ដឹងរដ្ឋប្បវេណី សូមអរគុណលោកស្រី ហើយសូមផ្ទេរវេទិកាជូនលោកប្រធាន ដើម្បីផ្ដល់ដល់ភាគីដទៃទៀត។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដើមបណ្ដឹងរដ្ឋប្បវេណីនេះ ប្រសិនបើមានពាក់ព័ន្ធទៅនឹងស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មដែលកើតមានចំពោះគាត់ ដែលគាត់បានថ្លែងរៀបរាប់កន្លងមកនេះ។ សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ វាំងសង់ វ៉ាយឌ៍។ ខ្ញុំនឹងសួរសំណួរលោកស្រីតាងនាមឲ្យការិយាល័យសហព្រះរាជអាជ្ញា។ សំណួរខ្ញុំ គឺពាក់ព័ន្ធជាពិសេសទៅនឹងទំនប់ ១មករា ក៏ប៉ុន្តែមុននឹងសួរអំពីទំនប់១មករានេះ ខ្ញុំចង់សួរលោកស្រីដោយខ្លី អំពីអ្វីដែលបានកើតឡើងចំពោះបងប្រុស និងប្អូនស្រីរបស់លោកស្រី។ សូមអភ័យទោស គឺប្អូនប្រុសទាំងពីរនាក់របស់លោកស្រី គឺ ថៅ សំណាង និង ថៅ សុវណ្ណារិទ្ធិ។ លោកស្រីអាចរៀបរាប់អំពីរឿងរ៉ាវរបស់គាត់ទាំងពីរនាក់នេះបានទេ?

[១៥:០៩:០០]

**លោកស្រី ថៅ ឡាង៖**

**ឆ៖** ចាស នាងខ្ញុំអាចរៀបរាប់បានចាស។ ប្អូននាងខ្ញុំ ប្រុសទាំងពីរនាក់នេះ គាត់មានជំងឺ គាត់ស្លាប់ដោយជំងឺទេ ពីរនាក់នេះ។ ប្អូនខ្ញុំស្លាប់ដោយជំងឺ ម្ដាយខ្ញុំស្លាប់ដោយដាច់ពោះបាយ គាត់មានជំងឺបន្តិចបន្តួច គាត់ដាច់ខ្យល់ដោយសារអត់បាយ។

**ស៖** សូមអរគុណលោកស្រី។ មុននឹងចូលទៅនិយាយអំពីលក្ខខណ្ឌធ្វើការនៅទំនប់១មករា ខ្ញុំចង់និយាយអំពីការរៀបអាពាហ៍ពិពាហ៍របស់លោកស្រី។ តើត្រឹមត្រូវដែរឬទេ ថាក្រោយពេលលោកស្រីរៀបការហើយ គឺលោកស្រីមិនបានត្រឡប់ទៅធ្វើការនៅទំនប់១មករាវិញទេ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ត្រឹមត្រូវហើយចាស។

**សៈ** អម្បាញ់មិញនេះ លោកស្រីបានឆ្លើយថា គេព្រមានលោកស្រីនៅទំនប់១មករាហ្នឹងថា កុំឲ្យប្រកែក បើគេឲ្យរៀបការ។ លោកស្រីអាចជម្រាបបានទេ អ្នកណាជាអ្នកប្រាប់លោកស្រីបែបហ្នឹង កុំឲ្យប្រកែក ពេលគេឲ្យរៀបការនុ៎ង?

**ផៈ** ចាស គឺមេកង។ មេកង មេក្រុម គាត់ប្រាប់ថា កុំឲ្យប្រកែក។

**សៈ** ពេលដែលលោកស្រីទៅដល់កន្លែងគេឲ្យប្ដេជ្ញា តើអ្នកណាជាអ្នកដឹកនាំរៀបចំពិធីហ្នឹង? ហើយមានការឡើងថ្លែងសុន្ទរកថាអីទេ?

[១៥:១១:០៥]

**ផៈ** ចាស ពេលនោះមានគណៈតំបន់ គាត់ឡើងនិយាយ គណៈតំបន់៤២ គាត់ឡើងនិយាយ។ គាត់បានថ្លែងការណ៍ថា "មិត្តយើងទាំងអស់គ្នា ខំប្រឹងសម្រេចផែនការដែលអង្គការដាក់ចុះ ឲ្យបាន១00ភាគរយ។ ឲ្យបាន១00ភាគរយ អ៊ីចឹងប្រឹងឡើងទាំងអស់គ្នា។ ហើយកង់ប្រវត្តិសាស្ត្រវិលទៅមុខហើយ មិនអាចថយក្រោយបានទេ។ អ៊ីចឹងមានតែយើងទាំងអស់គ្នាហ្នឹងហើយ ដែលសម្រេចបានផែនការរបស់អង្គការដាក់ចុះនោះ"។ ហើយក៏បាននាំគ្នាប្ដេជ្ញាចិត្ត គេឲ្យសម្រេចប្ដេជ្ញាចិត្ត។ គេឲ្យស្រែកប្ដេជ្ញាចិត្តគោរពតាមមាគ៌ារបស់អង្គការ និងសម្រេចបានផែនការឲ្យបាន១00ភាគរយ ហើយនិងស្រែកជយឃោសជយោ! មហាលោតផ្លោះ មហាអស្ចារ្យ។

**សៈ** លោកស្រីនិយាយអំពីភារកិច្ចដែលអង្គការប្រគល់ជូន។ អ៊ីចឹងនៅពេលដែលប្ដេជ្ញាហ្នឹង តើគេចង់ឲ្យប្ដីប្រពន្ធដែលរៀបការជាមួយគ្នាហ្នឹង សម្រេចភារកិច្ចអ្វីខ្លះ ជូនអង្គការ?

**ផៈ** សូមទោសលោកមេធាវី ដោយនាងខ្ញុំមានការភ័ន្តច្រឡំទៅលើទំនប់១មករាទេ។ ការដែលខ្ញុំនិយាយអម្បាញ់មិញនេះ តែរឿងរៀបការនេះ គឺគេឲ្យប្ដេជ្ញាចិត្ត។ ប្ដេជ្ញាចិត្តទៅវិញទៅមក គឺឲ្យប្ដេជ្ញាចិត្តទទួលស្គាល់គ្នាជាគ្រួសារ ជាប្ដីប្រពន្ធ ហើយនិងយើងនឹងខិតខំទាំងអស់គ្នា ដើរតាមមាគ៌ារបស់អង្គការ តាមដែលអ្វីដែលអង្គការដាក់ទិសឲ្យនោះ ដូចជាយើងលើកទំនប់ ជីកប្រឡាយ គឺយើងប្ដេជ្ញាចិត្តនឹងធ្វើតាមឲ្យបានៗគម្រប់តាមផែនការរបស់អង្គការដាក់ចុះតាម ការប្ដេជ្ញាចិត្តរបស់ប្ដីប្រពន្ធ។

[១៥:១៤:២៥]

**សៈ** ខ្ញុំសួរសំណួរបែបនេះ ព្រោះថានៅក្នុងទម្រង់បែបបទព័ត៌មានបន្ថែម ដែលស្ថិតនៅក្នុងសំណុំរឿងគឺ D22/339a ជាភាសាខ្មែរគឺ 00586027, ជាភាសាអង់គ្លេស 01098624។ លោកស្រីបានសរសេរថា៖ "អង្គការប្រាប់ថា ឲ្យរៀបការដើម្បីបង្កើតកូនជូនអង្គការ។" តើលោកស្រីអាចបញ្ជាក់

ពីចម្លើយនេះ ម្តងទៀតបានទេ?

**ឆ៖** ខ្ញុំអត់បាននិយាយទេក្នុងចំណុចហ្នឹង។ អត់បាននិយាយថា ឲ្យបានបង្កើតកូនឲ្យទេ គឺបានប្តេជ្ញាចិត្តតែរឿងការងារទេ ជូនអង្គការតែប៉ុណ្ណោះ។

**ស៖** នៅពេលដែលលោកស្រីនៅទំនប់១មករា គឺលោកស្រីស្ថិតនៅក្នុងកងចល័តតំបន់៤២។ តើគេរៀបចំកងចល័តហ្នឹងយ៉ាងម៉េច ជារបៀបតាមខាងយោធា ឬក៏យ៉ាងម៉េច? លោកស្រីអាចរៀបរាប់បានទេ អំពីរចនាសម្ព័ន្ធនៃកងចល័តតំបន់៤២នេះ?

**ឆ៖** ចាស ខ្ញុំសូម – នាងខ្ញុំសូមបញ្ជាក់ដែរ ខ្ញុំពុំបានដឹងថាកងចល័តហ្នឹង ជាខាងយោធា ឬខាងណានោះទេ។ គ្រាន់តែដឹងថា គេប្រកាសប្រាប់ថា យើងជាកងចល័តតំបន់៤២ ហើយការមកធ្វើទំនប់នេះមានបីតំបន់ តំបន់៤១ តំបន់៤២ និងតំបន់៤៣។

**ស៖** នៅក្នុងកងរបស់លោកស្រី មានគ្នាប៉ុន្មាននាក់? ហើយមានអ្នកណាខ្លះនៅគ្រប់គ្រងលើមេកងរបស់លោកស្រី?

**ឆ៖** ចាស ខ្ញុំបានស្គាល់តែពីររូបទេ គឺមិត្តគឹម មួយហើយនិង មិត្តស្រៀង។ មិត្តស្រៀង ហ្នឹងគឺជាមេកងសម្រាប់ពួកនាងខ្ញុំហើយ។ ហើយ មិត្តស្រៀង នោះគាត់ស្លាប់តាំងពីសម័យនោះហើយដោយសារគាត់ខុសសីលធម៌ នៅតែ មិត្តគឹម ទេ។ មិត្តគឹម នៅរាលស្តី។

[១៥:១៧:៣៤]

**ស៖** មិត្តគឹម ហ្នឹងគាត់មានមុខងារអ្វីដែរ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ដែរ អ្វីដែលខ្ញុំមិនជាច្បាស់ប៉ុន្មានទេ ប៉ុន្តែគ្រាន់តែចងចាំថា មិត្តគឹម នេះគឺជាអ្នកគ្រប់គ្រងចល័តតំបន់៤២។

**ស៖** ដើម្បីឲ្យបានច្បាស់ អម្បាញ់មិញនេះ លោកស្រីបាននិយាយអំពីការងារពេលព្រឹក និងពេលថ្ងៃ គឺលោកស្រីត្រូវងើបតាំងពីម៉ោងបួន ហើយត្រូវធ្វើការរហូតទៅដល់ម៉ោងប្រាំល្ងាច។ ហើយលោកស្រីក៏បានឆ្លើយថា លោកស្រីពេលខ្លះធ្វើការដល់យប់ គឺដល់ម៉ោងដប់ ម៉ោងដប់មួយយប់ ហើយត្រូវនាំឈ្មោះ ឃឹម ផូ។ ពេលយប់ហ្នឹង ក្រៅពីលោកស្រីនាំឈ្មោះអម្បាញ់មិញហ្នឹង តើលោកស្រីមានធ្វើការអ្វីផ្សេងទៀតទេ?

**ឆ៖** ពេលយប់ហ្នឹង គឺនៅពេលចប់ការរែកដីហ្នឹងហើយ គឺនាងខ្ញុំបានបណ្តើរឈ្មោះ ឃឹម ផូ។ ឃឹម ផូ ហ្នឹងបានបណ្តើរគាត់មកកន្លែងសម្រាកហើយ តែពុំបានធ្វើអ្វីទេ ព្រោះអីមកដល់ហ្នឹងវា១សឹង

ថាម៉ោងប្រហាក់ប្រហែលជាកណ្ដាលអធ្រាត្រហើយ។ ខ្ញុំពុំបានធ្វើអ្វីកើតទៀតទេ មានតែដាក់ខ្លួនភ្លឹបទៅ ហើយមិនទាន់ដឹងថាម៉េច ដូចថាអារម្មណ៍មួយថាមិនទាន់បានគេងហ្នឹងឲ្យបានស្ងប់អ្វីមួយផងស្រាប់តែឮកញ្ចែស្រែកទៀតហើយ ស្រែកហើយ។

**ស៖** តើគេឲ្យអ្នកធ្វើការនៅក្នុងកងរបស់លោកស្រីហ្នឹង រែកដីប៉ុន្មានម៉ែត្រគូបក្នុងមួយថ្ងៃ?

**ឆ៖** ចាស នាងខ្ញុំមកពេលឥឡូវនេះ នាងខ្ញុំបាត់ការចងចាំមួយចំនួនហើយ គឺពុំអាចចាំបានទេ ប៉ុន្តែមិនច្បាស់ត្រង់ថា កន្លែងណាៗដែលត្រូវរែកប៉ុន្មានៗទេ គ្រាន់តែចាំថា ២ម៉ែត្រក្នុងម្នាក់ បីនាក់ហ្នឹងគឺធ្វើរួមគ្នា។ រួមគ្នា បើយើងធ្វើអ្នកណាហើយគឺជួយគ្នា ធ្វើម៉េចឲ្យហើយ ឲ្យសម្រេចដែលតាមដែលអ្វីដែលគេដាក់ចុះឲ្យយើងធ្វើ។

[១៥:២០:៥០]

**ស៖** ប្រធានបទនេះ ខ្ញុំមានការចាប់អារម្មណ៍ខ្លាំង ពីព្រោះលោកស្រីបាននិយាយថា លោកស្រីធ្វើជាបុគ្គលិកពេទ្យយោធាក្នុងរបប លន់ នល់។ អ៊ីចឹងមានន័យថា លោកស្រីមានចំណេះដឹងខ្លះផ្នែកពេទ្យ។ តើលោកស្រីអាចជម្រាបអំពីគុណភាពនៃការព្យាបាលដែលបានផ្ដល់ជូនអ្នកជំងឺនៅទំនប់ ១មករាហ្នឹងទេ?

**ឆ៖** ចាស ខ្ញុំបានជួយអាយុជីវិតបានម្នាក់ដែរ។ ពេលនោះ នាងខ្ញុំឃើញមិត្តៗនេះ ឥឡូវនៅទួលទំពូង ខ្ញុំភ្លេចឈ្មោះហើយចាស យូរពេកហើយ។ គាត់ស្គមឈឺ ឈឺស្គមគេងពេទ្យហ្នឹង ហើយឃើញមិត្តនារីដែលគេចាក់ថ្នាំហ្នឹង គេដោតម្ជុលឲ្យគាត់ហ្នឹង រឹតទៅរឹតមក ឡើងបញ្ឈរភ្នែកឡើងលើ។ បញ្ឈរភ្នែកឡើងលើ នាងខ្ញុំដើរកាត់ហ្នឹងភ្លែត ឃើញៗអ៊ីចឹង នាងខ្ញុំមានអារម្មណ៍មួយថា ចូលទៅៗសុំថា "មិត្តអើយមិត្ត ខ្ញុំសុំៗជួយ ឲ្យខ្ញុំសុំជួយៗដោតម្ជុលឲ្យមិត្តហ្នឹង"។ ដល់អស់តម្រិះទៅ រុញម្ជុលហ្នឹងមកឲ្យនាងខ្ញុំ នាងខ្ញុំក៏ដោតបញ្ចូលស៊ីរ៉ូមឲ្យទៅ។ ហើយនាងខ្ញុំបានអង្វរដល់មិត្តនារីពេទ្យហ្នឹងថា "មិត្តអ្នក! អាណិតខ្ញុំ មិត្តកុំរាយការណ៍អី កុំរាយការណ៍ថាខ្ញុំជួយមិត្ត មិត្តកុំរាយការណ៍។ រាយការណ៍ ខ្ញុំស្លាប់ហើយ មិត្តអាណិតខ្ញុំ"។ ពេលនោះនារីហ្នឹងផុតពីការស្លាប់ដែរចាស ឥឡូវរស់នៅទួលទំពូង គាត់លក់មាស ប៉ុន្តែខ្ញុំពុំដែលបានទៅជិតទេ ដោយសារគេមាន ចាស។

**ស៖** តើពេទ្យនៅសម័យនោះ មានទទួលការបណ្ដុះបណ្ដាលត្រឹមត្រូវទេ? ហើយមានថ្នាំពេទ្យគ្រប់គ្រាន់សម្រាប់ព្យាបាលអ្នកជំងឺទេ ជាពិសេសអ្នកជំងឺនៅការដ្ឋានហ្នឹង?

[១៥:២៣:៣២]

**ឆ៖** នេះ បើតាមខ្ញុំដឹងគឺអត់មានទេ អត់មានថ្នាំអីដែលគួរឲ្យចាប់អារម្មណ៍ថា ជាថ្នាំព្យាបាលឲ្យជានោះទេ។ ប៉ុន្តែថៃដនឡូអ្វី នាងខ្ញុំមិនដឹងថាជំងឺរបស់នារីហ្នឹងយ៉ាងម៉េចទេពេលនោះ ដោយឃើញគាត់ស្គមមែនទែន គេយកទៅដាក់ដេកចោលហ្នឹង ហើយឃើញនារីមួយនោះ គាត់ទៅច្របាច់រកសរសៃដៃហ្នឹង ឡើងរឹតទៅរឹតមក ឡើងប៊ិះនឹងដាច់ខ្យល់ បញ្ឈរភ្នែកសឡើងលើ ខ្ញុំក៏ចូលជួបទៅ ប៉ុន្តែ*កុនណេសង់*របស់ខាងពេទ្យហ្នឹងមិនមានអីជាច្បាស់លាស់ ហើយការចេះដឹង តាមគំនិតខ្ញុំយល់គឺ មិនមានអីដែលច្បាស់លាស់នឹងវិជ្ជាពេទ្យទេ ព្រោះអីដោតម្ជុលចង់ងាប់មនុស្សហើយ អត់ចូលផង។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកស្រីនិយាយថាមានមនុស្សបាត់ខ្លួន។ លោកស្រីថានៅក្នុងពេលប្រជុំ នៅពេលដែលគេរិះគន់អ្នកណាម្នាក់ បន្ទាប់មកមានការបាត់ខ្លួន។ នៅពេលដែលលោកស្រីសម្រាក នៅកន្លែងសម្រាកហ្នឹង លោកស្រីមានសង្កេតឃើញថាមានមនុស្សបាត់ខ្លួនទេ? ឬនៅក្នុងអំឡុងពេលធ្វើការហ្នឹង លោកស្រីមានសង្កេតឃើញថា មិត្តរួមការងារលោកស្រីហ្នឹងមានការបាត់ខ្លួនទេ បាត់ជាទៀងទាត់ហ្នឹង?

**ឆ៖** ចាស មានៗការបាត់ខ្លួននេះ នៅពេលធ្វើការស្វ័យទិតៀនគ្នា ផ្ទុះបញ្ចាំងគ្នាទៅវិញទៅមកបាត់បន្តបន្ទាប់ ប៉ុន្តែខ្ញុំបានលេចឮដែរថា មិត្តនោះ មិនសកម្មការងារ ឥឡូវគេយកទៅកសាងបាត់ហើយមិត្តអើយ។ ចំណែកការកសាងរបស់គេនេះ ខ្ញុំមិនដឹងថា ការកសាងហ្នឹង វាយ៉ាងម៉េចទេ បាត់ខ្លួនរហូតតែម្តង មិនឃើញវិលមកវិញ។ ជាបន្តបន្ទាប់ មិនៗកំណត់បានថា យ៉ាងម៉េចនោះទេ គ្រាន់តែថា អ្វីដែលគេមើលឃើញមិនស្រួល គឺគេយកទៅ មិនសកម្ម។

[១៥:២៦:០៧]

**ស៖** សំណួរពីរបីចុងក្រោយ។ នៅការដ្ឋានទំនប់១មករា តើគេតាមដានពេលដែលលោកស្រីបំពេញការងារជាប្រចាំថ្ងៃហ្នឹងទេ មានគេតាមដាន ឃ្លាំមើលទេ?

**ឆ៖** បញ្ហាការឃ្លាំមើលនេះ គឺមិនថាតែទំនប់១មករាទេ ទីកន្លែងណាក៏មានទាំងអស់ការតាម-ដាន។ គ្រប់ពេលគ្រប់វេលា ការនិយាយស្តី ក៏ត្រូវប្រយ័ត្ន ការសម្រាក ក៏ត្រូវប្រយ័ត្ន ការជួបគ្នា ស៊ីញ៉ូគ្នាឬកេះគ្នា គឺគេតាមមើលគ្រប់ពេលគ្រប់វេលា គឺសូម្បីតែរែកទៅ បងនិងប្អូនឃើញគ្នា រែកក្បែរគ្នា មិនហ៊ានហៅគ្នាទេ។ មិនហ៊ានហៅទេ ហើយក៏មិនហ៊ានសុំគេមកជួបគ្នាដែរ អត់ហ៊ានទេគឺដោយឡែកៗតែម្តង។ ហើយជីវិតខ្ញុំនេះ គឺតែលតោលម្នាក់ឯងរហូត ចាស ជីវិតតែលតោលម្នាក់ឯង។

**ស៖** តើមានអ្នកណាម្នាក់ប៉ុនប៉ងរត់គេចចេញពីការដ្ឋានទេ? ហើយលោកស្រីផ្ទាល់នោះ

លោកស្រីធ្លាប់ព្យាយាមរត់គេចចេញទេ ដោយសារតែថាមានការងារវាលំបាកលំបិនពេកនោះ?

**ឆ៖** ខ្ញុំៗធ្លាប់រត់ដែរ។ រត់ហើយហ្នឹង ដោយសារថាខ្ញុំធ្វើលិខិតក្លែងក្លាយ ខ្ញុំជម្រាបដោយត្រង់ចុះ។ គេអនុញ្ញាតឱ្យទៅសហករណ៍ហ្នឹង គឺតែមិត្តនារីខាងចាស់ ជាប្រជាជនចាស់ទេ។ ឯ១៧មេសា គឺគេមិនអនុញ្ញាតការឱ្យសំបុត្រស្នាមទៅទេ។ ពេលនោះខ្ញុំឃើញមិត្តនារីគេបានសំបុត្រមក ខ្ញុំសូមគេមើលហើយ សូមមើលការស៊ីញ៉េរបស់មេ សមមិត្តគឹម ហ្នឹង។ គាត់ចារ គាត់ស៊ីញ៉េហ្នឹង។ អ៊ីចឹងទេ ខ្ញុំលួចធ្វើតាមហើយ ខ្ញុំធ្វើជាលិខិតក្លែងក្លាយហ្នឹង យកទៅៗចូលសហករណ៍ ដើម្បីទៅសុំបានអង្ករដំណើប និងស្ករ។ ខ្ញុំធ្លាប់រត់អ៊ីចឹង ទៅជួបយោធា ទៅបោកយោធាវាហូបបានបាយទៀត ដោយសារលិខិតក្លែងក្លាយរបស់នាងខ្ញុំ។

[១៥:២៨:៥៨]

**ស៖** តើលោកស្រីអាចបញ្ជាក់បានទេ ពេលលោកស្រីក្លែងលិខិតអនុញ្ញាតហ្នឹង គឺនៅពេលណាដែរ មុនពេលសាងសង់ទំនប់ ឬក្នុងពេលសាងសង់ទំនប់១មករា? ហើយពេលដែលលោកស្រីចេញទៅបាត់ហ្នឹង គេមានកត់សម្គាល់ឃើញថា បាត់លោកស្រីពីការដ្ឋានហ្នឹងទេ?

**ឆ៖** ចាស គេសម្គាល់ឃើញថាបាត់ដែរ។ ការដែលរត់របស់នាងខ្ញុំនេះ ក្នុងការដ្ឋានម្ដងម្កាលនេះ គឺៗសង្ឃឹមថា ជីវិតនាងខ្ញុំហ្នឹង មុននិងក្រោយ គឺត្រូវតែស្លាប់។ ហេតុដូច្នេះហើយ បាននាងខ្ញុំត្រូវតែធ្វើបែបនេះមុននឹងស្លាប់។ បើស្លាប់ ក៏ស្លាប់ទៅចុះ ឱ្យតែបានទៅសហករណ៍ យកលិខិតហ្នឹងទៅ មុខតែបានរបបហើយ។ ទៅកន្លែងយោធា ហុចលិខិតហ្នឹងទៅ គឺបានបាយ។ ដល់អ៊ីចឹងប្ដេជ្ញាចិត្តថា ត្រូវតែធ្វើទង្វើទាំងអស់នេះដើម្បីរស់។ រស់មួយពេល វិលទៅវិញមុខតែស្លាប់ហើយ ប៉ុន្តែវិលទៅវិញ គេទិតៀនហើយ។ វិលទៅវិញអត់ប៉ាននៅយូរទេ បានរបបហ្នឹងហើយ គឺវិលទៅវិញ មិនប៉ាននៅយូរ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាងឯល៖**

សូមអរគុណលោកស្រីសាក្សី ដោយសារតែខ្ញុំអស់ពេលហើយ។ លោកប្រធាន ខ្ញុំសូមបញ្ចប់ត្រឹមនេះ។ សូមអរគុណលោកស្រីដើមបណ្ដឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដី ដែលដំបូងនេះ ក្រុមសហមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសអាចតាំងសំណួរពាក់ព័ន្ធនឹងសេចក្ដីថ្លែងរៀបរាប់ទុក្ខសោកវេទនារបស់គាត់កន្លងមកនេះ។ សូមអញ្ជើញលោកក្រុមសហមេធាវីការពារក្ដី

លោក នួន ជា។

[១៥:៣១:០៧]

**លោក លីវ សុវណ្ណា៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម សូមគោរពអង្គសវនាការ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ខ្ញុំបាទឈ្មោះ លីវ សុវណ្ណា ជាមេធាវីក្រុមការពារក្តីរបស់លោក នួន ជា។ ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ជាដំបូងខ្ញុំបាទសូមតាំងសំណួរមួយចំនួន។ ទី១ កាលពីមុនហ្នឹងលោកស្រីបានមានប្រសាសន៍ថា លោកស្រីមានកូនបីនាក់។ អ៊ីចឹងតើកូននីមួយៗហ្នឹងរបស់លោកស្រីហ្នឹងកើតនៅឆ្នាំណាខ្លះបាទ?

**លោក ចៅ ឡាង៖**

**ឆ៖** ចាស អរគុណលោកមេធាវី។ នាងខ្ញុំ កូនទី១កើតឆ្នាំ៨០ កូនទី២ឆ្នាំ៨៣ កូនទី៣ឆ្នាំ៨៥។

**ស៖** អ៊ីចឹងលោកស្រីលែងលះជាមួយប្តីលោកស្រីឆ្នាំណាដែរបាទ?

**ឆ៖** កាលែងលះគ្រួសារនាងខ្ញុំក្នុងឆ្នាំ៨៨, ៨៩។

[១៥:៣២:៥៦]

**ស៖** តើលោកស្រីអាចជម្រាបអង្គសវនាការបានទេ មូលហេតុដែលលោកស្រីលែងលះប្តីលោកស្រី ដោយសារមូលហេតុអីដែរបាទ?

**ឆ៖** ចាស សូមអរគុណលោកមេធាវី។ នាងខ្ញុំលែងលះគ្នានេះ ដោយសារតែការរៀបការដោយបង្ខំសម័យខ្មែរក្រហម គឺឪពុកម្តាយខាងប្តីខ្ញុំហ្នឹង គាត់មិនពេញចិត្ត។ មកសម័យនេះ ឃើញខ្ញុំជាមនុស្សអត់បងអត់ប្អូនអត់ម៉ែឪ អត់មានភូមិករ ដីធ្លី ជាមនុស្ស គេចាត់ទុកថាជាមនុស្សមួយអត់មានគោលដៅ។ អ៊ីចឹងម្តាយក្មេកខ្ញុំ គាត់ៗស្វែងរកចង់ឲ្យកូនគាត់មានគ្រួសារអ្នកដែលមានឪពុកម្តាយ អ្នកដែលមានភូមិដីស្រែចម្ការចាស។ មូលហេតុទាំងអស់នេះហើយធ្វើឲ្យខ្ញុំដាច់ចិត្តលះលែងប្តីរបស់នាងខ្ញុំ។

**ស៖** អ៊ីចឹងបើខ្ញុំសង្ខេបថា លោកស្រីលែងលះដោយសារស្ថានភាពដែលគ្រួសារខាងប្តីលោកស្រីមិនពេញចិត្តនឹងស្ថានភាពជីវភាពរបស់លោកស្រី វាមិនមែនជាការមនោសញ្ចេតនារវាង -- ការលែងលះនេះវាមិនមែនកើតឡើងរវាងមនោសញ្ចេតនារវាងលោកស្រីនិងប្តីរបស់លោកស្រីទេ។ តើអ៊ីចឹងការកត់

សម្គាល់បែបហ្នឹងអាចត្រឹមត្រូវទេបាទ?

[១៥:៣៥:២០]

**ឆ៖** នាងខ្ញុំថា តាមគំនិតរបស់នាងខ្ញុំគឺ ការបែកបាក់នេះដោយសារការរៀបការពីសម័យខ្មែរក្រហម មិនដឹងជាថាត្រឹមត្រូវ ឬមិនត្រឹមត្រូវទេ លោកមេធាវីចាស។

**ស៖** អ៊ំមិញលោកស្រីបានអះអាងថា ការលែងលះដោយសារលោកស្រីខឹងនឹងម្ដាយក្មេករបស់លោកស្រីដែលមើលងាយលោកស្រីដែលថាអត់ ជាកូនកំព្រាស្អីៗនោះ...។ល។ អ៊ីចឹងតើការលែងលះហ្នឹងវាពាក់ព័ន្ធជាមួយមនោសញ្ចេតនាលោកស្រី ជាមួយប្ដីលោកស្រីផ្ទាល់ ឬមួយក៏ដោយសារសង្គមគ្រួសាររបស់ប្ដីលោកស្រី?

**ឆ៖** ចាស សូមបញ្ជាក់ដែរ គឺដើមហេតុមកពីយើង ទី១ យើងរៀបការដោយបង្ខំនេះហើយ។ ទី២ ដោយសារការបែកបាក់ដោយសារក្រុមគ្រួសាររបស់ខាងប្ដី ជាឪពុកម្ដាយ ជាម្ដាយបង្កើតរបស់គាត់ឌុដាន់ ថាយើងជាមនុស្សមួយដែលគ្មានក្បាល គ្មានកន្ទុយអ៊ីចឹងចុះចាស។ ហើយខ្ញុំក៏សម្រេចចិត្តដោយខ្លួនឯង ថាមើលទៅមិនអាចសុខសាន្តបានទេ ខ្ញុំនឹងចុះចេញតែម្ដង។

**ស៖** លោកស្រីថាមូលហេតុលែងលះវាពាក់ព័ន្ធនឹងមួយផ្នែក គឺទាក់ទងនឹងការរៀបការដោយបង្ខំ។ ចុះហេតុអ្វីបានជានៅពេលដែលរំដោះឆ្នាំ១៩៧៩នោះ ថ្ងៃ០៧ មករា ១៩៧៩ភ្លាមនោះ ហេតុអ្វីបានជាលោកស្រីមិនធ្វើការសម្រេចចិត្តលែងលះ?

[១៥:៣៧:៤៨]

**ឆ៖** ចាស នាងខ្ញុំសូមបញ្ជាក់ប្រាប់ទៅលោកមេធាវីវិញដែរ ហេតុអីបានជាពេលនោះ បែកមកហើយ យើងមិនៗធ្វើការសម្រេចចិត្តលែងលះ មិនមែនជាការសម្រេចបានទេ ដោយសារថាពេលនោះមិនទាន់ដឹងថា យើងទៅដល់ទីដៅរបស់យើង ស្រុកទេសរបស់ខាងគាត់នោះ ឬក៏ខាងខ្ញុំនេះវាអាចជួបអ្នកណា ឬក៏យ៉ាងម៉េច ឬក៏ជួបគ្រួសារ ឬក៏ជួបយ៉ាងណានោះ វាពុំទាន់ដឹង។ ណាមួយយើងពុំបានរកកន្លែងទីដៅពិតប្រាកដរបស់គាត់ ពួកគាត់។ នៅពេលដែលយើងរកឃើញភូមិអ្នកលឿងរបស់គាត់នោះ ជាភូមិស្រុកកំណើតរបស់គាត់ យកគាត់ទៅទុកដាក់ទីនោះហើយនោះ បានធ្វើផ្ទះជូនគាត់ហើយនោះ ទើបគាត់មានគំនិតថា ចង់រកប្រពន្ធដែលមានផ្ទះមានសម្បែងមានដីធ្លីមានស្រែចម្ការ ចាសពេលនោះ។ ហើយក៏មិនមែនថា យើងនឹងងាយនឹងសម្រេចចិត្តថា លែងបានទេ ដោយសារថាប្ដីប្រពន្ធនាងខ្ញុំពុំមានអ្វីដែលជាទំនាស់ ឬមានការឈ្លោះទាស់ទែងគ្នានោះទេ ខំប្រឹងតែរកទេ។ តែដោយសារថា ម្ដាយរបស់

គាត់មិនពេញចិត្ត ខ្ញុំតូចចិត្តខ្លួនឯង គឺខ្ញុំចុះចេញ លែងលះពីគាត់ហ្នឹង។

**ស៖** លោកស្រីមានចាំបានទេ តើលោកស្រីធ្លាប់បានបំពេញទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះដែរទេបាទ កន្លងមក?

**ឆ៖** ចាស នាងខ្ញុំធ្លាប់។ ធ្លាប់បំពេញបែបបទជនរងគ្រោះកន្លងមក។

**ស៖** តើព័ត៌មានដែលលោកស្រីបំពេញនោះ ជាព័ត៌មានដែលត្រឹមត្រូវតាមការរៀបរាប់របស់លោកស្រី ឬមួយក៏វាខុសពីការរៀបរាប់របស់លោកស្រី?

**ឆ៖** ចាស ជាការពិតណាស់ អ្វីដែលកើតឡើងនៅក្នុងឯកសារទាំងអស់នោះ គឺជាការរៀបរាប់របស់នាងខ្ញុំហើយ បានចេញជាឯកសារទាំងអស់ហ្នឹងចាស ជាការពិត ព័ត៌មានទាំងអស់នោះ។

[១៥:៤០:៥៦]

**ស៖** ចុះហេតុអ្វីបានជាការបំពេញទម្រង់បែបបទលើកទី១របស់លោក អត់មានព័ត៌មានដែលលោកស្រីថា លោកស្រីត្រូវបានគេបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍?

**ឆ៖** ចាស ព័ត៌មានបង្ខំអាពាហ៍ពិពាហ៍នេះ ដោយសារថា មុនដួនកាលសួរទៅ ពុំចំនូវការរៀបការបង្ខំ។ ចាស ឯកសារក្រោយៗមកទៀត ខ្ញុំបានដាក់ ដោយគាត់សួរថា ចុះគ្រួសារហ្នឹងរៀបការពីពេលណា? ខ្ញុំថារៀបការសម័យខ្មែរក្រហម។ ចាសពីមុន ខ្ញុំពុំបានដឹងដែរ ប៉ុន្តែឯកសារក្រោយៗនេះ ខ្ញុំបានដាក់ហើយ ថាខ្ញុំបានរៀបការដោយបង្ខំពេលនោះ។

**ស៖** កាលពីមុនម៉ោងសម្រាក លោកស្រីបានឆ្លើយថា ថ្លែងទុក្ខថា លោកស្រីធ្វើពេទ្យនៅបាត់ដំបង។ ប៉ុន្តែបើមើលទៅលើទម្រង់បែបបទដែលលោកស្រីបានបំពេញ ដែលលោកស្រីអះអាងថាត្រឹមត្រូវអំមិញនេះ ឯកសារលេខ D22/339, ឯកសារជាភាសាអង់គ្លេសលេខ D22/339/1 ត្រង់ ERN លេខ 00484847 បារាំងគឺឯកសារដូចឯកសាររបស់ភាសាខ្មែរគឺ D22/339, ERN 00846972 តែខ្មែរគឺ ERN លេខ 00484834។ ក្នុងនោះលោកស្រីបាន – ខ្ញុំបាទសូមអាន៖ “មុនឆ្នាំ១៩៧៥ គ្រួសារនាងខ្ញុំ (ចៅ ឡាង) រស់នៅបន្ទាយទាហានប្រសូត្រ ខេត្តស្វាយរៀង ឪពុកឈ្មោះ ចៅ សាង ធ្វើទាហានស័ក្តិ៣ ម្តាយឈ្មោះ ស៊ឹម សុខុម។ នាងខ្ញុំរស់នៅជាមួយនឹងបងប្អូនបួននាក់។ នាងខ្ញុំជាកូនបងទី១ ឈ្មោះ ចៅ ឡាង (ភេទស្រី), កូនទី២ឈ្មោះ ចៅ ស្រី (ភេទស្រី), កូនទី៣ឈ្មោះ ចៅ សំណាង (ភេទប្រុស), កូនទី៤ ចៅ សុវណ្ណារិទ្ធិ (ភេទប្រុស)។ នាងខ្ញុំ (ចៅ ឡាង) ធ្វើជាពេទ្យទាហាន នៅបន្ទាយទាហានប្រសូត្រនោះផងដែរ។” អ៊ីចឹងហេតុអ្វីបានជាចម្លើយរបស់លោកស្រីពេលនេះ ហើយនិងចម្លើយ

នៅក្នុងពីមុនហ្នឹងវាខុសគ្នា? លោកស្រីអាចបញ្ជាក់បានទេ?

[១៥:៤៣:៥៨]

**ឆ៖** ចាស សូមជម្រាបទៅលោកមេធាវី។ ខ្ញុំពុំដែលថា ធ្វើពេទ្យនៅប្រសូត្រទេ។ ខ្ញុំគឺធ្វើការនៅខេត្តសៀមរាប មន្ទីរពេទ្យ ពេលនោះគេអត់ដែលហៅមន្ទីរពេទ្យ៤០៤ទេ គេហៅថា "មន្ទីរពេទ្យកាត់សង់កាត់"។ ចាស ទំនៀមទម្លាប់គេគឺហៅអ៊ីចឹង។ តែដល់ខ្មែរយើង គេហៅមន្ទីរពេទ្យ៤០៤។ ហើយខ្ញុំមិនដែលបានរៀបរាប់ថា នាងខ្ញុំធ្វើការនៅប្រសូត្រទេ។ ពេលនោះ គឺនាងខ្ញុំនៅការសិក្សា នៅការសិក្សានៅឡើយទេ នៅបន្ទាយប្រសូត្រនោះ។ នាងខ្ញុំដល់តែពេលឆ្នាំ៧២ បាននាងខ្ញុំទៅធ្វើការនៅខេត្តសៀមរាប។

**ស៖** បាទ ខ្ញុំចង់បញ្ជាក់បន្ថែម។ លើសពីហ្នឹងទៅទៀត នៅក្នុងឯកសារដដែលហ្នឹង គឺលោកស្រីបានអះអាងថា លោកស្រីបានធ្វើដំណើរជម្លៀសចេញពីខេត្តស្វាយរៀងសំដៅមកក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៧៥។ ប៉ុន្តែមុននេះ គឺលោកស្រីបានអះអាងថា លោកស្រីបែរជាចេញពីវត្តចំប៉ា ស្រុកកៀនស្វាយនេះទៅកាន់ខេត្តស្វាយរៀងវិញ។ ហើយក្នុងឯកសារចាស់ហ្នឹងទៀត លោកស្រីបានរៀបរាប់ថា លោកស្រីជាមួយនឹងបងប្អូន ជាមួយឪពុកម្ដាយរបស់លោកស្រីគឺ ចៅ សាង ហើយនិងប្អូនបីនាក់ និងម្ដាយលោកស្រី ប្រាំនាក់បានធ្វើដំណើរមកភ្នំពេញ។ ចុះហេតុអីបានជាចម្លើយឥឡូវ ហើយនិងចម្លើយពីមុនខុសគ្នាអ៊ីចឹង លោកស្រី?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី ពេជ អង្គ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ដោយសារលោកមេធាវីរបស់លោក នួន ជា បានលើកអំពីផ្នែកនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់ ប៉ុន្តែគាត់ពុំបានផ្ដល់ ERNទេ។ ដូច្នេះខ្ញុំសូមឲ្យគាត់ផ្ដល់ ERN ដើម្បីយើងអាចផ្ទៀងផ្ទាត់អំពីផ្នែកដែលពាក់ព័ន្ធបាន។ សូមអរគុណលោកប្រធាន។

**សួរដោយលោក លើវ សុវណ្ណា៖**

**ស៖** បាទ គឺលេខ ERN ជាភាសាអង់គ្លេស និងភាសាបារាំង គឺដដែល។ ឯ ERN ជាភាសាខ្មែរ គឺមានលេខ 00484835។ ក្នុងហ្នឹង គឺខ្ញុំសូមដកស្រង់៖ "នៅខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានទទួល

ជ័យជម្នះលើរបប លន់ នល់ ទាំងស្រុង។ ពេលនោះនាងខ្ញុំ (ចៅ ឡាង) បាននឹកដល់បណ្តាំរបស់ កូវ៉ាង្គូ ដាមីត ប្រាប់ឲ្យលាក់ប្រវត្តិរូបរបស់ខ្លួន។ នាងខ្ញុំ (ឡាង) និងឪពុក (ចៅ សាង) បានបោះបង់កាំភ្លើង និង លាក់ឯកសណ្ឋានទាហាន ទៅរស់នៅជាមួយប្រជាជន។ លុះបាន៥ថ្ងៃក្រោយមក ទាហានខ្មែរក្រហម ជាច្រើននាក់ស្លៀកពាក់ឯកសណ្ឋានខោខ្មៅ អាវខ្មៅ មិនស្គាល់ឈ្មោះ មកប្រាប់ប្រជាជនថា មិត្តទាំងអស់គ្នា ពេលនេះអង្គការខ្មែរក្រហម ជាអ្នកគ្រប់គ្រងប្រទេស ហើយអង្គការត្រូវឲ្យមិត្តទាំងអស់គ្នាទៅរស់នៅលើទឹកថ្មី ទីជនបទ បង្កបង្កើនផលកសិកម្មដើម្បីសង្គមជាតិរុងរឿង។ ម៉ោងប្រាំបួនព្រឹក ប្រជាជនទាំងអស់បានចេញដំណើរពីស្វាយរៀងសំដៅទៅទីក្រុងភ្នំពេញ ដោយឆ្លងកាត់អ្នកលឿង។"

[១៥:៤៧:៥៤]

ខ្ញុំបាទសូមបន្តដកស្រង់កន្លែងសំខាន់ គឺនៅលេខ ERN ដដែល៖ "ពេលមកដល់ទីក្រុងភ្នំពេញ ប្រជាជនបាននាំគ្នាទៅរកអង្ករសម្រាប់ដាំបាយហូប ក្នុងធ្វើដំណើរតាមផ្លូវ។ ចំណែកឪពុកខ្ញុំ (ចៅ សាង) បានទៅរកស្បៀងសម្រាប់បន្តដំណើរទៅមុខដូចប្រជាជនដទៃដែរ ដោយគាត់ប្រាប់ឲ្យម្តាយ (ស៊ីម សុខុម) នៅមើលកូនៗទាំងបួននាក់ កុំឲ្យបែកគ្នាឲ្យសោះ រង់ចាំឪពុកនៅទីនេះហើយ"។ បាទ អ៊ីចឹងហេតុអីបានជាចម្លើយដែលលោកស្រីឆ្លើយពេលនេះ ថាលោកស្រីបែកពីឪពុកម្តាយ ប៉ុន្តែចម្លើយរបស់លោកស្រីលើកមុនហ្នឹង គឺការរៀបរាប់របស់លោកស្រីលើកមុនហ្នឹងគឺថាលោកស្រី ពេលជម្លៀសមក គឺជួបជុំជាមួយឪពុកម្តាយលោកស្រី?

**លោកស្រី ចៅ ឡាង៖**

**ឆ៖** ចាស នាងខ្ញុំសូមសាឡើងវិញ។ ការលោកមេធាវីសួរមកនេះ ពុំពិតប្រាកដដូចនាងខ្ញុំរៀបរាប់ទេ ដូចនាងខ្ញុំបានរៀបរាប់ពីព្រឹកមកហើយ។ ការដែលនាងខ្ញុំមកលេងកៀនស្វាយមុនចូលឆ្នាំបោះអង្កុញបោះអីនៅទីនោះ នៅភូមិដីឥដ្ឋ ឪពុកខ្ញុំនៅទីក្រុងភ្នំពេញជាមួយម្តាយខ្ញុំ។ នៅពេលដែលជិតបែកហ្នឹង ឪពុកខ្ញុំបានស្កាត់មកជួបនាងខ្ញុំ សូមបញ្ជាក់បន្តិចត្រង់ហ្នឹងចុះ ដោយខ្ញុំពុំបានរាប់រៀបនៅក្នុងឯកសារ ដោយសារមានការភ្លេចខ្លះ។ មកជួបនាងខ្ញុំហ្នឹងគឺមកប្រាប់នាងខ្ញុំថា ទៅបើកលុយនៅធនាគារចេញ ធនាគារពាណិជ្ជកម្មខ្មែរ បើកចេញឲ្យអស់ទៅ ព្រោះអីយើងមិនអាចទុកបានទេ ហ្នឹងមុនចូលឆ្នាំ--

[១៥:៥០:១២]

**សៈ** សូមទោសលោកស្រី សូមកាត់ប្រសាសន៍លោកស្រី។ សំណួរខ្ញុំវាមិនមែនរឿងហ្នឹងទេ គឺរឿងដែលជម្លៀសដែលលោកស្រីអះអាងថា លោកស្រីបែកពីឪពុកម្តាយទាំងអស់ ប៉ុន្តែនៅក្នុងឯកសារ

របស់លោកស្រី គឺបានបញ្ជាក់ថា លោកស្រីធ្វើដំណើរពេលជម្លៀសគឺជួបជុំជាមួយឪពុកម្ដាយ។ ហើយ ខ្ញុំសូមបន្តសំណួរថ្មីរបស់ខ្ញុំ គឺនៅអំមិញនេះ លោកស្រីបានមានប្រសាសន៍ថា ឪពុកលោកស្រីគឺដើរទៅ ដល់កំពង់ចាម ហើយគេចាប់សម្លាប់ទៅ។ ឯម្ដាយលោកស្រី គឺបែកទៅហ្នឹងគឺជាមួយប្អូនៗលោកស្រីគឺ ជម្លៀសទៅខេត្តពោធិ៍សាត់។ ប៉ុន្តែតាមឯកសារដដែលលេខ ERN ដដែលទាំងបីភាសាហ្នឹង គឺលោកស្រី បានអះអាងថា ខ្ញុំសូមដកស្រង់៖ "នាងខ្ញុំ (ចៅ ឡាង) និងម្ដាយ (ស៊ឹម សុខុម) ធ្វើដំណើរទៅមុខយឺតៗ ដោយរង់ចាំក្រែងឪពុក (ចៅ សាង) មកតាមក្រោយទាន់។ តែទោះបីជាយ៉ាងណា មិនឃើញឪពុកមក ក្រោយទាន់ពួកយើងខ្ញុំទេ។ ឪពុក (ចៅ សាង) បាត់ខ្លួន ប្រហែលជាទាហានខ្មែរក្រហមចាប់ដោយគាត់ មានដំណើររបាំងពាក់ និងមានស្នាមត្រូវគ្រាប់នៅជើង។ ការធ្វើដំណើរទាំងថ្ងៃទាំងយប់អស់រយៈពេល ១០ថ្ងៃ បានទៅដល់ស្រុកចំការលើ ខេត្តកំពង់ចាម។ ពេលទៅដល់ស្រុកចំការលើ អង្គការខ្មែរក្រហម បានបែងចែកប្រជាជនរស់នៅតាមភូមិ ឃុំផ្សេងដើម្បីងាយស្រួលគ្រប់គ្រង និងគ្រួសារខ្ញុំ (ចៅ ឡាង) ទាំងប្រាំនាក់ត្រូវបានអង្គការឲ្យស្នាក់នៅភូមិអូរកន្សែង ឃុំតាប្រុក ស្រុកចំការលើ ខេត្តកំពង់ចាម។" អ៊ីចឹងសំណួររបស់ខ្ញុំសួរថាតើហេតុអីបានជាអង្គហេតុដែលនៅក្នុងចម្លើយលោកស្រីពីមុន ហើយនិងអង្គ ហេតុនៅពេលលោកស្រីបានរៀបរាប់នៅថ្លែងទុក្ខនៅថ្ងៃនេះ គឺខុសគ្នាទាំងស្រុងបែបនេះបាទ?

[១៥:៥២:១២]

**ឆ៖** ចាស ខ្ញុំសូមជម្រាបដែរ ខ្ញុំពុំដែលបាននិយាយទេ ពីរឿងថាជួបជុំឪពុកម្ដាយទៅជាមួយគ្នា ឬក៏បែកតែឪពុកនោះ ខ្ញុំពុំបាននិយាយទេ។ គឺនៅចងចាំច្បាស់ណាស់ថា ឪពុកមានពេលមួយជួប ជួប ហើយគាត់វិលទៅវិញ ចាសវិលទៅវិញ ហើយបែកគ្នាទៀត បែកទាំងអស់ ឪពុកបែកដោយឡែក ម្ដាយ បែកដោយឡែក។

**លោក លីវ សុវណ្ណា៖**

បាទ ខ្ញុំបាទសូមអរគុណលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំបាទ សូមអស់សំណួរ អរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ខ្ញុំសូមចោទសំណួរមួយចំនួន សូមការបំភ្លឺពីលោកស្រីទាក់ទងនឹងចម្លើយរបស់លោកស្រី។ ហើយជាបឋម ខ្ញុំចាប់អារម្មណ៍ទៅនឹងរយៈពេលដែលលោកស្រីធ្វើការនៅទំនប់១មករា។ លោកស្រីបាននិយាយអំពីហេតុការណ៍ជាមួយនឹងអ្នកធ្វើការជាមួយលោកស្រី ដែលមានជំងឺខ្វាក់មាន់។ លោកស្រីពន្យល់ថា ដោយសារតែមានការអន្តរាគមន៍របស់អ្នកគ្រប់គ្រងបីនាក់ដែលយើងហ្នឹងហើយ បានជាយើងបានបញ្ជាឲ្យគាត់ហ្នឹង បញ្ជាឲ្យគាត់ឈប់ធ្វើការពេលយប់។ តើខ្ញុំរៀបរាប់នេះ ត្រឹមត្រូវតាមដែលលោកស្រីបាននិយាយដែរឬទេ?

[១៥:៥៤:០៧]

**លោកស្រី ចៅ ឡាង៖**

**ឆ៖** ចាស ពិតណាស់លោកមេធាវី។

**ស៖** តើលោកស្រីមានចាំអ្នកគ្រប់គ្រងទាំងបីនាក់ហ្នឹងដែលធ្វើអន្តរាគមន៍ហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំចាំបានថាបីរូបនោះ គាត់គ្រាន់តែដឹងថាជាអ្នកគ្រប់គ្រងជាន់ខ្ពស់ ព្រោះអីសញ្ញាមួយដែលគួរឲ្យដឹងនោះ គឺគាត់បង់កកន្សែងស្ទូត្រ។ សម័យនោះ អ្នកដែលបង់កកន្សែងស្ទូត្រ គឺមានតួនាទីខ្ពស់ណាស់ ប៉ុន្តែឈ្មោះនាងខ្ញុំអត់បានស្គាល់ទេ។

**ស៖** តើលោកស្រីស្គាល់ឈ្មោះពួកគាត់ទេ?

**ឆ៖** ចាស នាងខ្ញុំបានបញ្ជាក់ហើយ អម្បាញ់មិញនេះ គឺនាងខ្ញុំអត់បានស្គាល់ឈ្មោះទេ។ គ្រាន់តែថាដឹងថាជាអ្នកគ្រប់គ្រងជាន់ខ្ពស់ ដោយសារថា សម្គាល់ទៅលើ និយាយទៅអ្នកទាំងអស់នោះសម្គាល់ដូចៗគ្នា ថាឲ្យតែបង់កកន្សែងស្ទូត្រ ក្រមា កន្សែងស្ទូត្រសុទ្ធហ្នឹងគឺមិនធម្មតាទេ គឺជាមន្ត្រីរបស់គេជាន់ខ្ពស់ហើយ។

**ស៖** តើលោកស្រីដឹងថា ពួកគាត់ហ្នឹងមានតំណែងនៅថ្នាក់ស្រុក ថ្នាក់ឃុំ ឬក៏ថ្នាក់ណាផ្សេងទៀតទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ដែរ បើតាមខ្ញុំដឹងឮសួរ ប៉ុន្តែមិនជាជាក់លាក់ប៉ុន្មានទេ ប៉ុន្តែគ្រាន់តែខ្ញុំឮច្បាស់មេក្រុមមេកងហ្នឹងគាត់ថា “នែ! ថ្ងៃនេះមានគណៈមជ្ឈិមគាត់ចុះមក”។ តែនាងខ្ញុំអត់បានស្គាល់ទេ អត់បានស្គាល់ថា អ្នកនោះជាអ្នកណាទេ។ គ្រាន់ថាឃើញមកមែន ឃើញមកបីរូប។

[១៥:៥៦:៥៧]

**ស៖** តើលោកស្រីបានឃើញអ្នកដឹកនាំជាន់ខ្ពស់ហ្នឹងច្រើនដងដែរឬទេ នៅពេលដែលលោកស្រីធ្វើការនៅទំនប់១មករាហ្នឹង?

**ឆ៖** ចាស នាងខ្ញុំសូមបញ្ជាក់ដែរ ការឃើញរបស់នាងខ្ញុំតែម្តងហ្នឹងទេ បានពន្លែងអ្នកខ្វាក់មាន់ឲ្យទៅជាន់វា។

**ស៖** តើនៅសម័យនោះ លោកស្រីស្គាល់ ប៉ុល ពត ដែរឬទេនៅពេលដែលលោកស្រីធ្វើការនៅទំនប់១មករាហ្នឹង?

**ឆ៖** ខ្ញុំអត់បានស្គាល់គាត់ទេ ប៉ុន្តែគ្រាន់តែឮៗគេថា ថាប៉ុល ពតៗ មកទីនេះ ប៉ុន្តែខ្ញុំអត់បានស្គាល់ទេ។ ចាស សូមជម្រាប អត់បានស្គាល់។

**ស៖** លោកស្រីខ្ញុំនិយាយយ៉ាងដូច្នេះ ពីព្រោះថានៅក្នុងចម្លើយរបស់លោកស្រីគឺឯកសារ E3 – គឺថាទម្រង់បែបបទជនរងគ្រោះនោះគឺឯកសារ E3/31927.4.13*(ស៊ីក)* ជាភាសាបារាំងគឺ -- ជាភាសាខ្មែរគឺ 008--

**អ្នកបកប្រែ៖**

បាទ លោកប្រធាន សុំឲ្យលោកមេធាវីផ្តល់លេខ ERN ម្តងទៀត លោកប្រធាន។

[១៥:៥៨:៤៦]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ឥឡូវខ្ញុំឲ្យលេខ ERN ម្តងទៀតជាភាសាខ្មែរគឺ 00484836, ជាភាសាអង់គ្លេស មិនទាន់មានការបកប្រែឯកសារនេះនៅឡើយទេ។ យើងនឹង -- ក៏ប៉ុន្តែខ្លឹមសារនេះមាននៅក្នុងឯកសារ E319/27.4.13 ផងដែរ ហើយជាភាសាអង់គ្លេសគឺ 01098616។ លោកស្រីបាននិយាយដូច្នេះក្នុងសំណៅជាភាសាបារាំងដែលខ្ញុំមាន៖ “រាល់ខែ ប៉ុល ពត ទៅការដ្ឋាននោះម្តង ឬពីរដង ដោយគាត់ប្រាប់ឲ្យយើងខំប្រឹងធ្វើការដើម្បីប្រទេសយើង។” អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះថា តើនៅពេលដែលលោកស្រីធ្វើការនៅទំនប់១មករានោះ រាល់ខែ ប៉ុល ពត តែងតែលើកទឹកចិត្តលោកស្រីឲ្យធ្វើការដើម្បីកសាងជាតិដែរឬទេ កសាងប្រទេសដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកមេធាវីដែរ។ ទោះបីជាលោក ប៉ុល ពត គាត់ទៅទីនោះ យ៉ាងញឹកក៏ដោយ មិនញឹកក៏ដោយ គឺនាងខ្ញុំអត់បានស្គាល់គាត់ ដូច្នេះខ្ញុំពុំដឹងថា គាត់មកប៉ុន្មានដងនោះទេ។ គ្រាន់តែ

បានឮថា ឲ្យតាមរយៈរបស់គណៈតំបន់ និងៗមេកងដែលលើកឡើងទេ គាត់ថាឲ្យខំប្រឹងប្រែង ដោយមានអង្គការធំៗគាត់ចុះមកមើល។ ហើយគណៈតំបន់ហ្នឹង គាត់បើកប្រជុំក្នុងកងចល័តតំបន់៤២ហ្នឹង គឺឲ្យយើងប្ដេជ្ញាចិត្តដូចបានរៀបរាប់ពីព្រឹកមិញហើយ។

**ស៖** សំណួរខ្ញុំនោះ ច្បាស់លាស់ជាងហ្នឹងអម្បាញ់មិញនេះ។ លោកស្រីបាននិយាយ នៅពេលដែលលោកស្រីបំពេញទម្រង់បែបបទលោកស្រី លោកស្រីបាននិយាយថា ប៉ុល ពត មកទំនប់១មករាហ្នឹងរាល់ខែ។

[១៦:០១:៣៣]

**ឆ៖** ចាស សូមជម្រាបទៅលោកមេធាវីវិញ ខ្ញុំបាននិយាយថា ប្រហាក់ប្រហែលជាបីដងទេ នៅពេលដែលខ្ញុំលើកទំនប់នោះ។ ហើយខ្ញុំពុំបានស្គាល់ថា ប៉ុល ពត យ៉ាងម៉េចនោះទេ គ្រាន់តែមេកងថា នោះ ប៉ុល ពត។ គ្រាន់ឮគេថាអ៊ីចឹងទេ តែខ្ញុំអត់ស្គាល់ថាមួយណាទេ ហើយក៏ខ្ញុំមិនដឹងថា ប៉ុល ពត ពិតប្រាកដ ឬមិនពិតប្រាកដ ខ្ញុំអត់បានដឹងទេ។ ហើយគ្រាន់តែថា ដឹងថាជាមន្ត្រីជាន់ខ្ពស់មកពីមជ្ឈិម ឬក៏ឋានៈតំបន់ គាត់បើកការប្រជុំ។ ហើយបើៗតាមខ្ញុំចងចាំ ឬក៏ភ្លេចមួយចំនួន តាមចងចាំពិតប្រាកដនោះ គឺមានតែថ្នាក់តំបន់ទេ ដែលគាត់ប្រជុំញឹកញាប់។ តែឋានៈជាន់ខ្ពស់ដូចលោក ប៉ុល ពត នោះគឺគាត់បានមកទស្សនកិច្ចអីអ៊ីចឹងម្ដងម្កាល អ៊ីចឹងខ្ញុំពុំបានទទួលអ្វី ពាក្យសម្ដីអ្វីពីគាត់បានច្បាស់លាស់ទេ អត់មាន។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ នៅពេលដែលលោកស្រីបំពេញទម្រង់បែបបទរបស់លោកស្រីហ្នឹង គឺលោកស្រីបាននិយាយថា ប្រហែលជា ប៉ុល ពត អាចមកដែរ។ ក៏ប៉ុន្តែបើតាមអ្វីដែលលោកឆ្លើយនៅក្នុងចម្លើយហ្នឹង គឺលោកស្រីឆ្លើយថា លោកស្រីបានឃើញគាត់ទៀតផង។ អ៊ីចឹងនិយាយសង្ខេបឡើងវិញ គឺបានន័យថា លោកស្រីគ្រាន់តែឆ្លើយថា ប្រហែលជា ប៉ុល ពត អាចមកដែរទេ ត្រឹមតែប៉ុណ្ណឹងទេ ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស ខ្ញុំសូមបញ្ជាក់ឡើងវិញ។ ពាក្យដែលថា ខ្ញុំដឹងថា ប៉ុល ពត មកហ្នឹង ដោយសារមេក្រុមរបស់នាងខ្ញុំ និងមេកង គាត់ថាថ្ងៃនេះមាន ប៉ុល ពត មកហើយ គាត់ជាមន្ត្រីជាន់ខ្ពស់។ ចាស ឲ្យខ្ញុំស្គាល់ថា នោះជាពិតប្រាកដជា ប៉ុល ពត នោះគឺខ្ញុំអត់បានស្គាល់ទេ ចាសគ្រាន់តែប៉ុណ្ណឹងទេ។ គ្រាន់តែឮគេថា ឮមេកង ឮមេក្រុមគាត់បានប្រាប់ថាមាន ប៉ុល ពត គាត់មក។ គ្រាន់តែឮតាមរយៈអ៊ីចឹងទេ បើឲ្យខ្ញុំស្គាល់ឈ្មោះ ឬក៏ឲ្យស្គាល់មុខមាត់នោះ គឺខ្ញុំអត់បានស្គាល់ទេ។

[១៦:០៤:២៨]

**ស៖** សូមអរគុណ។ អ៊ីចឹងគឺថា លោកស្រីនិយាយថា គាត់ទៅទស្សនកិច្ចតែម្តងនោះទេ។ ខ្ញុំៗចង់យល់ ថាម៉េចក៏ក្នុងចម្លើយរបស់លោកស្រីហ្នឹង ទម្រង់បែបបទលោកស្រីនេះ ជាភាសាបារាំង ជាភាសាខ្មែរហ្នឹង មានសរសេរថា មួយ ឬពីរដង ប៉ុល ពត ទៅការដ្ឋានហ្នឹង -- ម្តងឬពីរដងមួយខែឯណោះ។ អ៊ីចឹងខ្ញុំសួរលោកស្រីថា តើលោកស្រីឃើញគាត់មកហ្នឹង តែម្តងទេ តែប៉ុណ្ណឹងទេឬ ម្តងពីរដងមួយខែ ប៉ុណ្ណឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស ខ្ញុំសូមបញ្ជាក់ឡើងវិញ។ ទំនប់១មករានេះ នៅពេលដែលខ្ញុំទៅធ្វើការទីនោះ ខ្ញុំពុំបានធ្វើជាប់លាប់ដូចកងចល័តដទៃទៀតទេ។ អ៊ីចឹងខ្ញុំដឹងថា ប៉ុល ពត មកនេះគឺបើតាមខ្ញុំគេប្រាប់នោះ តែខ្ញុំឃើញជាក់លាក់ពិតប្រាកដនោះតែម្តងទេ។ តែបើតាមគេប្រាប់នោះវាមាន ពីរដងទៅបីដងនោះ ប៉ុន្តែខ្ញុំបានឃើញតែម្តងទេ ដែលគេថា ប៉ុល ពត នោះដែលអង្គុយបីនាក់នោះ ដូចខ្ញុំបានជម្រាបហើយ។

**ស៖** សូមអរគុណដែលបានឆ្លើយបំភ្លឺនេះ។ ឥឡូវខ្ញុំសូមការបំភ្លឺទាក់ទងទៅនឹងអ្វីដែលលោកស្រីបានឆ្លើយ។ នៅពេលដំបូងដែលលោកស្រីផ្តល់សក្ខីកម្មនៅទីនេះ លោកស្រីដូចជាបាននិយាយអំពីការងាររបស់លោកដែលធ្វើការជាមួយស្ត្រីម្នាក់ ដែលជនជាតិហ្វីលីពីន ហើយស្រាប់តែក្រោយមកទៀតដូចជា ខ្ញុំយល់ ស្តាប់ឮជាភាសាបារាំងនោះឮថា ម្នាក់នោះធ្វើការដូចជាសក្តិ៥ ទាហានស័ក្តិ៥ ហើយតួនាទីរបស់គាត់អ្នកបំផ្ទុះគ្រឿងផ្ទុះទៅវិញ។ អ៊ីចឹងតើលោកស្រីអាចបំភ្លឺបានទេ ត្រង់ចំណុចនេះ?

[១៦:០៦:៤៩]

**ឆ៖** ចាស ខ្ញុំអាចរៀបរាប់ជូនមេធាវីបាន។ លោក កូវ៉ាដូ ដាមីត គាត់ពាក់ស័ក្តិ៥ គាត់ជាអ្នកទទួលៗបន្ទុកទៅលើគ្រាប់ គ្រាប់គ្រប់ប្រភេទដាក់ឃ្លាំង គឺគាត់ចាំត្រួតពិនិត្យមើល ដែលគេដាក់ចុះពីកប៉ាល់ហោះ ដឹកជញ្ជូនចូលឃ្លាំង គាត់ត្រួតពិនិត្យប៉ុណ្ណឹង។

**ស៖** ឥឡូវខ្ញុំចង់សួរបញ្ជាក់ម្តងទៀត គាត់ហ្នឹងជាបុរស ឬក៏ស្ត្រី?

**ឆ៖** ចាស សូមជម្រាបផងដែរ ឲ្យច្បាស់លាស់ជាងនេះ ដើម្បីកុំឲ្យមានការសង្ស័យ។ គាត់ជាបុរសទេ កាត់ពាក់សក្តិ៥ អាយុគាត់កាលដែលជួបខ្ញុំហ្នឹង គាត់អាយុប្រហែលជា៥១, ៥២ ប៉ុន្តែគាត់ហ្នឹងធ្វើការ ប៊ុយរ៉ូរបស់គាត់ហ្នឹងក្បែរកន្លែងខ្ញុំធ្វើការៗ។ ហើយខ្ញុំដឹងនេះ តាមរយៈរបស់លោកៗស័ក្តិ៣ ប៉េង យ៉ែម ធ្វើការជាមួយគាត់ហ្នឹង។ លោកស័ក្តិ៣ ប៉េង យ៉ែម ហ្នឹងគាត់ណែនាំខ្ញុំជាកូនធម៌របស់គាត់ ដូច្នេះខ្ញុំស្គាល់តាមរយៈហ្នឹង។

**ស៖** ខ្ញុំលើកបញ្ហានេះ ឡើងដោយសារថានៅក្នុងចម្លើយរបស់លោកស្រី គឺឯកសារ E3/5965 ERN ជាភាសាខ្មែរគឺ 00484834 ជាភាសាអង់គ្លេសហ្នឹងគឺនៅក្នុងឯកសារ E319/27.4.13 ERN បន្ទាប់ទៀតនោះគឺថា 01098615 ជាអកុសលមិនទាន់មានការបកប្រែជាភាសាបារាំងនោះទេ។ ខ្ញុំសូមអាននូវអ្វីដែលលោកស្រីបានឆ្លើយនៅក្នុងទម្រង់បែបបទរបស់លោកស្រី ជាភាសាអង់គ្លេស៖ "ខ្ញុំដើរជាមួយនឹងគ្រូពេទ្យជនជាតិហ្វីលីពីនស្ត្រីម្នាក់ដែលមានឈ្មោះ កូរ៉ាដូ ដាមីត នៅក្នុងខែមីនា ១៩៧៥ ដោយសារតែមានការបះបោរនៅក្នុងប្រទេស កូរ៉ាដូ ដាមីត ហ្នឹងក៏បានទៅត្រឡប់ទៅប្រទេសហ្វីលីពីនវិញទៅ។" បញ្ចប់ការដកស្រង់។ ដូច្នេះសំណួរខ្ញុំៗចង់ដឹងថា តើបុគ្គលរូបហ្នឹងដែលមកពីហ្វីលីពីនហ្នឹងពិតជាស័ក្តិ៥ ទទួលបន្ទុកខាងគ្រឿងរំសេវ ឬក៏ជាអ្នកដែលលោកស្រីធ្វើការជាមួយនៅពេលនោះ? គេនិយាយថា បកប្រែជាភាសាខ្មែរអំមិញនេះ ប្រហែលជាខុស។ សំណួរខ្ញុំចង់ដឹងថាតើអ្នកហ្វីលីពីនហ្នឹងជនជាតិហ្វីលីពីនហ្នឹង ជាអ្នកទទួលបន្ទុកខាងដឹកគ្រឿងរំសេវហ្នឹង ឬក៏ជាពេទ្យស្ត្រីជាពេទ្យម្នាក់នោះដែលធ្វើការនៅមន្ទីរពេទ្យយោធា?

[១៦:១១:២៥]

**ឆ៖** ចាស ខ្ញុំសូមបញ្ជាក់ជូនទៅវិញឲ្យច្បាស់។ នាងខ្ញុំជាបុគ្គលិកពេទ្យនៅពេទ្យ៤០៤ ឯលោក កូរ៉ាដូ ដាមីត ហ្នឹងគាត់ជាអ្នកគ្រប់គ្រងគ្រាប់រំសេវដែលចេញពីប្រទេសអាមេរិក យកមកដាក់ឃ្លាំងហ្នឹង គាត់ចាំតែមើលការខុសត្រូវ គឺគាត់ជាបុរសទេ ហើយការងារនេះ ប៉ុយរ៉ូរបស់គាត់ហ្នឹង វានៅក្បែរនឹងមន្ទីរពេទ្យ ម្ខាងម្នាក់។ ម្ខាងជាកន្លែងទីតាំងដែលគាត់ធ្វើការ ម្ខាងជាមន្ទីរពេទ្យ។ តែគាត់ហ្នឹងជាពួកម៉ាករបស់ប៉ាខ្ញុំ ដែលជាប៉ាធម៌របស់ខ្ញុំហ្នឹងឈ្មោះ ប៉េង យ៉ែម ស័ក្តិ៣។ អ៊ីចឹងកុំមានការភ័ន្តច្រឡំថា គាត់ជាពេទ្យ មិនមែនទេ ដូចបានបញ្ជាក់ហើយ គាត់ស័ក្តិ៥ គឺគាត់គ្រប់គ្រងផ្នែកខាងគ្រាប់គ្រប់ប្រភេទដាក់ចូលឃ្លាំង។

**ស៖** តើលោកស្រីយល់ស្របដែរឬទេថា រយៈពេលហ្នឹងៗប្រហែលជានៅឆ្នាំមួយពាន់ -- នៅត្រីមាសទី១នៃឆ្នាំ១៩៧៥ អ៊ីចឹងមែនទេ ហេតុការណ៍ហ្នឹងគឺកើតឡើងនៅពេលហ្នឹង?

**ឆ៖** ចាស។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំមើលឃើញថាពេលវេលាកាន់តែទៅមុខហើយ។ ខ្ញុំឃើញម៉ោងប្រហែលជាបួនដប់ប្រាំនាទីហើយ។ អ៊ីចឹងខ្ញុំចង់សួរលោកប្រធានថា តើលោកប្រធានអាចអនុញ្ញាតឲ្យខ្ញុំសួរបន្តទៀត

ប្រហែលជាប្រាំនាទីអីទៀតបានទេ ពីព្រោះចៀសវាងកុំឲ្យបន្តសួរស្អែកទៀតលោកប្រធាន?

[១៦:១៣:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយរដ្ឋបាលជូនព័ត៌មានទៅ -- ខាងក្រឡាបញ្ជីជូនព័ត៌មាននេះទៅខាងអង្គភាពដឹកជញ្ជូននៃការិយាល័យរដ្ឋបាលផង ដើម្បីជ្រាបជាព័ត៌មាន និងការពន្យឺត -- ពន្យារនៃការដឹកជញ្ជូនមន្ត្រីរាជការ -- មន្ត្រីបុគ្គលិកត្រឡប់ទៅទីក្រុងភ្នំពេញវិញផង។

អញ្ជើញ! អង្គជំនុំជម្រះអនុញ្ញាត។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមអរគុណលោកប្រធាន ខ្ញុំនឹងសួរដោយសង្ខេប។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសូមចូលមកនិយាយអំពីរយៈពេលដែលលោកស្រីធ្វើការនៅទំនប់១មករា លោកស្រីបាននិយាយថា លោកស្រីធ្លាក់ខ្លួនឈឺ គឺថាគ្រុនក្តៅ ហើយលោកស្រីក៏បាននិយាយផងដែរអំពីមិត្ត ការជួយដល់មិត្តលោកស្រីម្នាក់ ដែលគាត់ខ្វាក់មាន់ ដែលលោកស្រីបាននិយាយថា កាលណោះដោយប្រើស្លឹកគយកដាក់ឲ្យផឹក។ លោកស្រីធ្លាប់បានរៀនពេទ្យ អ៊ីចឹងខ្ញុំចង់សួរលោកស្រីថា តើនៅសម័យនោះការប្រើថ្នាំខ្មែរហ្នឹង គេប្រើញឹកញាប់ទេ មនុស្សភាគច្រើនប្រើទេ?

**លោកស្រី ចៅ ឡាង៖**

**ឆ៖** ចាស សូមបញ្ជាក់ទៅវិញដែរ អស់ជម្រើស ពេលនោះអស់ជម្រើស គ្មានអ្វីដែលត្រូវជ្រើសរើសទេ ព្រោះអីអត់មានថ្នាំពេទ្យពិតប្រាកដ មានតែថ្នាំស្លអាចម៍ទន្សាយ។ អ៊ីចឹងទេ បើតាមយើងជាអ្នកធ្លាប់ធ្វើពេទ្យនោះ យើងមិនអាចជឿទេ ប៉ុន្តែអស់ជម្រើស ត្រូវតែពិសោធមើល ថាតើយើងអាចធូរស្រាលបានដែរអត់? អ៊ីចឹងខ្ញុំខិតខំហូបស្លឹកគនេះ ទឹកគនេះ វាបានជួយ ជួយការគ្រជាក់ហ្នឹងបានមួយចំនួន ហើយនិងបានអាស្ពារីនមួយគ្រាប់ រួមផ្សំមកបាន ទើបបានជំងឺខ្ញុំជាសះស្បើយ។ អានេះបើទោះបីជឿ មិនជឿ ក៏ត្រូវតែជឿដែរ ដោយសារថាការក្តៅខ្លាំងមកសម័យនេះ យើងពិបាកនឹងព្យាបាលណាស់ថ្នាំពេទ្យ។ តើហេតុអីថ្នាំមួយគ្រាប់សោះ យើងជាបាន ដោយសារអ្វី? អានេះតាមខ្ញុំយល់ខ្លួនឯងគឺដោយសារស្លឹកគនោះ ជួយមួយចំនួនដែរ មួយចំនួន។

**ស៖** បើតាមអ្វីដែលលោកស្រីនិយាយអម្បាញ់មិញនេះ លោកស្រី បើតាមខ្ញុំយល់នោះ គឺថាជា

ដំបូងយល់ថាដូចជាថ្នាំបុរាណទេ ហើយបន្ទាប់មកទៀត លោកស្រីបាននិយាយអាស្ពារីន ហើយលោកស្រីទទួលស្គាល់ថា ស្គាល់ថ្នាំអាស្ពារីនហ្នឹង។ អ៊ីចឹងខ្ញុំសួរលោកស្រីថា អ្នកណាជាអ្នកឲ្យអាស្ពារីនហ្នឹងទៅលោកស្រី? តើជាពេទ្យនៅទំនប់១មករាហ្នឹង ឬក៏ជាអ្នកណាផ្សេងទៀត?

[១៦:១៧:០៧]

**ឆ៖** ចាស សូមអរគុណ។ ដោយសារថា ពេទ្យហ្នឹង គឺពេទ្យនៅទីនោះហើយ ពេទ្យនៅការដ្ឋានលើកទំនប់នោះហើយ។ ប៉ុន្តែដោយសារតែអាស្ពារីនមួយគ្រាប់នេះ មើលទៅស្ថានភាពរបស់នាងខ្ញុំហ្នឹងវាធ្ងន់ធ្ងរពេក ប្រហែលជាមិនដាច់ចិត្តឲ្យស្លាប់។ យោងទៅតាមបង ឃឹម ស៊ីថូ ដែលគាត់លើកដៃសំពះនោះ ហុចមួយគ្រាប់ហ្នឹងមក គាត់អត់ស្គាល់ទេ មានតែខ្ញុំទេដែលជាអ្នកស្គាល់ មើលអក្សរទៅ គេដាក់អាស្ពារីន។ ប៉ុន្តែមិនងាយរកទេថ្នាំហ្នឹង មិនងាយអ្នកណាទទួលបានទេ សូមជម្រាបដែរចាស។ ប៉ុន្តែជាអកុសល -- ជាកុសលផលបុណ្យរបស់នាងខ្ញុំហើយ ដែលបានទទួលបានថ្នាំមួយគ្រាប់នោះ។

**ស៖** នេះជាចំណុចចុងក្រោយរបស់ខ្ញុំ លោកស្រីបានឆ្លើយថា គេធ្លាប់បញ្ជូនលោកស្រីទៅអប់រំជាមួយនឹងមិត្តភក្តិពីរនាក់ ក្រោយពីពេលលោកស្រីមិនព្រមចេញពីសហករណ៍មួយ។ នៅក្នុងចម្លើយរបស់លោកស្រី គឺឯកសារ E3/5965 គឺមានសរសេរថា ខ្ញុំសូមយកលេខយោងជាភាសាអង់គ្លេស គឺឯកសារ E319/27.4.13 ERN ជាភាសាអង់គ្លេសគឺ 01098616។ ហើយខ្ញុំនឹងសូមដកស្រង់ជាភាសាអង់គ្លេស លោកស្រីបានឆ្លើយ ដើម្បីសង្ខេប នៅពេលដែលលោកស្រីបានត្រឡប់ទៅផ្ទះម្តាយលោកស្រីវិញនោះ លោកស្រីបាននិយាយថា លោកស្រីបានចេញពីកន្លែងដែលគេចាត់តាំងឲ្យទៅធ្វើការនោះរយៈពេល៣ថ្ងៃ ពេលដែលលោកស្រីត្រឡប់មកវិញ លោកស្រីបានឆ្លើយដូចតទៅនេះ ខ្ញុំដកស្រង់ជាភាសាអង់គ្លេស៖ "នៅពេលនោះខ្ញុំទៅដល់កង គេដូរកងស្ត្រីម្នាក់ឈ្មោះ តាគីម ហៅខ្ញុំទៅឲ្យរៀនសូត្រ។" អ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ តើលោកស្រីត្រូវបានគេអប់រំច្រើនដងដែរឬទេ ថាក្រោយពីលោកស្រីបានជំទាស់មិនព្រមចេញពីសហករណ៍ ហើយមួយទៀត គឺពេលដែលលោកស្រីអវត្តមាន ដោយមិនមានការអនុញ្ញាតទៅមើលម្តាយលោកស្រីនោះ ឬក៏មានអ្វីខុសពីនេះទៀត ក្រៅពីចម្លើយដែលលោកស្រីបានផ្តល់នៅក្នុងទម្រង់បែបបទរបស់លោកស្រី?

[១៦:២០:៣២]

**ឆ៖** ចាស គេមកយកខ្ញុំទៅវិញនេះ គឺមិនមែនយកទៅកសាងទេ គេយកទៅកន្លែងធ្វើការងារវិញ។ តែនាងខ្ញុំជំទាស់នេះ បានជាគេដាក់ច្រវាក់បណ្តើរទាំងយប់នោះ ដោយសារតែគេណែនាំតាំងពី

ពេលព្រឹក រហូតដល់ល្ងាចនៅតែខ្ញុំប្រកែកទៀត។ ដល់អ៊ីចឹងព្រលប់ៗហើយហ្នឹង គេហៅទៅប្រជុំ គេប្រធានសហករណ៍ទៅប្រជុំដែរ សូមបញ្ជាក់។ ឲ្យទៅប្រជុំដើម្បីបោកៗឲ្យរូបនាងខ្ញុំចូលខ្លួនទៅជួបគេ ដើម្បីគេដាក់ច្រវាក់ចងយកទៅ ចូលទៅការដ្ឋានកន្លែងយើងធ្វើការងារ។

**ស៖** ខ្ញុំយល់ហើយ គឺថានៅពេលដែលលោកស្រីត្រូវចេញពីសហករណ៍នោះ។ សំណួររបស់ខ្ញុំនោះ គឺយ៉ាងដូច្នេះទេ គឺថានៅពេលដែលលោកស្រីត្រឡប់មកវិញ ពេលលោកស្រីទៅលេងម្ដាយលោកស្រី៣ថ្ងៃហើយហ្នឹង គេមានអប់រំលោកស្រីដែរឬទេ កាលនុ៎ង?

**ឆ៖** នៅគេបណ្ដើរ ដូចខ្ញុំបានបញ្ជាក់ពីព្រឹកមិញហើយ គេបណ្ដើរខ្ញុំយកទៅដល់កន្លែងគេហ្នឹង។ គេបានឲ្យញ៉ាំបាយហើយៗហ្នឹង គេបានណែនាំហើយ កសាងហើយ។ គេថា "មិត្តឯង អត់មានថ្ងៃមុខថ្ងៃក្រោយធ្វើអ៊ីចឹងទៀតទេ។ ឈប់ពីពេលហ្នឹងទៅ កុំធ្វើអ៊ីចឹងទៀត។ ពេលនេះអង្គការតាមអង្វរមិត្តឯងរាល់គ្នាហ្នឹងហើយ ប៉ុន្តែថ្ងៃក្រោយហ្នឹង មិត្តឯងកុំភ្លេចថា មិត្តឯងទៅអង្វរអង្គការវិញនោះ មិត្តឯងកុំភ្លេច។ ពេលនេះអង្គការតាមអង្វរមិត្តឯង។ តែកុំភ្លេចថ្ងៃក្រោយ ប្រយ័ត្នទៅតាមអង្វរអង្គការវិញ"។ ចាស ហ្នឹងគេព្រមានអ៊ីចឹង។

[១៦:២២:៣៦]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ដោយមើលទៅឃើញពេលវេលាកាន់តែទៅមុខហើយ ខ្ញុំសូមបញ្ចប់ត្រឹមណេះតែម្ដង លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។ សវនាការនៅថ្ងៃនេះ ដល់ឈប់សម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០២ ខែកញ្ញា ឆ្នាំពីរពាន់--

អញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមអធ្យាស្រ័យលោកប្រធាន ដែលកាត់លោកប្រធានយ៉ាងដូច្នេះ។ លោកប្រធានមិនបានទាន់ផ្ដល់ឱកាសដល់លោកស្រី ដើម្បីលើកជាសំណួរតាមរយៈលោកប្រធាន ជូនទៅជនជាប់ចោទទេលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញលោកស្រី ចៅ ឡាង ហើយមានសំណួរឯណាចង់សួរទៅចំពោះជនជាប់ចោទតាមរយៈយើងដែរឬទេ? បើមាន សូមអញ្ជើញបាទ!

[១៦:២៣:៤២]

**លោកស្រី ចៅ ឡាង៖**

ចាស សូមអរគុណលោកប្រធាន។ សូមគោរព និងសូមអរគុណលោកប្រធាន។ នាងខ្ញុំមានសំណួរពីរចំណុចដែលត្រូវសួរ។ តើលោក ខៀវ សំផន លើកឡើងថា មិនប្រាថ្នាជម្លៀស មិនប្រាថ្នាសម្លាប់ តើនរណាជាអ្នកធ្វើបញ្ហាទាំងអស់នោះ? មួយ។ មួយទៀត ពីរ លោក ខៀវ សំផន លោកបានលើកឡើងថា មិនចង់និយាយជាមួយអ្នកដែលមិនចង់ស្តាប់ តើជនរងគ្រោះ និងអ្នកដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះ មិនចង់ស្តាប់គាត់ ឬយ៉ាងណា? ចាស សូមអស់ អស់សំណួរហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី ចៅ ឡាង ហើយអង្គជំនុំជម្រះសូមជម្រាបលោកស្រីថា នៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានស្តាប់ជនជាប់ចោទទាំងពីររូបឆ្លើយបញ្ជាក់ពីការដែលពួកគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ។ អង្គជំនុំជម្រះបានកត់សម្គាល់ថា ជនជាប់ចោទទាំងពីរនាក់ នៅតែរក្សាជំហររបស់ខ្លួន បន្តអនុវត្តនូវសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល។ លើកលែងតែ និងរហូតដល់ពេលណា ដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានព័ត៌មានជាក់ច្បាស់ផ្សេងទៀតពីជនជាប់ចោទ ឬពីសហមេធាវីការពារក្តីរបស់ជនជាប់ចោទ។ ហើយនៅក្នុងសវនាការនោះ អង្គជំនុំជម្រះបានកំណត់ឲ្យជនជាប់ចោទ និង/ឬ មេធាវីការពារក្តីរបស់ជនជាប់ចោទត្រូវមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការជូនដំណឹងមកដល់អង្គជំនុំជម្រះឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទ សម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះ ឬក៏ភាគីពាក់ព័ន្ធនៅដំណាក់កាលមួយនៃកិច្ចដំណើរការសវនាការ។ ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្តូរជំហររបស់ជនជាប់ចោទទាំងពីរនាក់ ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប មកជាការយល់ព្រមឆ្លើយតបនឹងសំណួរនៅឡើយទេ។

[១៦:២៥:៥០]

បាទ ហើយសវនាការថ្ងៃនេះ អង្គជំនុំជម្រះប្រកាសផ្អាកហើយត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០២ ខែកញ្ញា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើការស្ដាប់សេចក្ដីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីររូប 2-TCCP-993 និង 994 ពាក់ព័ន្ធនឹងការដ្ឋានទំនប់ត្រពាំងថ្ម សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះសូមអរគុណលោកស្រី ចៅ ឡាង សវនាការស្ដាប់សេចក្ដីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មដែលលោកស្រីអះអាងថា លោកស្រីបានទទួលរងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពាក់ព័ន្ធនឹងអង្គហេតុការដ្ឋានទំនប់១មករានោះ ដល់ទីបញ្ចប់ហើយ ហើយលោកស្រីអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនលោកស្រី ចៅ ឡាង វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ និងឲ្យជូនដើមបណ្ដឹងរដ្ឋប្បវេណីពីររូបផ្សេងទៀតដែលបានបម្រុងទុកនៅថ្ងៃនេះ ត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់មកចូលរួមសវនាការនៅថ្ងៃស្អែកវិញឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះអរគុណលោកស្រី ឆាយ ម៉ារីដែត ជាបុគ្គលិកអង្គការ ធី.ភី.អូ លោកស្រីអាចសម្រាកបានហើយ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:២៧ នាទី)*